- Waste recycling volumes and recycling ratios tend to consistently rise after establishment of recycling laws.




Municipal waste: Data collected in FY08.
Industrial waste: Data collected in FY07

Copyright METI

# Background of Containers and Packaging Recycling Law

It is necessary to solve problems of tight final disposal site and establish recycling-oriented society aiming for zero refuse with the increase of disposal volume for Municipal waste.

Containers and packaging waste counts up about 60% of household waste (volume ratio)




※ Ratio by volume and by weight was calculated based on the sample survey targeting for 6 cities and 3 areas across the nation.

Copyright METI

# Overview of Containers and Packaging Recycling Law

The basic principle of this law is that every player has a role to play in recycling. Consumers should separate their waste according to category, municipalities should collect the separated waste, and businesses should recycle what has been collected into new products.




Copyright METI

## Issues and concerns about the Law

Copyright METI

Currently, we identify some issues and concerns about Japan's Containers and Packaging Law such as
1) efficiency of recycling system (e.g. cost reduction, cost efficiency and creation of high value-added recycled products),
2) improvement of fairness, transparency and stability,
3) promotion of prevention and re-use.

**1. efficiency of recycling system**
- ✓ Cost reduction / cost efficiency
  - including social costs of the whole processes: from separate collection to recycling
- ✓ Creation/promotion of high value-added recycled products

**2. improvement of fairness, transparency and stability**
- ✓ Reconsideration of roles and responsibilities of relevant players (i.e. consumers, local governments and Designated Manufacturer/Users) and their cooperation
  - based on the idea of EPR
- ✓ Prevention of free-riders

**3. promotion of prevention and re-use**
- ✓ Methods for setting quantitative prevention targets and units

# Seeking the possibility and suitable technologies of waste plastics recycling for developing countries

UNEP United Nations Environment Programme

National Institute of Advanced Industrial Science and Technology AIST

**UNEP-AIST Workshop on Waste Plastics-to-Resources**

AIST Tsukuba Center
March 1 – 4, 2011





City officials, researchers and technology providers from Thailand, Philippines, and Japan gathered at AIST under the framework of UNEP.

# Plastic waste conversion to liquid fuel in Thailand. Case Study : Warinchamrap Municipality

Budget Supporting By
Energy Policy and Planning Office,
Ministry of Energy,
Royal Thai Government

Rungnapa Tubnonghee
Warinchamrap Municipality
& Muang Sa-ad Co.Ltd

# Outline of Presentations

1. Introduction
2. Current status of reforming MPW to useful oil in Thailand
3. Characteristics and qualities of the pyrolytic oil (Liquid Fuel)
4. Prospect of technology and industry for reforming MPW to useful oil
5. Ackhowledgement

# 1.Introduction




3

# 1.Introduction

- The generation amount of MSW in Warinchamrap Municipality is ~ 24-25 tons per day.
- The recyclable waste is about 20% of total MSW (12.6% of plastic waste (PW)).





4

# 90% of municipal plastic waste is PE and PP. Most of these waste is disposed in landfill.






- Thai government Policy of Renewable energy promoted local organization to converse MSW to energy.

- The Energy Policy and Planning Office (EPPO), Ministry of Energy, Royal Thai Government provided budgets for 3 pilot projects in 2009-2010: Warinchamrap , Khonkhan, and Pitsanulok Municipality.

# 2.Current status of reforming MPW to useful oil in Thailand

**(Muang Sa-ad Co., plant of Warinchamrap site)**











**Disposed waste at the landfill cell (G mine) is 125,000 tons (7years)**





# The process consists of 2 parts:

## 1.Separation of MSW





## 2.Pyrolysis of MPW







# 1. Separation of MSW at the front end system







# The mixed plastic waste





11

# Cleaning and drying











# MPW Raw Material for Pyrolysis




HDPE LDPE PP

**90% of mixed plastic waste are PE and PP**



# 2. Pyrolysis of MPW waste



## Concept of Pyrolysis

**Process of Plastic Production is Polymerization**

**Decomposition of plastic is De-Polymerization**




## Pyrolysis Process

C-H Bond (Polymer)




**Thermal degradation**

↓

**Catalytic degradation**

**Operate with high temperature ($< 500^{o}$ C) in absent oxygen or without oxygen and then produce liquid hydrocarbon and syn-gas**

# Pyrolysis Process





# Pyrolytic oil



# By Product; Wax and Carbon Black





# Ratio and capacity of production




| | Mixed plastic waste (tons) | Crude oil (Liter) | Crude oil (Barrel) |
|---|---|---|---|
| Day | 10 | 6,600 | 40.3 |
| MO | 300 | 198,000 | 1,209.8 |
| Year | 3,000 | 1,980,000 | 12,098.3 |

Yield of production 60% →

# 3.Characteristics of Pyrolytic oil



The major products in the pyrolytic oil for MPW were having a group of diesel range, as well as that of kerosene and gasoline range.



# 3.Characteristics of pyrolytic oil





- Quality Improvement of the pyrolytic oil is carried out by using coagulation technique.

# 4. Prospect of technology and industry for reforming MPW to useful oil



As the economic support from Ministry of Energy in Thailand is guarantee of price on 18 bahts per liter for a distillation industry.



# Utilization of Distilled pyrolytic oil with diesel engine







# Utilization of pyrolytic oil with gasoline engine





# CONCLUSION

- The technology for reforming MPW to oil is applicable for plastic waste recycling in Thailand.

- This technology can save the space for landfill and thus extend lifetime of landfill and also avoid CO2 emission from burning of plastic waste.

# CONCLUSION

- The characteristic of PO is similar to crude oil. It will be improved to useful fuel oil by distillation.

- Moreover, the distillation of crude oil for valuable diesel-range and gasoline-range hydrocarbons similar commercial oil quality is still required and developed for a standard and safety engine concern.

27

# Distilled Oil



# ACKNOWLEDGMENT


- Muang Sa-ad Company and National Center of Excellence for Environmental and Hazardous Waste Management, Ubon Ratchathani University, Thailand.

- We are also very grateful to Associate Prof Tharapong Vitidsant, Faculty of Science, Chulalongkorn University, Thailand for his dedication and suggestion.


29

# Thank you for attention

Kub Khun Kaa & Sawadee



**Polymer Energy Technology**
**Green Business : Win- Win Solution**

30


การพัฒนาเมืองอย่างยั่งยืน สู่ความเป็นเมืองวารินน่าอยู่


ការកសាងសមត្ថភាពលើការសម្រេចចិត្តជ្រើសរើសវិធានការគ្រប់គ្រងសំណល់សរីរាង្គ ចូលរួមកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់នៅព្រះរាជាណាចក្រកម្ពុជា
គំនិតផ្តួចផ្តើមគ្រប់គ្រងសំណល់តាមគោលការណ៍នៃ
ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ
នៅព្រះរាជាណាចក្រកម្ពុជា
COMPED
បទបង្ហាញដោយ
លោកបណ្ឌិត ជ្រិន សុខា
អគ្គនាយករងបច្ចេកទេស នៃក្រសួងបរិស្ថាន
13/05/2008

## ចំណុចដែលត្រូវធ្វើបទបង្ហាញ

១. គោលការណ៍នៃការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R) ជាអ្វី?

២. ហេតុអ្វីយើងត្រូវការ 3R?

៣. សកម្មភាពទាក់ទងនឹង 3R នៅកម្ពុជា

៤. សេចក្តីព្រាងយុទ្ធសាស្រ្តអនុវត្តគោលការណ៍ 3R

៥. សេចក្តីសន្និដ្ឋាន

## ១. គោលការណ៍នៃការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃជាអ្វី?

- ការកាត់បន្ថយ ជាជំរើសក្នុងការប្រើប្រាស់វត្ថុធាតុដើម ឬផលិតផលអោយអស់លទ្ធភាពដើម្បីកាត់បន្ថយបរិមាណសំណល់ដែលត្រូវបង្កើតឡើង។
- ការប្រើប្រាស់ឡើងវិញ ជាជំរើសពាក់ព័ន្ធនឹងការប្រើប្រាស់វត្ថុនិងសារធាតុផ្សេងៗឡើងវិញ ឬផ្នែកខ្លះនៃវត្ថុ ឬសារធាតុដែលអាចប្រើប្រាស់អោយអស់លទ្ធភាពមុននឹងធ្វើការបោះបង់ចោល។
- ការកែច្នៃ ជាការប្រើប្រាស់សំណល់ទៅតាមប្រភេទសម្រាប់ជាធនធានបម្រើដល់ផលិតកម្មកែច្នៃ ឬផលិតកម្មពាក់កណ្តាលសម្រេច ។

## ១. គោលការណ៍នៃការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃជាអ្វី? (ត)

- គោលដៅទី៧ នៃការអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា : "*ធានានូវចីរភាពបរិស្ថាន*" មានទំនាក់ទំនងជិតស្និទ្ធនឹងការអនុវត្តកម្មវិធីនៃការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ (3R) ដោយប្រសិទ្ធិភាព ពុំបង្កការប៉ះពាល់ ឬសម្ពាធដល់បរិស្ថាន ប្រព័ន្ធអេកូឡូស៊ី និងសុខភាពសាធារណៈ។

## ១. គោលការណ៍នៃការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃជាអ្វី? (ត)

- នៅក្នុងការគ្រប់គ្រងសំណល់ ការអនុវត្តន៍គោលការណ៍នៃការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ ជាដំណោះស្រាយជាក់ស្តែង :
  - កាត់បន្ថយហានិភ័យ និងគ្រោះថ្នាក់ដល់<u>បរិស្ថាន និងសុខភាពសាធារណៈ</u>
  - កែលម្អផលិតភាព និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធិភាពខ្ពស់
  - រួមចំណែកកាត់បន្ថយដល់កត្តាដែលជម្រុញអោយកើតមានការប្រែប្រួលអាកាសធាតុ
  - បង្កើនកាលានុវត្តភាពការងារដល់សហគមន៍មូលដ្ឋានពិសេសប្រជាពលរដ្ឋក្រីក្រ

# ២. ហេតុអ្វីយើងត្រូវការ 3R?




# ២. ហេតុអ្វីយើងត្រូវការ 3R? (ត)




- ការសិក្សាសមាសធាតុសំណល់ទីក្រុង(COMPED) បានបង្ហាញអំពីភាគរយខ្ពស់នៃសំណល់ ដែលអាចធ្វើការកែច្នៃនៅក្នុងស្រុក ឬកែច្នៃជាផលិតផលពាក់កណ្តាលសម្រេចដើម្បីនាំចេញទៅប្រទេសក្រៅ

## ២. ហេតុអ្វីយើងត្រូវការ 3R? (ត)

- ក្នុងបរិបទកម្ពុជា ការចំណាយលើការគ្រប់គ្រងសំណល់ស្ថិតក្នុងកម្រិតទាប បើសិនអនុវត្តនៅតាមគោលការណ៍ 3R និងមានអត្ថប្រយោជន៍ច្រើន ធៀបនឹងវិធីសាស្ត្រគ្រប់គ្រងតាមបែបសាមញ្ញ :
  - សេវាកម្មប្រមូល ដឹកជញ្ជូន ការគ្រប់គ្រង-ថែរក្សានៅទីលាន
  - ការប្រើប្រាស់ទីលាន អាចមានរយៈពេលយូរជាងការគ្រប់គ្រងសំណល់តាមបែបធម្មតា
- សំណល់ដែលអាចធ្វើការកែច្នៃ គឺជាប្រាក់.....

## ៣. សកម្មភាពទាក់ទងនឹង 3R នៅកម្ពុជា

- សក្តានុពលភាពលើការគ្រប់គ្រងសំណល់តាមគោលការណ៍ 3R នៅកម្ពុជាមានច្រើន ប៉ុន្តែការអនុវត្តមានកម្រិតនៅតាមប្រភពមួយចំនួន និងពុំទាន់មានការចាប់អារម្មណ៍ជាទូទៅនៅឡើយ។
  - គោលការណ៍ 3R ពុំទាន់ត្រូវបានចាត់ទុកជាកត្តាអាទិភាពនៅក្នុងផែនការអភិវឌ្ឍន៍ជាតិ
  - ពុំទាន់មានបរិធានច្បាប់ដែលជម្រុញការអនុវត្តន៍គោលការណ៍ 3R អោយបានត្រឹមត្រូវ
  - ការយល់ដឹងអំពីគោលការណ៍ 3R និងបច្ចេកទេសអនុវត្តនៅមានកំរិត ជាមូលហេតុចម្បងនៃកង្វះការចូលរួមពីភាគីពាក់ព័ន្ធ

# ៣. សកម្មភាពទាក់ទងនឹង 3R នៅកម្ពុជា (ត)

- នៅតាមខេត្ត-ក្រុង សកម្មភាពអនុវត្តគោលការណ៍ 3R ទៅលើការគ្រប់គ្រងសំណល់ មានលក្ខណៈជាប្រព័ន្ធផ្សេងគ្នា :
  - អ្នកបង្កើតសំណល់ និងអ្នកប្រមូលទិញសំណល់ដែលអាចធ្វើការកែច្នៃ
  - អ្នករើសសំណល់ដែលអាចធ្វើការកែច្នៃនៅតាមតំបន់សាធារណៈ និងទីលានចាក់សំណល់
  - អ្នកប្រមូលសំណល់ដែលអាចធ្វើការកែច្នៃ (ស្ថិតក្នុងសេវាកម្មប្រមូល និងដឹកជញ្ជូនសំណល់)
  - ម្ចាស់ដេប៉ូប្រមូលទិញសំណល់ដែលអាចធ្វើការកែច្នៃ
  - អាជីវករ សហគមន៍មូលដ្ឋាន ឬអង្គការក្រៅរដ្ឋាភិបាល ដែលមានអាជីពទាក់ទងនឹងការកែច្នៃសំណល់




ទិដ្ឋភាពរួមនៃការធ្វើជីកំប៉ុសរបស់អង្គការ COMPED



ទិដ្ឋភាពរួមនៃការវេចខ្ចប់សំបកកំប៉ុងមុននឹងធ្វើការនាំចេញ




ទិដ្ឋភាពរួមនៃសកម្មភាពកែច្នៃសំណល់ប្លាស្ទិកនិងផលិតផលកែច្នៃ



ទិដ្ឋភាពរួមនៃការកែច្នៃសំណល់កំទេចក្រណាត់ ជាផលិតផលប្រើប្រាស់




ទិដ្ឋភាពរួមនៃការកែច្នៃសំណល់អាគុយ ដើម្បីធ្វើការនាំចេញ




# ៤. សេចក្តីព្រាងយុទ្ធសាស្ត្រអនុវត្តគោលការណ៍ 3R

- សេចក្តីព្រាងយុទ្ធសាស្ត្រអនុវត្តគោលការណ៍ 3R មាន គោលបំណងរៀបចំប្រព័ន្ធគ្រប់គ្រងសំណល់ដោយប្រសិទ្ធិភាព និងផ្តល់កាលានុវត្តភាពការងារ ប្រាក់ចំណូលដល់ប្រជាពលរដ្ឋ កាត់បន្ថយបរិមាណសំណល់នៅទីលាន និងពុំបង្កអោយកើតមានហានិភ័យ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរដល់បរិស្ថាន ជីវៈចម្រុះ និងសុខភាពសាធារណៈ។
  - ប្រភេទសំណល់ស្ថិតក្នុងគោលបំណងនៃការគ្រប់គ្រងរបស់យុទ្ធសាស្ត្រនេះ រួមមាន : សំណល់លំនៅដ្ឋាន សំណល់ឧស្សាហកម្ម និងសំណល់ផ្នែកសុខភាព។

## ៤. សេចក្តីព្រាងយុទ្ធសាស្ត្រអនុវត្ត គោលការណ៍ 3R (ត)

➢ ការគ្រប់គ្រងប្រភេទសំណល់ទាំងនេះ ដោយផ្អែកលើគោលការណ៍សុវត្ថិភាពបរិស្ថាន :

- ការស្តុកទុក ការប្រមូលនិងការដឹកជញ្ជូនសំណល់ដើម្បីបោះចោលនៅទីលាន
- ការញែកសំណល់ដើម្បីធ្វើការកែច្នៃ
- ការធ្វើកំប៉ុសសរីរាង្គ
- ការរៀបចំនិងការប្រតិបត្តិនៅទីលាន ទៅតាមសេចក្តីចែងក្នុងបញ្ញត្តិច្បាប់

## ៤. សេចក្តីព្រាងយុទ្ធសាស្ត្រអនុវត្ត គោលការណ៍ 3R (ត)

❑ ស្ថិតក្នុងចក្ខុវិស័យនៃឆ្នាំ២០១៥ និង ២០២០ សេចក្តីព្រាងយុទ្ធសាស្ត្រគ្រប់គ្រងសំ... ឡើងនូវយុទ្ធសាស្ត្រអាទិ... ខាងក្រោម :

មានទិសដៅរៀបចំគោលនយោបាយនិងបញ្ញត្តិច្បាប់សំដៅគ្រប់គ្រងសំណល់លំនៅដ្ឋាននិងសំណល់ឧស្សាហកម្មតាមគោលការណ៍ 3R

➢ *យុទ្ធសាស្ត្រទីមួយ* : រៀបចំគោលនយោបាយនិងបទបញ្ញត្តិអនុវត្តគោលការណ៍ 3R នៅក្នុងការគ្រប់គ្រងសំណល់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ។

# ៤. សេចក្តីព្រាងយុទ្ធសាស្ត្រអនុវត្តគោលការណ៍ 3R (ត)

- ***យុទ្ធសាស្ត្រទីពីរ***
  អនុវត្តគោលការណ៍
  សមត្ថភាពដល់មន្ត្រី
- ***យុទ្ធសាស្ត្រទីបី*** :
  គោលការណ៍ 3R
  ផ្តោតទៅការគ្រប់គ្រង
  បានជ្រើសរើស។

អនុវត្តគោលការណ៍ 3R ជាក់ស្តែងទៅលើប្រភេទសំណល់ជ្រើសរើស ដើម្បីជាឧទាហរណ៍នៃប្រសិទ្ធភាពគ្រប់គ្រងសំណល់

មានទិសដៅរៀបចំ និងលើកកំពស់ បង្កើនសមត្ថភាពបច្ចេកទេសនិងពង្រឹងស្ថាប័នទទួលបន្ទុកនិងពាក់ព័ន្ធការគ្រប់គ្រងសំណល់តាមគោលការណ៍ 3R

# ៤. សេចក្តីព្រាងយុទ្ធសាស្ត្រអនុវត្តគោលការណ៍ 3R (ត)

- ***យុទ្ធសាស្ត្រទី***
  គោលនយោ
  របស់រដ្ឋ និង
- ***យុទ្ធសាស្ត្រទី***
  ផ្តួចផ្តើម 3R
  អភិវឌ្ឍន៍ជាតិ

ធ្វើសមាហរណកម្មគោលការណ៍ 3R ទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជាតិ ដើម្បីចីរភាពបរិស្ថាន

ការលើកកំពស់និងបង្កើនការយល់ដឹងអំពីគោលការណ៍ 3R ដល់បណ្តាអ្នកពាក់ព័ន្ធ និងធ្វើការអនុវត្តទៅលើគោលដៅជាក់លាក់

## ៥. សេចក្តីសន្និដ្ឋាន

- សេចក្តីព្រាងយុទ្ធសាស្ត្រអនុវត្តគោលការណ៍ 3R និងធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លើយតបនឹងតម្រូវការបច្ចុប្បន្ន ដោយផ្អែកលើទិន្នន័យនិងព័ត៌មាន រួមនឹងគោលនយោបាយរបស់រដ្ឋាភិបាល។
- ទោះបីយ៉ាងណាក៏ដោយ គំនិតផ្តួចផ្តើមនៃការអនុវត្តគោលការណ៍ 3R បានបញ្ជ្រាបទៅក្នុងផែនការយុទ្ធសាស្ត្របរិស្ថាន ឆ្នាំ២០០៩ – ២០១៣ ។
  - គំនិតផ្តួចផ្តើមនេះ ក៏កំពុងពិចារណាបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យការបំពុលបរិស្ថាន ។

**សូមអរគុណ ជាអនេកប្បការ**

# ការធ្វើជីកំប៉ុសតាមបែបវិមជ្ឈការ ជាផ្នែកមួយនៃការគ្រប់គ្រងសំណល់រឹងទីក្រុង បទពិសោធន៍ ពីទីក្រុង Surabaya, ប្រទេសឥណ្ឌូណេស៊ី

វាគ្មិន D.G.J.PREMAKUMARA, Policy Researcher, IGES

## សង្ខេប បទបង្ហាញ

- ការណែនាំអំពីការធ្វើជីកំប៉ុសបែបវិមជ្ឈការ ជាការគ្រប់គ្រងសំណល់រឹងទីក្រុង
- ពិភាក្សាករណីសិក្សា នៅ Surabaya
- ចង្អុលបង្ហាញនូវសក្តានុពល និងការមធ្យោបាយកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់ឆ្លង តាមរយៈការធ្វើជីកំប៉ុស
- សរុបសេចក្តី និងអនុសាសន៍

ការធ្វើចំណាកស្រុកមកនៅទីក្រុង និងការកើនឡើងសេដ្ឋកិច្ចឆាប់រហ័សគឺជាមូលហេតុដែលធ្វើអោយមានការកើនឡើងសំណល់រឹងយ៉ាងរហ័ស។

ទីក្រុងកំពុងអភិវឌ្ឍន៍នៅអាស៊ី កំពុងប្រឈមមុខនឹងលើការយក សំណល់រឹងទីក្រុង ទៅចាក់ចោលនៅទីលានចំហ មិនតាមបទដ្ឋានបរិស្ថាន។ ការធ្វើរបៀបនេះអាចធ្វើអោយប៉ះពាល់ដល់បរិស្ថាន សុខភាព និងការរស់នៅ ធ្វើអោយសាយភាយឧស្ម័នផ្ទះកញ្ចក់ចូលទៅក្នុងបរិយាកាស និងធ្វើអោយខូចខាតនូវធនធានមួយចំនួនដែលអាចប្រើប្រាស់វិញបាន។

## ការមិនប្រើប្រាស់សក្តានុពលសំណល់សរីរាង្គក្នុងសំណល់រឹងទីក្រុង

គណនាបានបង្ហាញថា ជាងពាក់កណ្តាលសំណល់ទីក្រុងក្នុងតំបន់អាស៊ាន គឺជាសំណល់សរីរាង្គ ដែលងាយយកធ្វើជីកុំប៉ុស ប៉ុន្តែមិនទាន់បានទាញយកប្រយោជន៍ប្រកបដោយប្រសិទ្ធភាពនៅឡើយ។




## ការធ្វើជីកំប៉ុសបែបវិមជ្ឈការ

ធ្វើជីកំប៉ុសបែបវិមជ្ឈការ មានទីតាំងនៅក្បែរប្រភពសំណល់ ប្រើប្រាស់បច្ចេកទេសសមរម្យ ខ្នាតតូចៗ បង្កើតឲ្យមានការងារធ្វើ ទទួលស្គាល់ពីប្រជាពលរដ្ឋ និងការសន្សំសំចៃបានច្រើនទៅការចំណាយលើការងារគ្រប់គ្រងសំណល់។

**ការធ្វើកំប៉ុសតាមផ្ទះ ឬការធ្វើកំប៉ុសបែប គ្រួសារ** ( ធ្វើទៅបាន សម្រាប់ប្រជាពលរដ្ឋដែលមានការយល់ដឹងលើការងារធ្វើកុំប៉ុស និងមានដី)។

**ធ្វើជីកំប៉ុស ជាសហគមន៍** (ជាទូទៅ ជាខ្នាតតូច និងបញ្ចូលជាមួយនឹងប្រព័ន្ធគ្រប់គ្រងសំណល់ ប្រមូលសំណល់។ សំណល់ទាំងអស់ត្រូវបានញែកនៅប្រភព ឬញែកក្រោយពេលប្រមូលរួច វាអាស្រ័យកម្រិតនៃការចូលរួម របស់ប្រជាពលរដ្ឋ។



## ករណីសិក្សា នៅ Surabaya

ទីក្រុង Surabaya មានប្រជាជនរស់នៅជាង៣លាននាក់ (ឆ្នាំ ២០១០) គឺជាទីក្រុងធំលំដាប់ទី២ នៅប្រទេសឥណ្ឌូណេស៊ី ជាកន្លែងតំបន់ពាណិជ្ជកម្មសំខាន់ ជាទីក្រុងឧស្សាហកម្ម នៅកោះជ្វាខាងកើត។

នៅ Surabaya ការគ្រប់គ្រងសំណល់រឹងទីក្រុងធ្វើឡើងពីរដំណាក់ (ច្បាប់សហគមន៍បឋម ស្តីពីការប្រមូលសំណល់ (Coprocol) ឆ្នាំ ១៩៨០)។

ជាការទទួលខុសត្រូវរបស់សហគមន៍ **(Kampong)**។ ការប្រមូលសំណល់ត្រូវបានចាត់ចែងដោយក្រុមសហគមន៍ តាមរយៈអង្គការ **(Rukun Warga)**។ ផ្ទះនីមួយៗត្រូវបង់ថ្លៃសេវាប្រមូលសំណល់។

សំណល់ត្រូវបានរៀបចំទុកដាក់តាមផ្ទះ សម្រាប់ការប្រមូល យកទៅដាក់នៅ ដេប៉ូបណ្តោះអាសន្ន។ នៅទីនោះសំណល់ត្រូវបានលើកដាក់ទៅក្នុង រថយន្តដឹកជញ្ជូនសំណល់ ចាក់ចោលនៅទីលានចាក់សំរាម។

អនាម័យ និងសំអាតសួន និងផ្លូវថ្នល់ ជាការទទួលខុសត្រូវ ដោយក្រុង។ ផ្ទះនីមួយៗត្រូវបង់ថ្លៃសេវាប្រមូលសំណល់។ សំណល់ឧស្សាហកម្មត្រូវបានប្រមូលនិងដឹកជញ្ជូនដោយក្រុង។

## ការគ្រប់គ្រងសំណល់រឹងទីក្រុងបានក្លាយជាចំណោទធ្ងន់ធ្ងរនៅក្នុងទីក្រុង Surabaya

- ការបង្កើតសំណល់សរុប ១៨០០តោនក្នុងមួយថ្ងៃ ក្នុងឆ្នាំ ២០០៤ (តាមផ្ទះ ៦៨%, តាមផ្សារ ១៦%, ពាណិជ្ជកម្ម/សហគ្រាស ១១%, និងតាមផ្លូវសាធារណៈ ៥%)
- ការប្រមូលសំណល់ទីក្រុងបានត្រឹមតែ ៧០% ហើយផ្សេងទៀតត្រូវបានយកទៅចាក់ចោលនៅតាមដងផ្លូវ, ប្រឡាយទឹក និងទីសាធារណៈ
- ទីលានចាក់សំរាម Keputih ចោលកាកសំណល់ត្រូវបានបិទនៅឆ្នាំ ២០០១ ដោយហេតុ មកពីមានការប្រឆាំង ពីប្រជាពលរដ្ឋ នៅជិតកន្លែងនោះ។ មានតែ Benowa ដែលប្រើសំរាប់ ចាក់សំណល់ ដែលរួចទៅហើយ។ ការស្វែងរកទីលានថ្មី មានការពិបាកដោយសារដីរដ្ឋមានតិច។
- ទីលានចាក់សំរាម មិនបានអភិវឌ្ឍន៍ត្រឹមត្រូវ ហើយការដុតសំណល់ប្លាស្ទិកកើតឡើងជាច្រើន។

## សហគមន៍គំរូ នៅ Kampong Rungkut Lor អភិវឌ្ឍន៍ក្រោមកិច្ចសហប្រតិបត្តិការ បច្ចេកវិទ្យា ទីក្រុង Kitakyushu , ប្រទេសជប៉ុន

- អប់រំដល់ស្ត្រីអោយចាប់អារម្មណ៍លើសំណល់កែច្នៃបានជាប្រភពចំណូល
- ធ្វើការអប់រំតាមផ្ទះអោយធ្វើការញែកសំណល់នៅតាមប្រភព ហើយធ្វើកំប៉ុស
- ធ្វើការអប់រំតាមផ្ទះអោយចាប់ផ្តើមធ្វើកសិកម្មតាមបែបធម្មជាតិ តាមគ្រួសារ និងសហគមន៍
- សំណល់សរីរាង្គដែលប្រមូលបានពីការញែកនៅប្រភព ត្រូវបានប្រមូលយកធ្វើកំប៉ុសតាមសហគមន៍

និងកំប៉ុសដែលផលិតបានយកទៅលក់នៅទីផ្សារ។

## អភិវឌ្ឍន៍ អនុសាសន៍ គ្រប់គ្រងសំណល់រឹង ផ្នែកគំរូគ្រប់គ្រងសំណល់តាម សហគមន៍ និង ក្រោមការគាំទ្រគោលនយោបាយពេញទំហឹង ពីសំណាក់ រដ្ឋអំណាច




បរិមាណសំណល់សរីរាង្គ មានចំនួនច្រើនជាងពាក់កណ្ដាលនៃចំនួនសំណល់សរុប។
កាត់បន្ថយសំណល់សរីរាង្គ ជាអាទិភាពដែលត្រូវធ្វើ។
លើកកម្ពស់ការធ្វើជីកំប៉ុសបែបវិមជ្ឈការ ដោយ

- ញែកសំណល់នៅប្រភព
- ធ្វើជីកំប៉ុសនៅតាមផ្ទះ
- កន្លែងធ្វើជីកំប៉ុសថ្នាក់កណ្ដាល
- លើកកម្ពស់បញ្ចូល ការងាររើសសំណល់អាចកែច្នៃ ទៅជាផ្លូវការ។



## យុទ្ធនាការអប់រំជាសាធារណៈ

- សកម្មភាពពិគ្រោះយោបល់
- យុទ្ធនាការអប់រំការយល់ដឹងពីបរិស្ថាន
- បញ្ចូលការយល់ដឹងពីបរិស្ថាន និងបញ្ហាសំណល់នៅតាមសាលារៀន។

## ជ្រើសរើស អ្នកសម្របសម្រួល និងអ្នកដឹកនាំគ្រូបង្ហាត់ បរិស្ថាន សំរាប់ធ្វើការងារចលនា សហគមន៍

- ពន្យល់សមាសធាតុនៅក្នុងសំណល់
- ពន្យល់ពីការប្រើប្រាស់ធុងធ្វើកំប៉ុស
- យកសំណល់ប្លាស្ទិក ដេរធ្វើកាបូប
- បណ្ដុះបណ្ដាលគ្រូបង្គោលបរិស្ថាន
- គ្រូបង្គោលបរិស្ថានចុះធ្វើសកម្មភាពតាមសហគមន៍
- រៀបចំកម្មវិធីបរិស្ថាន។

## គាំទ្រការចាប់ផ្ដើមកម្មវិធីធ្វើជីកំប៉ុស

- ចែកធុងធ្វើជីកំប៉ុស អ្នកចូលរួម សិក្ខាកាម និងអ្នកស្ម័គចិត្តធ្វើកំប៉ុសតាមផ្ទះ (លើសពី២០០០០ គ្រួសារ)។
- ផ្ដល់ការគាំទ្រ សម្រាប់ការចាប់ផ្ដើម ធ្វើជីកំប៉ុសតាមសហគមន៍:ឧបករណ៍សំអាត ឧបករណ៍ធ្វើជីកំប៉ុស ដី និងតម្លៃវិនិយោគ និងទិញផលិតផលកំប៉ុស សំរាប់ការថែទាំសួនសាធារណៈ។

- បែងចែកកន្លែងធ្វើជីកំប៉ុសក្នុងទីក្រុង (កន្លែងធ្វើជីកំប៉ុស ១៦ កន្លែងធ្វើ កែច្នៃសំណល់សរីរាង្គទីក្រុងបាន ១១០ តោនក្នុងមួយថ្ងៃ។
- លើកកម្ពស់សកម្មភាពកែច្នៃតាមភូមិ បញ្ចូលទៅក្នុងអាជីវកម្មផ្លូវការ ជាមួយផ្នែកឯកជន ។
- ផ្ដល់រង្វាន់ និងពង្រឹងការអនុវត្តន៍ច្បាប់លើកទឹកចិត្តការចូលរួមក្នុងសហគមន៍។
  - រង្វាន់ត្រូវបានផ្ដល់ជូនសហគមន៍ ណាដែលស្ម័គ្រចិត្តចូលរួមក្នុងកម្មវិធីបៃតង និងសំអាត របស់ទីក្រុង Surabaya
  - រង្វាន់ត្រូវបានផ្ដល់ជូនដល់អ្នកមានគំរូល្អក្នុងការងារបរិស្ថាន។
- លើកទឹកចិត្ត ដល់បុគ្គលិក និងអាជ្ញាធរមូលដ្ឋាន តាមរយៈការកសាងសមត្ថភាព និងផ្ដល់នូវរង្វាន់

ថ្នាក់ជាតិ។

## ការសំរេច កាត់បន្ថយការយកសំណល់យកទៅចាក់ចោលនៅទីលាន

- តាមរយៈញែកសំណល់សរីរាង្គ ពីសំណល់ការកែច្នៃ ដទៃទៀត (៧៨% នៃការកាត់បន្ថយសំណល់ពីការកែច្នៃបាន)។
- ៣០% នៃសំណល់យកទៅចាក់ចោលនៅទីលាន ត្រូវបានកាត់បន្ថយជារៀងរាល់៥ឆ្នាំ។
- ការធ្វើកំប៉ុសតាមផ្ទះមានចំនួន ៣% ការធ្វើកំប៉ុសថ្នាក់កណ្តាល ១៥% និង ៧៨% ពង្រឹងលើការកែច្នៃ។
- កាត់បន្ថយការចំណាយលើការគ្រប់គ្រងសំណល់ បាន៣០%។
- គាំទ្រលើកស្ទួយគម្រោង ភាពជាដៃគូ សាធារណៈ និងឯកជន

## បទពិសោធន៍ ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

- ធ្វើកំប៉ុសបែបវិមជ្ឈការ កើតឡើងភាគច្រើនក្នុងដំណាក់ការ ប្រមូលសំណល់បឋម ដែលអាចជួយធ្វើឲ្យការងារ គ្រប់គ្រងសំណល់ទីក្រុងធ្វើបានប្រសើរឡើង ប្រកបដោយអនាម័យ។
- ធ្វើកំប៉ុសបែបវិមជ្ឈការ អាចកាត់បន្ថយការចំណាយលើការដឹកជញ្ជូនសំណល់ អាចពន្យារអាយុកាលទីលានចាក់សំណល់។
- ធ្វើកំប៉ុសបែបវិមជ្ឈការ មិនទាមទារមានការវិនិយោគខ្ពស់។ យកការចំណាយលើការធ្វើកំប៉ុសកណ្តាល ទៅវិនិយោគលើការធ្វើកំប៉ុសបែបវិមជ្ឈការបានច្រើនកន្លែង។
- ធ្វើកំប៉ុសបែបវិមជ្ឈការ ងាយស្រួលធ្វើការសម្រេចផ្លាស់ប្តូរទីតាំង សម្របទៅតាមស្ថានភាពជាក់ស្តែង។
- ធ្វើកំប៉ុសបែបវិមជ្ឈការ បង្កើតឲ្យមានការងារធ្វើ នាំឲ្យមានប្រភពចំណូល ជាពិសេសសម្រាប់ពួករើសអេតចាយ។
- ធ្វើកំប៉ុសបែបវិមជ្ឈការ បង្កឲ្យមានការចូលរួមការគ្រប់គ្រងសំណល់ប្រកបដោយអនាម័យ ធ្វើឲ្យប្រជាពលរដ្ឋមានការយល់ពីបរិស្ថានស្អាតពីសំណល់។

## លក្ខខណ្ឌអនុវត្តធ្វើកំប៉ុសវិមជ្ឈការ

- ការងារលើកកំពស់ការធ្វើកំប៉ុសវិមជ្ឈការ មិនទាមទារឲ្យមានការចំណាយខ្ពស់ ប៉ុន្តែទាមទារឲ្យមានការផ្លាស់ប្តូរគោលនយោបាយ និងអនុសាសន៍គ្រប់គ្រងសំណល់រឹង ការទទួលខុសត្រូវ ទាំងអាជ្ញាធរ ទាំងប្រជាពលរដ្ឋ។
- ធ្វើកំប៉ុសវិមជ្ឈការ ត្រូវបញ្ចូលទៅក្នុងការងារគ្រប់គ្រងសំណល់ មិនត្រូវចាត់ទុកជាគម្រោងដាច់ដោយ



ឡែក។

- ធ្វើកំប៉ុសវិមជ្ឈការទាមទារឲ្យមានការចូលរួម ពីសំណាក់ពាក់ព័ន្ធទាំងអស់ ទាំងស្ថាប័នថ្នាក់ជាតិ សាលាក្រុង អាជ្ញាធរមូលដ្ឋាន អ្នកបង្កើតសំណល់ និងស្ថាប័នឯកជន។
- ការចូលពីសហគមន៍ និងកិច្ចសហប្រតិបត្តិការ អាចធ្វើទៅបាន តាមរយៈការងារអប់រំផ្សព្វផ្សាយ បង្កើតប្រព័ន្ធលើកទឹកចិត្ត និងពង្រឹងការអនុវត្តន៍ច្បាប់។
- សាលាក្រុងគួរសម្បទានដីដល់ការងារធ្វើកំប៉ុសវិមជ្ឈការ ផ្តល់ប្រឹក្សាបច្ចេកទេស និងចូលរួមចំណែកក្នុងការធ្វើវិនិយោគ។
- រៀបចំនិងពង្រឹងការងារទីផ្សារ តាមរយៈបង្កើតឲ្យមានបទដ្ឋានគុណភាព ផ្តល់នូវវិញ្ញាបនបត្រ និងត្រួតពិនិត្យមើលការអនុវត្តន៍ បង្កឲ្យមានទំនាក់ទំនងជាមួយនឹងវិស័យកសិកម្ម និងសាកវប្បកម្ម។

## សក្តានុពលការកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់តាមរយៈធ្វើកំប៉ុសវិមជ្ឈការ

**នៅ Surabaya**

**មូលដ្ឋានសេណារីយ៉ូ**

| | |
|---|---|
| បរិមាណសំណល់សរុប | ១,៤ តោនក្នុងមួយថ្ងៃ |
| សមាសធាតុសំណល់សរីរាង្គ | ៦៥% |
| មេគុណបំបែកការបោះសរីរាង្គ | ០,៥ |
| មេគុណសម្រួលមេតាន | ១ |
| ប្រសិទ្ធភាពកំប៉ុស | ៩៥% |
| គណនាកនុងអំឡុង | ១០ឆ្នាំ |

**ការគណនាការសាយភាយ តាមគោលការណ៍ UNFCCC's AMS-111F សម្រាប់គម្រោងខ្នាតតូច**

ការសាយភាយត្រូវបានកាត់បន្ថយក្នុងរយៈពេល១០ឆ្នាំ បាន ២៩៤៥ **tCO2e** ។ ទទួលបានឥណទានការបោន ២៩៤៥០ អឺរ៉ូ (១០ អឺរ៉ូក្នុងមួយ **tCO2e**)។

កាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់ជាឱកាសទទួលបានឥណទានការបោន

## ហានិភ័យធ្វើកំប៉ុសវិមជ្ឈការ

- យកល្អគួរចងក្រងគម្រោងធ្វើកំប៉ុសវិមជ្ឈការ គ្រាន់ថាវាមានការលំបាកក្នុងការងារគ្រប់គ្រង។ ហានិភ័យអាចទៅលើការកាត់បន្ថយការសាយភាយបានមិនទៅតាមការរំពឹងទុក និងមិនមានការគ្រប់គ្រងត្រឹមត្រូវ។
- ហានិភ័យមួយទៀត ដោយសារ ធ្វើកំប៉ុសវិមជ្ឈការខ្នាតតូចមិនបានគិតពីបច្ចេកទេសដិតដល់ការងារមិនបានដិតដល់។
- ភាពមិនមាននិរន្តរភាពយូរអង្វែងជាហានិភ័យមួយដែរ។ ដូចជា មិនមានការទិញកំប៉ុស មិនមានការគាំទ្រការញែកសំណល់នៅប្រភពបានយូរ ព្រមទាំងការបង់សេវាប្រមូលសំណល់ ធ្វើឲ្យការប្រមូលមានការធ្លាក់ចុះ។
- អាចលែងទទួលបានគាំទ្រពីអាជ្ញាធរ កាលណាមានការផ្លាស់ប្តូរថ្មី។
- តម្រូវឲ្យមានការបង្កើតនូវស្ថាប័ន សម្រាប់ធ្វើការងារនេះ។ វាមានភាពស្មុគស្មាញកាលណាគម្រោងធ្វើកំប៉ុសវិមជ្ឈការកាន់តែច្រើន។ ពេលនោះមិនមានភាពច្បាស់លាស់ថាតើអ្នកខ្លះជាម្ចាស់គម្រោង។



## គម្រោងឡជីវឧស្ម័ន នៅប្រទេស ឥណ្ឌា

**អ្នកអនុវត្តគម្រោង៖ ក្រុមហ៊ុន BIOTECH**

**វាគ្មិន៖ Dr.A. Saji Das នាយកគ្រប់គ្រងគម្រោង ក្រុមហ៊ុន BIOTECH Renewable Energy Pvt.Ltd,**

ដោយសារការកើនឡើងចំនួនប្រជាពលរដ្ឋមានសន្ទុះខ្លាំង សំណល់ដែលគេបង្កើតឡើងក៏មានបរិមាណកើនឡើងជារៀងរាល់ថ្ងៃ។ ការកើនឡើងបរិមាណសំណល់សរីរាង្គ បង្កឲ្យមានបញ្ហាបរិស្ថានច្រើនបែបច្រើនយ៉ាង។ កំណើនប្រជាពលរដ្ឋ មានន័យថា តម្រូវការថាមពលក៏កើនឡើង ជារៀងរាល់ថ្ងៃ។ ដោយសារវិបត្តិសុវត្ថិភាព ការផ្គត់ផ្គង់ថាមពល ទាមទារឲ្យមានការលើកកម្ពស់ឲ្យមានការប្រើប្រាស់ថាមពលកកើតឡើងវិញ។ សំណល់សរីរាង្គជាប្រភពវត្ថុធាតុដើម ដែលអាចកែច្នៃទៅជា ជីវឧស្ម័ន សម្រាប់ប្រើប្រាស់ក្នុងវិស័យផ្គត់ផ្គង់ថាមពល។

## បច្ចេកទេស ឡជីវឧស្ម័ន

បច្ចេកទេសនេះ អាចប្រើប្រាស់បានសម្រាប់កែច្នៃសំណល់សរីរាង្គ។ សំណល់សរីរាង្គ ជាប្រភពមួយដែលនាំឲ្យមានការកើនឡើងកម្តៅបរិយាកាសផែនដី។ បច្ចេកទេសឡជីវឧស្ម័ន ផលិតបានជីវឧស្ម័ន និងកាកដែលវាហៀរចេញ ពីឡជីវឧស្ម័នជាជីកំប៉ុសដែលមានគុណភាពសម្រាប់ដីកសិកម្ម កាត់បន្ថយការទិញ និងប្រើប្រាស់ជីគីមី។ កាត់បន្ថយការទិញ និងប្រើប្រាស់ជីគីមី មានន័យថាកាត់បន្ថយការសាយភាយឧស្ម័ន $CO_2$ ទៅក្នុងបរិយាកាស។

បច្ចេកទេសឡជីវឧស្ម័ន អាចផលិតជីវឥន្ធនៈ តាមរយៈកែច្នៃសំណល់សរីរាង្គ ដែលកើតមាននៅតាម ផ្ទះ ទីផ្សារ ទីសត្តឃាត សណ្ឋាគារ វត្តអារាម ។ល។

ដុតជីវឧស្ម័ន សម្រាប់ដាំស្ល អាចកាត់បន្ថយតម្រូវការ ឥន្ធនៈហ្វូស៊ីល។ កាត់បន្ថយការដុតចម្រាញ់ ឥន្ធនៈហ្វូស៊ីល មានន័យថាកាត់បន្ថយការសាយភាយឧស្ម័ន $CO_2$ ទៅក្នុងបរិយាកាស ។ ដុតជីវឧស្ម័ន សម្រាប់ដាំស្ល មានន័យថា កាត់បន្ថយការកាប់ព្រៃឈើ ធ្វើឧសដុត។

តាមរយៈការដំឡើង ឡជីវឧស្ម័ន តាមគេហដ្ឋាន ឬខ្នាតមធ្យម និងធំ សម្រាប់ធ្វើប្រព្រឹត្តិកម្មសំណល់ជីវៈ ការសាយភាយឧស្ម័នមេតានមួយចំនួនធំ ត្រូវបានគ្រប់គ្រងនិងត្រួតពិនិត្យ។ ដើម្បីសម្រេចទិសដៅនេះ នៅតាមផ្ទះនានា ស្ថាប័នសាធារណៈ និងឯកជន គួរខិតខំប្រឹងប្រែងសាងសង់ឡជីវឧស្ម័ន តាមបែបវិមជ្ឈការ ឲ្យបានច្រើន។

## ប្រៀបធៀបលក្ខណៈពិសេសនៃផលិតជីវឥន្ធនៈទៅនឹងប្រភពថាមពលកកើតឡើងវិញ

វាមានពហុគុណប្រយោជន៍។

- មិនមានកង្វះវត្ថុធាតុដើម ដោយសារសំណល់សរីរាង្គ កើតឡើងរាល់ថ្ងៃ។

- ប្រើប្រាស់ថាមពលកកើតឡើងវិញផ្សេងទៀតគ្រាន់តែជួយរក្សាទុកហ្វូស៊ីលសិន។
- ការទាញយកប្រយោជន៍ពីសំណល់សរីរាង្គ បម្លែងទៅជាជីវឧស្ម័ន វាជាគម្រោងការពារបម្រែបម្រួលអាកាសធាតុ។
- ឥន្ធនៈជីវៈ ជួយការពារអាកាសធាតុដោយចំពោះ តាមរយៈការធ្វើប្រព្រឹត្តិកម្ម ការទុកដាក់សំណល់ដោយអនាម័យ។
- បច្ចេកទេសដ៏សាមញ្ញនេះ វាជួយ ដល់សាធារណៈទូទៅ បានជាផ្នែកមួយនៃប្រព័ន្ធចេជាស្រេច។
- នៅតាមមូលដ្ឋាន ឡជីវឧស្ម័ន ជួយផ្តល់ការងារដល់អ្នករស់នៅទីនោះ ។

### ឡជីវឧស្ម័នតាមផ្ទះ

ឡនេះសម្រាប់ផលិតជីវឧស្ម័ន ពីសំណល់តាមផ្ទះដែលអាចធ្វើការបំបែកតាមបែបជីវបាន។ ជីវឧស្ម័ន ដែលផលិតបានអាចដុតចម្អិនអាហារ និងដុតបំភ្លឺពេលយប់។ អាចជួយសម្រួលការដាំ ស្ល ផាមពលជីទេឡេបាន ៥០ភាគរយ។ ឡជីវឧស្ម័នមួយគ្រប់គ្រងការសាយភាយបាន ៣.៥ តោន នៃឧស្ម័ន CO2។







### ទិន្នន័យឡជីវឧស្ម័នតាមផ្ទះមួយសម្រាប់ប្រព្រឹត្តិកម្មសំណល់សរីរាង្គ

| | |
|---|---|
| អាចប្រព្រឹត្តិកម្មសំណល់បាន | ២គីឡូក្រាម |
| ទំហំឡ | ១០០០លីត្រ |
| សម្រាប់គ្រួសារ | បី ទៅបួន នាក់ |
| ដីសម្រាប់បញ្ចុះឡ | ១,២៥ ម៉ែត្រការ៉េ |
| ជីវឧស្ម័នផលិតបានក្នុងមួយថ្ងៃ | មួយម៉ែត្រគូប |
| កុំប៉ុសរាវ | ២០ លីត្រក្នុងមួយថ្ងៃ |
| មួយម៉ែត្រគូបជីវឧស្ម័នស្មើនឹង | ០,៥ គីឡូក្រាម ឧស្ម័ន LPG |
| ជីវឧស្ម័នផលិតបានក្នុងឆ្នាំ | ៣៦៥ ម៉ែត្រគូប |

ទទួលបានពី កម្មវិធី យន្តការអភិវឌ្ឍន៍ស្អាត បាន ៣,៥ ឥណទានក្នុងមួយឆ្នាំ។

### ផែនការដំណើរការឡ

ប្រមូលសំណល់ជីវៈពីផ្ទះបាយដាក់ចូលក្នុងធុងមួយ។ លាយជាមួយសំណល់រាវបានមកពីលាងអង្ករជាដើម។ចាក់បញ្ចូលទៅក្នុងឡ។ ជីវឧស្ម័នដែលកើតឡើងត្រូវបានទុកដាក់នៅនឹងមួយកន្លែង។ ជីវឧស្ម័នហូរពីកន្លែងស្តុកទៅចង្ក្រានដុតដាំស្លតែម្តង។

### ឡអាចលើកចុះឡើងបាន

BIOTECH បានធ្វើឡដែលអាចលើកចុះឡើងបាន សម្រាប់ប្រើប្រាស់នៅកន្លែងណាដែល មិនអាចសង់ឡក្រោមដីបាន ដោយសារដីវារឹងពេក ឬដោយសារហានិភ័យពីទឹកក្រោមដីខ្ពស់។

### បង្គន់ដែលមានភាពសន្សំសំចៃ

សំណល់ជីវៈ និងលាមកដែលចេញពីបង្គន់ អាចបង្កើតជីវឧស្ម័នសម្រាប់ដុតចម្អិនអាហារ កាលណាសំណល់នេះទទួលបានធ្វើប្រព្រឹត្តិកម្ម ប្រកបដោយអនាម័យ។ សម្រាប់ប្រជាពលរដ្ឋដែលរស់នៅតំបន់មាត់សមុទ្រ តំបន់សំណង់អនាធិបតេយ្យ (marshy area) តំបន់ដែលមានប្រភពទឹកក្រោមដីរាក់ បង្គន់របៀបនេះ មានលក្ខណៈសមស្រប។ បង្គន់នេះមិនតម្រូវឲ្យមានការសាងសង់ល្អស្តុកនៅដាច់ពីគ្នា។

### ឡជីវឧស្ម័នសម្រាប់ប្រព្រឹត្តិកម្ម សំណល់ភក់បង្គន់

ឡនេះសង់នៅតាម សណ្ឋាគារ សាលារៀន វត្តអារាម មន្ទីរពេទ្យ រោងចក្រ។ល។ សំណល់ជីវៈ និងសំណល់ភក់បង្គន់ ត្រូវបានធ្វើប្រព្រឹត្តិកម្ម ដែលមានអនាម័យ និងសេដ្ឋកិច្ច។

### ផលិតភ្លើងអគ្គិសនី ពីសំណល់

សំណល់សរីរាង្គនៅតាមទីផ្សារ នៅទីសត្តឃាត ។ល។ អាចប្រើសម្រាប់ផលិតភ្លើងអគ្គិសនី តាមរយៈការសាងសង់ឡ ធ្វើប្រព្រឹត្តិកម្មសំណល់ខាងលើ ផលិតជីវឧស្ម័ន។ ជីវឧស្ម័នមួយម៉ែត្រគូបអាចផលិតអគ្គិសនីបាន ១,៥ គីឡូវ៉ាត់។ គុណសម្បត្តិ នៃគម្រោង ការទាញយកប្រយោជន៍សំណល់សរីរាង្គបម្លែងទៅជាអគ្គិសនី ដោយសារមិនត្រូវការវត្ថុធាតុដើមផ្សេងទៀតក្រៅពីសំណល់សម្រាប់ផលិតអគ្គិសនី។ អគ្គិសនីនេះអាចដុតបំភ្លឺទីផ្សារ ឬផ្លូវសាធារណៈ។

## សាវតារ ក្រុមហ៊ុន BIOTECH

ចាប់ផ្ដើមដំណើរការនៅឆ្នាំ ១៩៩៤។ សកម្មភាពចម្បងៗមាន៖ ផ្សព្វផ្សាយ អនុវត្តន៍ បណ្ដុះបណ្ដាល ស្រាវនិងអភិវឌ្ឍន៍ ហើយនឹងកសាងធនធានមនុស្ស លើចំណេះដឹងផ្នែកការពារបរិស្ថាន អភិរក្សថាមពល និងផលិតថាមពលកកើតឡើងវិញតាមរយៈការគ្រប់គ្រងប្រកបដោយបទដ្ឋានបរិស្ថាន។

ឡជីវឧស្ម័នជាច្រើនប្រភេទត្រូវបានអភិវឌ្ឍ សម្រាប់ធ្វើប្រព្រឹត្តិកម្មសំណល់ ស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់ និងសំណល់ដែលជាវត្ថុធាតុដើមដែលមាន។

ឡជីវឧស្ម័នជាច្រើនប្រភេទ សម្រាប់ប្រយោជន៍ មន្ទីរពេទ្យ សាលារៀន វត្តអារាម ។ល។ និងសម្រាប់ប្រើប្រាស់តាមមូលដ្ឋាន ដូចជា នៅ Panchayats, សាលាក្រុង សហគមន៍។ **BIOTECH** ទទួលបានជ័យលាភី ថ្នាក់អន្តរជាតិ **Ashden "GREEN OSCAR 2007"** ។

## សេវា BIOTECH

លទ្ធភាពធ្វើកិច្ចសហការ ផ្ទេរបច្ចេកវិទ្យា ពិគ្រោះយោបល់បច្ចេកទេស ពិគ្រោះយោបល់ផ្នែកសេវា អនុវត្តន៍ ធ្វើការសិក្សាពីលក្ខណៈដែលអាចធ្វើបាន សរសេររបាយការណ៍គម្រោង អនុវត្តគម្រោង ជំនួយការផ្នែកបច្ចេកទេសនៅតាមរោងចក្រ និងបើកវគ្គបណ្ដុះបណ្ដាល។

## តើមានមធ្យោបាយអ្វីខ្លះដែលយើងអាចលើកស្ទួយគម្រោង ប្រើប្រាស់ថាមពលកកើតឡើងវិញចូលរួមទប់ស្កាត់បម្រែបម្រួលអាកាសធាតុ

គម្រោងប្រព្រឹត្តិកម្មសំណល់សរីរាង្គ។ យើងមានជំនឿថា អាជ្ញាធរមូលដ្ឋានអាចរៀបគម្រោងនេះបាន។ យើងទាំងអស់តែងតែបានរៀបចំអនាគតឲ្យកូនចៅជំនាន់ក្រោយ តាមរយៈការសាងសង់ផ្ទះសម្បែង អាគារ។ ប៉ុន្តែយើងទាំងអស់គ្នាមិនបានដឹងថាទៅថ្ងៃអនាគតទៅ កូនចៅជំនាន់ក្រោយរស់ស្ថិតនៅក្នុងស្ថានភាពអនាម័យបែបណា។ បរិយាកាសនៅជុំវិញមានភាពអាប់អួ ខ្យល់អាកាសប្រកបដោយការបំពុល។ ទាំងអស់ជាការទទួលខុសត្រូវរបស់ទាំងអស់គ្នានៅក្នុងសម័យនេះ ដើម្បីឲ្យកូនចៅជំនាន់ក្រោយ រស់នៅប្រកបដោយបរិស្ថានស្អាត ខ្យល់អាកាសល្អ។

យើងទាំងអស់គ្នាត្រូវចូលរួម យ៉ាងសកម្មក្នុងការងារការពារ បរិស្ថាន ការពារអាកាសធាតុ ទប់ស្កាត់បម្រែបម្រួល។ ការប្រើប្រាស់បច្ចេកទេសឡជីវឧស្ម័ន ជាគម្រោងមួយប្រសើរ ក្នុងការផលិតជីវថាមពលតាមផ្ទះ និងស្ថាប័នផ្សេងៗដែលមានសំណល់សរីរាង្គ។

យើងយល់ឃើញថា នៅពេលណាដែលនៅគ្រប់ទីកន្លែងទាំងអស់ ដែលអាចសាងសង់ឡជីវឧស្ម័ន នាំគ្នាសាងសង់សម្រាប់ប្រព្រឹត្តិកម្មសំណល់សរីរាង្គ ជាពិសេសតាមបែបវិមជ្ឈការ ជាការចូលរួមចំណែកមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ការឡើងកម្ដៅផែនដី បម្រែបម្រួលអាកាសធាតុ។ សំណល់ដែលសល់ពីឡជាជីជីវៈដែលមានគុណភាពសម្រាប់ដីកសិកម្ម។

សូមឲ្យមានការសហការជាមួយគ្នាបានល្អ។ សូមអរគុណ

អាសយដ្ឋានទំនាក់ទំនង


Dr.A. Saji Das, Managing Director
BIOTECH Renewable Energy Pvt.Ltd, PB.NO.520, M.P.AppanRoad,
Vazhuthacadu,Thycadu.P.O,
Trivandrum.Pin.695 014, KERALA, INDIA, Tel.+91 471 - 2332179, 2321909,
Mob+91 94477 92179, E mail- biotechindia@eth.net
web site www.biotech-india.org

# *បទបង្ហាញស្តីពី* **ការផ្សព្វផ្សាយបច្ចេកវិទ្យាឡជីវឧស្ម័ន**

**Mr. Meng Chanvibol** ***មន្ត្រីបច្ចេកទេស NBP***

## ១. ការណែនាំពី កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិNBP

- NBP គឺជាផ្នែកមួយនៃកម្មវិធីឡជីវឧស្ម័នអាស៊ី (ABP) ទទួលជំនួយពីរដ្ឋាភិបាលប្រទេសហុឡង់តាមរយៈអង្គការ SNV
- NBP គឺជាកម្មវិធីមួយរបស់ក្រសួងបរិស្ថាន និងអង្គការSNV ក្នុងឆ្នាំ២០០៥
- ដំណាក់កាលទី១ ៖ ២០០៦-២០០១២ ដោយមានទិសដៅសាងសង់ឡចំនួន១៨៦០០
- NBP ដំណាក់កាលទី១ទទួលបានជំនួយពី DGIS, SNV, GIZ និង PIN (People in Need) និងថវិកាពីCarbon Emission Reduction Trade
- NBP មានផែនការបន្តដំណាក់កាលទី២ ២០១៣-២០១៦

## ២. ទិសដៅ និងសកម្មភាព

ទិសដៅ: NBP មានទិសដៅបង្កើតនូវវិស័យឡជីវឧស្ម័នប្រកបដោយនិរន្តរភាព និងទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- បង្កើនចំនួនឡឱ្យគ្រួសារធានាគុណភាពចំនួន១៨៦០០ឡ នៅបំណាច់ចុងឆ្នាំ២០១២
- ធានានូវការបន្តប្រើប្រាស់ឡជីវឧស្ម័នសាងសង់ដោយNBP
- ប្រើប្រាស់អោយអស់លទ្ធភាពទាញបានពីឡជីវឧស្ម័ន
- ពង្រឹងសមត្ថភាពរបស់NBP និងក្រុមការងារសាងសង់ឡ PBPO ដើម្បីធានាភាពយូរអង្វែងរបស់កម្មវិធីនេះ
- បង្កើតការវិនិយោគពីវិស័យឯកជនប្រកបដោយសមត្ថភាព និងការជឿជាក់នៅក្នុងការធ្វើទីផ្សារ ការសាងសង់ និងសេវាកម្មផ្តល់ក្រោយពីសាងសង់ឡរួច





## ៣. រចនាសម្ព័ន្ធ NBP

## ៤. ដៃគូរបស់ NBP

## ៥. យុទ្ធសាស្ត្រចំពោះអតិថិជនរបស់NBP

## ៦. តំបន់ប្រតិបត្តិការរបស់ NBP

## ៧. ការណែនាំពីឡ តម្លៃ និងគុណប្រយោជន៍

- រូបភាពខ្សែចង្វាក់ឡជីវឧស្ម័ន
- ដំណាក់កាលសាងសង់
- បរិមាណលាមកចាក់ចូលក្នុងឡ

| ទំហំឡ | លាមកដាក់ដំបូង | លាមកដាក់ប្រចាំថ្ងៃ (គ.ក្រ) | ទឹកដាក់លាយជាមួយលាមក (លីត្រ) | រយៈពេលដាំស្ល (ម៉ោង) | រយៈពេលបំភ្លឺចង្កៀង (ម៉ោង) |
|---|---|---|---|---|---|
| 4 | 1500 | 20-40 | 20-40 | 2-4 | 8-16 |
| 6 | 2300 | 40-60 | 40-60 | 4-6 | 16-24 |
| 8 | 3000 | 60-80 | 60-80 | 6-8 | 24-32 |
| 10 | 3800 | 80-100 | 80-100 | 8-10 | 32-40 |
| 15 | 6000 | 100-150 | 100-150 | 10-15 | 40-60 |

ចង្ក្រានហ្គាស់ដុតដោយប្រើជីវឧស្ម័ន៤០០លីត្រ/ម៉ ចង្កៀងជីវឧស្ម័នអាចបំភ្លឺដោយប្រើជីវឧស្ម័ន ១០០លីត្រ/ម៉ ហើយ១គ.ក្រ លាមកសត្វគោអាចផលិតជីវឧស្ម័នបាន៤០លីត្រ

- តម្លៃឡ

| ការពិពណ៌នា | ៤ ម៉ែត្រគូប | ៦ ម៉ែត្រគូប | ៨ ម៉ែត្រគូប | ១០ ម៉ែត្រគូប | ១៥ ម៉ែត្រគូប |
|---|---|---|---|---|---|
| សម្ភារៈ | 260 | 325 | 383 | 439 | 657 |
| ឧបករណ៍ | 55 | 55 | 55 | 55 | 55 |
| កម្លាំងពលកម្ម | 80 | 90 | 107 | 126 | 168 |
| ថ្លៃធានា | 10 | 15 | 20 | 25 | 35 |
| ថ្លៃបដិភាគ | 15 | 15 | 15 | 15 | 15 |
| តម្លៃសរុប | 420 | 500 | 580 | 660 | 930 |
| សម្បទានពីNBP | 150 | 150 | 150 | 150 | 150 |
| ថវិកាពីកសិករ | 270 | 350 | 430 | 510 | 780 |

- គុណប្រយោជន៍ឡជីវឧស្ម័ន
  - នៅក្នុងគ្រួសារ
    - សន្សំសំចៃការចំណាយទិញអុស និងប្រេងកាតដុត
    - ប្រយោជន៍ចំពោះសុខភាព: កាត់បន្ថយជំងឺទាក់ទងនឹងផ្លូវដង្ហើម
    - ធ្វើអោយបរិស្ថានផ្ទះល្អ (បង្គន់ផ្ទះភ្ជាប់នឹងឡ ចង្ក្រានបាយស្អាត។ល។)
    - សន្សំសំចៃពេលវេលារយៈពេល២ ម៉ោង/ថ្ងៃ
    - បង្កើនគុណភាពដីតាមរយៈការប្រើប្រាស់កាកសំណល់ឡ
    - ការជួយឧបត្ថម្ភពីកម្មវិធី NBP ដល់ម្ចាស់ឡ
  - នៅក្នុងសកល
    - កាត់បន្ថយការបំផាយឧស្ម័នផ្ទះកញ្ចក់ ៤,៥ត $CO_2$/ឡ/ឆ្នាំ
    - ផ្តល់ចំណេះដឹង និងការងារដល់ប្រជាជនក្នុងមូលដ្ឋាន
    - សហគ្រិនសាងសង់ឡខ្នាតតូច
    - ដំរុញការចិញ្ចឹមសត្វពាហនៈបន្ថែម
- ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ

តាមរយៈការធ្វើអង្កេត BUS នៅក្នុងខែសីហា ឆ្នាំ២០១០ បង្ហាញពីផលចំណេញពីការសាងសង់ឡដូចខាងក្រោម:




Workshop on Capacity Building on Accounting and Utilising GHG Emission Reduction Measures for Local Waste Management Actors in Developing Asian Countries , 29-31 August 2011, Hotel Khemara 1 Battambang, Cambodia

- សន្សំសំចៃថាមពលសរុប ១៤,៤$/ខែ/គ្រួសារ
  - អុសដុតចម្អិន ១១$/ខែ/គ្រួសារ (0,0៦$/គ.ក្រ)
  - ប្រេងកាតដុតចង្កៀង ២,១៦$$/ខែ/គ្រួសារ (២,៤លីត្រ/នាទី)
  - ធ្យូង + សាកអាគុយ ១,២៤$$/ខែ/គ្រួសារ
  - ជី ៤,៣៣$/ខែ/គ្រួសារ (៥២$/ឆ្នាំ/គ្រួសារ)
- ការជួយឧបត្ថម្ភពីកម្មវិធី NBP ដល់ម្ចាស់ឡ
  - បដិភាគ ១៥០$/ឡពីកម្មវិធីNBP
  - ឥណទានការប្រាក់ទាបពី MFIs ដូចជា ប្រាសាក់ និងអម្រិត ពី ១៥០$ ដល់១០០០$ រយៈពេលពី ៤-២៤ខែ ក្នុងអត្រាការប្រាក់ ១,២%/ខែ
  - ការត្រួតពិនិត្យគុណភាព: ទាំងពេលកំពុងសាងសង់ និងការធានាគុណភាពក្រោយពេលសាងសង់រយៈពេល ២ឆ្នាំ
  - ការបណ្តុះបណ្តាលមុននិងក្រោយពេលសាងសង់ និងការផ្សព្វផ្សាយពីការប្រើប្រាស់កាកសំណល់ឡជីវឧស្ម័ន

## ៨. ផែនការរបស់ NBP

- ដំណាក់កាលទី២៖ ២០១៣-២០១៦ មានផែនការសាងសង់ឡចំនួន២៦៥០០
- ពង្រីកវិសាលភាពគម្រោងទៅគ្រប់ខេត្ត ដែលមានសក្តានុពល
- ការកសាងពង្រឹងស្ថាប័ន ជាពិសេសក្រុមហ៊ុនសាងសង់ឡ
- ធានាសុវត្ថិភាពផ្នែកហិរញ្ញវត្ថុតាមរយៈការលក់ឥណទានកាបូន


Mr. Meng Chanvibol_Introduction to National Biodigester Programme

## *បទបង្ហាញស្តីពី* ការផ្សព្វផ្សាយ

## បច្ចេកវិទ្យាឡជីវឧស្ម័នខ្នាតគ្រួសារសមស្របនៅក្នុងក្រុង

*លោក ងិន ប៊ុនរិទ្ធ នាយកបច្ចេកទេសអង្គការ* **V2DO**

### ១. បេសកម្មរបស់ V2DO

- V2DO គឺជាអង្គការក្រៅរដ្ឋាភិបាលធ្វើការងារទាក់ទងនឹងការបង្កើនផលិតភាពដំណាំកសិកម្ម ដោយប្រើប្រាស់នូវ EM និងកាកសំណល់ពីឡជីវឧស្ម័ន

### ២. ឡជីវឧស្ម័នសមស្របសម្រាប់គ្រួសារ

- V2DO បាន និងកំពុងសាកល្បងប្រភេទឡជីវឧស្ម័នផ្សេងៗ
- ឡជីវឧស្ម័នខ្នាតតូចមានគុណសម្បត្តិដូចតទៅ
  - អាចប្រើប្រាស់ជាមួយសំណល់ផ្ទះបាយ និងសំណល់សរីរាង្គផ្សេងៗ
  - មិនចាំបាច់ត្រូវមានចិញ្ចឹមជ្រូក ១០ក្បាលឬគោ៥ទេ
  - ត្រូវការនូវបរិមាណលាមកស្រស់មួយចំនួនតែប៉ុណ្ណោះពេលដំបូង
  - បរិមាណហ្គាស់បញ្ចេញមកក្នុង១គ.ក្រ ច្រើនជាងហ្គាស់ចេញពីលាមកគោ
  - ឡមានទំហំតូចល្មម និងសមស្របសម្រាប់ទីក្រុង ទីប្រជុំជន និងជនបទ

### ៣. ប្រភេទឡជីវឧស្ម័នផ្សេងៗកំពុងសាកល្បង

- ម៉ូដែលទី១៖ អាងប្លាស្ទិកជីវឧស្ម័ន
  - ជាប្រភេទអាងថង់ប្លាស្ទិកChongqing Wangliun
  - អាងបញ្ចូល និងបញ្ចេញហ្គាស់បាន
- ម៉ូដែលទី២៖ អាងស៊ីម៉ង់ និងធុងដែក
  - ជាប្រភេទអាងធ្វើឡើងពីអណ្តូងលូកង់ និងដាក់ធុងដែកគ្រប់ពីលើ ដែលអាចរំកិលឡើងចុះបាន
- ម៉ូដែលទី៣៖ អាងប្លាស្ទិករំកិលឡើងចុះបាន
  - ជាប្រភេទអាងធ្វើឡើងពីធុងទឹកប្លាស្ទិកពីរផ្គុំបញ្ចូលគ្នា







- ម៉ូដែលទី៤៖ អាងធ្វើពីធុងទឹកបិទជិត
  - ជាប្រភេទអាងធ្វើឡើងពីធុងទឹកបិទជិត និងរៀបចំអោយមានសំពាធគ្រប់គ្រាន់
- ម៉ូដែលទី៥៖ អាងសិបទិក
  - ជាប្រភេទអាងសិបទិកថ្មៃ និងរៀបចំអោយមានសំពាធគ្រប់គ្រាន់

### ៤. ប្រភេទឧបករណ៍ផ្សេងៗ

- ចង្ក្រានហ្គាស់៖ មានជើង១ និង២
- ម៉ូទ័រសំពាធហ្គាស់ អាចប្រើជាមួយផ្ទាំងកញ្ចក់ទទួលពន្លឺព្រះអាទិត្យ៥W និងបំពង់ចម្រោះហ្គាស់

### ៥. គុណសម្បត្តិ

- សមស្របសម្រាប់ការប្រើប្រាស់ ក្នុងទីប្រជុំជន ទំហំតូចល្មម និងមានតម្លៃសមរម្យ
- មិនចាំបាច់មានចិញ្ចឹមសត្វពាហនៈច្រើន
- សំណល់ដាក់ចូលក្នុងឡអាចជា:
  - សំណល់មានសារធាតុម្សៅ ឬស្ករ(ម្សៅ/គ្រាប់ធញ្ញជាតិ ផ្លែឈើ ឫសខ្មែរ ស្លឹកឈើស្រស់ សំណល់ផ្ទះបាយ
  - ៥គ.ក្រ សំណល់ និងលាយជាមួយទឹក ១០លីត្រ អាចផលិតហ្គាស់មេតានបាន ១០០gr (៥០gr LPG)
  - រយៈពេលសំណល់នៅក្នុងឡខ្លី និងដំណើរការបំបែកសំណល់ក្នុងឡលឿន

### ៦. គុណវិបត្តិ

- ឧស្ម័នមេតានចេញមកពីឡមានកម្តៅខ្ពស់ ប៉ុន្តែកម្រិតកាឡូរីទាប បើប្រៀបនឹងហ្គាស់ធុង (ហ្គាស់ធម្មជាតិមានកម្រិតកាឡូរី ពី៣១-៣៨ MJ/ម៣ ហ្គាស់ធុង ៩៤ MJ/ម៣ ជីវឧស្ម័ន២០-២៥ MJ/ម៣)
- ដោយសម្ពាធហ្គាស់ទាប តម្រូវអោយមានការប្រើប្រាស់ឧបករណ៍បូមហ្គាស់

## ៧. សេចក្តីសន្និដ្ឋាន

- មាននូវជម្រើសផ្សេងៗសម្រាប់តំបន់ទីក្រុង និងជនបទ ដែលមិនមានចិញ្ចឹមសត្វពាហនៈ
- ឡជីវឧស្ម័នមានទំហំតូចល្មម
- មានតម្លៃសមរម្យ កាត់បន្ថយការចំណាយផ្សេងៗ និងទទួលបានជីសម្រាប់បង្កើនគុណភាពដីថែមទៀត
- បច្ចុប្បន្នវាទាមទារអោយមានការស្រាវជ្រាវបន្ថែមទៀត ព្រមជាមួយនឹងការរៀបចំកម្មវិធីផ្សព្វផ្សាយ

អង្គការV2DO

ផ្ទះលេខ ៨១ ផ្លូវ១៣០ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ ភ្នំពេញ

ទូរស័ព្ទ: (៨៥៥-២៣) ២២១ ៧៨៥

ទូរសារ: (៨៥៥-២៣)២២៣ ១១៥

ទូរស័ព្ទដៃ: (៨៥៥-៧៨) ៦៩១ ៦៤៧

អ៊ីមែល: ngin.bunrith@gmail.com







# ប្រព្រឹត្តិកម្មសំណល់បែបជីវៈមេកានិក

## នៅ Phitsanulok

បកស្រាយដោយ **Suthi Hantrakul អភិបាលរងក្រុង Phitsanulok**

### ក្រុង Phitsanulok

- **Phitsanulok** មានផ្ទៃដីទំហំ ១៨,២៦ គីឡូម៉ែត្រក្រឡា
- មាន៣២០០ គ្រួសារ (ផ្ទះ) រស់នៅទីនោះ
- ប្រជាពលរដ្ឋដែលបានចុះបញ្ជីស្នាក់នៅ មានចំនួន ៧៨០០០នាក់
- ប្រជាពលរដ្ឋដែលមិនបានចុះបញ្ជីស្នាក់នៅ មានចំនួន នៅចន្លោះពី ៥០០០០ ទៅ ១០០០០០ នាក់
- ថវិកាប្រចាំឆ្នាំ ១៦,៦ លានដុល្លារសហរដ្ឋអាមេរិក។

### ការគ្រប់គ្រងសំណល់ដោយមិនមានទីលានចាក់សំរាម

**សំណល់បែកចែកជា៖**

- សំណល់ដែលលក់បាន។ ត្រូវបានធ្វើការញែកនៅប្រភព សម្រាប់លក់ទៅឲ្យក្រុមហ៊ុនកែច្នៃ។
- សំណល់អាចធ្វើការបំបែកជីវៈ។ ត្រូវបានធ្វើការញែកនៅប្រភព សម្រាប់យកធ្វើជីកំប៉ុស ឬផលិតជីវៈឧស្ម័ន។
- សំណល់ប្រកបដោយគ្រោះថ្នាក់។ ទុកត្រឹមត្រូវ គ្រប់គ្រងដោយក្រុមហ៊ុនឯកជន។
- សំណល់ចម្លងរោគ យកទៅដុតកម្ទេចចោល។

សំណល់ដែលមិនមានការញែកនៅប្រភព ត្រូវបានយកទៅធ្វើប្រព្រឹត្តិកម្មបែបជីវៈមេកានិក។ ក្រោយពីដំណើរប្រព្រឹត្តិកម្មចប់ សំណល់ទាំងនោះត្រូវបានរែង យកសំណល់ប្លាស្ទិក សម្រាប់ដុតចម្រាញ់យកប្រេង និងសំណល់ដែលនៅសល់ពីនេះ មានលក្ខណៈស្រដៀង កំប៉ុស ដុតយកចំហាយកម្តៅ។

### ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

សំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវបានយកមកទុកដាក់មួយកន្លែងសម្រាប់ប្រមូលនិងដឹកជញ្ជូន យកទៅទុកនៅស្ថានីយស្តុកបណ្តោះអាសន្នមួយកន្លែងសម្រាប់ រៀបចំយកទៅចាក់នៅទីលានសុវត្ថិភាពមួយគ្រប់គ្រងដោយក្រុមហ៊ុនឯកជន។

## ការគ្រប់គ្រងសំណល់ដែលចម្លងមេរោគ

សំណល់ដែលចម្លងមេរោគ ត្រូវបានប្រមូល និងយកទៅដុតកម្ទេចចោល។ ដំបូងសំណល់នេះត្រូវបានបញ្ជូនទៅ ស្ថានីយស្តុកបណ្តោះអាសន្នមួយកន្លែងសម្រាប់ រៀបចំយកទៅដុតកម្ទេចចោល។

## ការធ្វើប្រព្រឹត្តិកម្មសំណល់តាមបែបជីវៈមេកានិក

ជាប្រព្រឹត្តិកម្មដំណើរការដោយមេកានិកផង ជីវៈផង។

- ការធ្វើប្រព្រឹត្តិកម្មដោយមេកានិក មានការរើសយកសំណល់ដែលអាចកែច្នៃបាន ដូចជា ដែក កែវ ក្រដាស សំណល់គ្រឿងសង្ហារិម ។ល។ ការធ្វើប្រព្រឹត្តិកម្មបែបនេះ អាចធ្វើបានដោយដៃ ឬដោយម៉ាស៊ីនស្វ័យប្រវត្តិ។
- ការធ្វើប្រព្រឹត្តិកម្មដោយជីវៈតាមរយៈការសំងួតសំណល់ដោយកម្តៅថ្ងៃ ការបំបែកតាមរយៈអែរូបិក កុំប៉ុស ឬដំណើរការទាំងពីររួមគ្នា។
- ជាប្រព្រឹត្តិកម្មដំណើរការដោយជីវៈមេកានិកផង ធ្វើឡើងតាមបែបមេកានិកមុន បន្ទាប់មក តាមបែបជីវៈ ។

## កន្លែងធ្វើប្រព្រឹត្តិកម្មសំណល់បែបជីវៈមេកានិក។

តម្រូវឲ្យមានរៀបចំជារង សម្រាប់ការគរសំណល់។ រងនិមួយៗមាន ទំហំ បណ្តោយ ២៥ ម៉ែត្រ និង ទទឹង ២,៥ ម៉ែត្រ និងជម្រាល ប្រហែល៣ ភាគរយ ។ បាតក្រោមនៃរងសំណល់មានរាយបំពង់សម្រាប់បញ្ចូលខ្យល់។ សំណល់យកមកធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក ត្រូវច្របល់វា ដោយម៉ាស៊ីនជាមុន។ ក្នុងរយៈពេលដំណើរការ ប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក នេះ មានការជ្រោយរងសំណល់ ដោយប្រើប្រាស់គ្រឿងយន្ត។ បើមានឈើទ្រនាប់ដាក់ឥវ៉ាន់ ដែលគេបោះបង់ចោល អាចយកមកក្រាលពីក្រោមរងសំណល់។ ជាទីបញ្ចប់សំណល់ដែលធ្វើប្រព្រឹត្តិកម្មរួចត្រូវបានយកវាទៅរែង ហើយសមិទ្ធផលដែលទទួលបាន មានស្រដៀងដូចកុំប៉ុស ។ សំណល់ដែលសល់ពីការរែងភាគច្រើនជាសំណល់ប្លាស្ទិក ត្រូវបានយកទៅដុតចម្រាញ់យកប្រេង ដោយម៉ាស៊ីនចម្រាញ់។



Workshop on Capacity Building on Accounting and Utilising GHG Emission Reduction Measures for Local Waste Management Actors in Developing Asian Countries , 29-31 August 2011, Hotel Khemara 1 Battambang, Cambodia

## សេចក្តីសន្និដ្ឋាន

- សំណល់ដែលយកមកធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក ជាសំណល់និចល សម្រាប់ធ្វើប្រព្រឹត្តិកម្មចុងក្រោយ។
- កាត់បន្ថយទឹកសំអុយនៅពេល ធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក តាមរយៈបញ្ចូលខ្យល់ទៅក្នុងរងសំណល់។
- សំណល់ដែល ធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិករួច មានលំនឹង និងថយការសាយភាយឧស្ម័នទីលាន បើសំណល់នោះតម្រូវឲ្យយកទៅចាក់ចោលនៅទីលានចាក់សំណល់។
- អាចទទួលបានឥណទានការបោន ជាប្រភពចំណូល បន្ថែម។
- មិនចាំបាច់តម្រូវឲ្យមាន ការគ្របសំណល់នៅទីលានចាក់សំណល់ជារៀងរាល់ថ្ងៃ។
- ពន្យារអាយុកាលទីលានចាក់សំរាម យ៉ាងតិចបានពីរដង ព្រោះតាមរយៈធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក សំណល់ថយមាឌដល់ទៅ៥០ភាគរយ (ដង់ស៊ីតេសំណល់ ១,៣តោន ក្នុងមួយម៉ែត្រគូប។
- សំណល់បានពីធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិកអាច យកទៅដុតយកចំហាយកំដៅ និងប្លាស្ទិកចម្រាញ់យកប្រេង។

សំណល់មិនមានការញែកចំនួន ១០០ តោន

ក្រោយពីធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក ទទួលបាន

- ៣០ តោន ជាសំណល់ដែលមានចំហេះខ្ពស់
- ៣០ តោនជាសំណល់ដែលមានលក្ខណៈស្រដៀងនឹងកុំប៉ុស

| ចំណាយគិតជាប្រាក់ បាត ក្នុងមួយតោន សំណល់ | ទីលានចាក់សំរាម | ធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក និង ទីលានចាក់សំរាម | ធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក និងដុតចម្រាញ់ | ធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក ដុតចម្រាញ់ និងដុតយកចំហាយកម្តៅ |
|---|---|---|---|---|
| វិនិយោគ | ១០០ | ១០០ | ១០០ | ១០០ |
| ប្រតិបត្តិការ | ៦០០ | ៣០ | ៣០ | ៣០ |
| គ្រប់គ្រងបន្ត | ៤០ | | | |

Dr. Suthi Hantrakul_MBT in Phitsanulok

| | | | | |
|---|---|---|---|---|
| ប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក | | ៣៥០ | ៣៥០ | ៣៥០ |
| ដុតចម្រាញ់ | | | ចំណូល ១៥០ | ចំណូល ១៥០ |
| ដុតយកចំហាយក្តៅ | | | | ចំណូល ១០០ |
| សរុប | ៣៥០ | ៤៨០ | ៣៣០ | ២៣០ |





# ការទាញយកប្រយោជន៍ពីសំណល់សរីរាង្គបម្លែងទៅជាថាមពល នៅប្រទេសឡាវ

*វាគ្មិនៈ សាស្ត្រាចារ្យ **Korakanh Pasomsouk***
*ប្រធាននាយកដ្ឋានវិស្វកម្មគ្រឿងយន្ត, សកលវិទ្យាល័យជាតិឡាវ មហាវិទ្យាល័យវិស្វកម្ម*

## <u>បុព្វហេតុ</u>

- ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន តែងតែជួបប្រទះទៅនឹងបញ្ហាទុកដាក់សំណល់រឹងទីក្រុងដោយសារកង្វះថវិកា និងធនធានមនុស្សនៅមានកម្រិត ។
- ស្របគ្នានឹងការកើនឡើងចំនួនប្រជាពលរដ្ឋ និងភាពរីកចំរើនផ្នែកសេដ្ឋកិច្ចបរិមាណសំណល់រឹងទីក្រុងក៏កើនឡើងជាលំដាប់ដែរ ។
- នៅប្រទេសកំពុងអភិវឌ្ឍន៍គេនិយមចាក់សំណល់ចាក់ចោលនៅទីលានចំហ ឬដុតសំណល់ដោយមិនមានការត្រួតពិនិត្យត្រឹមត្រូវ ។
- នៅក្នុងសំណល់រឹងទីក្រុងសមាសធាតុសំណល់សរីរាង្គរហូតដល់៧៥% ។

- នៅទីលានចាក់សំរាមចំហ សំណល់សរីរាង្គ (សំណល់អាហារ បន្លែ ផ្លែឈើ។ល។) ធ្វើឲ្យសំណល់ដទៃបាត់គុណភាព ។
- សំណល់សរីរាង្គជាប្រភពបង្កើតឲ្យមានឧស្ម័នមេតាន ។
- ផែនដីមានការកើនកម្តៅពីមួយឆ្នាំទៅមួយឆ្នាំ ។
- តាមរយៈសកម្មភាពរបស់មនុស្ស មានឧស្ម័នផ្ទះកញ្ចក់ជាច្រើនសាយភាយទៅក្នុងបរិយាកាស ។
- បម្រែបម្រួលអាកាសធាតុជាបញ្ហាសកល ។
- ការសាយភាយឧស្ម័ន $CO_2$ មួយតោន នៅឡាវ មានន័យថានៅជប៉ុនវងការសាយភាយមួយតោន $CO_2$ ដែរ ។
- បម្រែបម្រួលអាកាសធាតុ មានឥទ្ធិពលអាក្រក់ទៅលើ បរិស្ថានសកល សេដ្ឋកិច្ច និងសង្គមកិច្ច។

- (១) ពន្លឺដែលចាំងមកលើផែនដី (២) ពន្លឺចាំងផ្លាកពីផែនដីចូលទៅក្នុងបរិយាកាសវិញ (៣) ពន្លឺនេះវាស្រូបចូលទៅក្នុងបរិយាកាសផែនដី ។ (៤) មានពន្លឺ Infra-red ភាយចេញពីផែនដី (៥) មានពន្លឺ Infra-red មួយផ្នែកភាយចូលទៅស្រទាប់បរិយាកាសផែនដី និង (៦) ស្រទាប់បរិយាកាសផែនដីមានសាយភាយជាឧស្ម័នផ្ទះកញ្ចក់ ។

➔ លទ្ធផលផែនដីឡើងកម្តៅ។

## ផលវិបាក

- ប៉ះពាល់ដល់សង្គម
- ព្យុះកំណាច ។

## ទិសដៅ

- សិក្សាពីបច្ចេកទេស និងមធ្យោបាយសមស្របសម្រាប់ធ្វើប្រតិបត្តិកម្មសំណល់សរីរាង្គ ចូលរួមទប់ស្កាត់ និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុ ។
- លើកកម្ពស់ការងារអនុវត្តន៍គោលការណ៍កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃ ។
- កំណត់យកបច្ចេកទេសសមស្របសម្រាប់គ្រប់គ្រងសំណល់នៅប្រទេសឡាវ ។

## ព័ត៌មានទូទៅ :

- ឡាវជាប្រទេសកំពុងអភិវឌ្ឍន៍មានប្រជាជន ៥,៥លាននាក់ ។ មានផ្ទៃដី ២៨៧៨០០ គីឡូម៉ែត្រក្រឡា ។
- សេដ្ឋកិច្ចមានការអភិវឌ្ឍន៍សន្សឹមៗ ។
- ជាប្រទេសឧស្សាហកម្មស្ថិតក្នុងដំណាក់ការចាប់ផ្តើម ។
- ទីក្រុងរូបនីយកម្ម ធ្វើឲ្យនៅទីប្រជុំ ជនមានកំណើនប្រជាជនខ្លាំង ។
- ប្រជាជនធ្វើចំណាកស្រុកពីជនបទមកនៅទីក្រុងដើម្បីរកការងារធ្វើ ។
- យុវជនមានបំណងរៀននៅសាកលវិទ្យាល័យជាងធ្វើការ នៅតាមជនបទ។
- សកម្មភាពក្នុងវិស័យទេសចរណ៍ក៏កើនឡើង ។

- រាល់សកម្មភាពខាងលើជាមូលហេតុនៃកំណើនបរិមាណសំណល់ ។
- ឆ្នាំ ២០០៩ នៅប្រទេសឡាវមានសំណល់ ៣៥០ តោន ក្នុងមួយថ្ងៃ ត្រូវបានយកទៅចាក់ចោលនៅទីលានចាក់សំរាម ។
- សំណល់ដែលយកទៅចាក់ចោលនៅទីលានចាក់សំរាមត្រូវចំណាយអស់ ៥,៤ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយតោនសំណល់ ។
- សំណល់សរីរាង្គមាន ៣៥% ។
- ប្រជាជនឡាវរស់នៅភាគច្រើនប្រកបរបរកសិកម្ម ។
- អ្នកទាំងនោះបោះចោលសំណល់ចោលតាមទម្លាប់របស់គេពីមុនមក ។

ទម្លាប់ទាំងនោះមាន៖

- ✔ ដុតសំណល់នៅក្នុងដីចម្ការរបស់គេ ។



- ✔ ចោលសំណល់នៅទីធ្លាជុំវិញកន្លែងដែលគេរស់នៅ ។
- ✔ បោះបង់ចោលក្នុងដីភក់ល្បាប់ តាមដងទន្លេ ។

- សំណល់សរីរាង្គ ២២០ តោនក្នុងមួយថ្ងៃត្រូវបានដឹកទៅចាក់ចោលនៅទីលានចាក់សំរាម
  - ✔ សំណល់អាហារ
  - ✔ សំណល់បន្លែផ្លែឈើ
  - ✔ ស្មៅ ស្លឹកឈើ
  - ✔ ក្រដាស
  - ✔ ឈើ មែក ឈើ ។

- ជាការពិតណាស់ទាំងអស់នេះអាចប្រើវាជាប្រភពធនធានសម្រាប់ផលិតរបស់ផ្សេងៗទៀត។

### សំណល់ជាប្រភពធនធាន
### តែវានៅកន្លែងមួយខុសទិសដៅ

## ការប្រមូល និងដឹកជញ្ជូនសំណល់ :

- នៅវៀងច័ន្ទ បានតែ ៥០%
- នៅទីក្រុង ៤ទៀតបានតែ ៤៧.៥%
- នៅតាមវគ្គ ខេត្ត ១៧ បានតែ ៤៧%
- ក្នុង ១៤១ ទីរួមស្រុកមានតែទីលានចាក់សំរាម ១៤ ជាទីលានមានការត្រួតពិនិត្យ ។

## ប្រភពសំណល់ :

| ប្រភព | បរិមាណ (តោនក្នុងមួយថ្ងៃ) | ភាគរយ |
|---|---|---|
| តាមផ្ទះ | ១៧៥ | ៧៥ |
| តាមផ្លូវ | ២ ក្នុងមួយដងផ្លូវមួយ គ.ម | ១ |
| តាមហាងលក់ទំនិញ | ៣៦ | ១៦ |
| តាមផ្សារ | ៩ | ៤ |
| មន្ទីរពេទ្យ | ២ | ១ |
| សាលារៀននិងការិយាល័យ | ២ | ១ |

## ទូរលេខបង្កើតសំណល់

| កន្លែង | ចំនួនប្រជាជន | សំណល់/ក្នុងម្នាក់/ថ្ងៃ គីឡូក្រាម | សំណល់បញ្ចេញក្នុងមួយថ្ងៃ គិតជាតោន |
|---|---|---|---|
| Vientiane | ៣៣០៧៩៨ | ០,៦៤ | ២១១,៧ |
| Luangprabang | ៧០៤៨១ | ០,៦០ | ៤២,៣ |
| Suvanaket | ៦៥៧២៤ | ០,៦៤ | ៤២ |
| Champasack | ៧២៩៥៥ | ០,៧០ | ៥២ |

## សមាសធាតុសំណល់នៅតាមទីក្រុងសំខាន់ៗ

| សមាសធាតុសំណល់ | Vientian | Luangprabang | Suvanaket | Champasack |
|---|---|---|---|---|
| ប្លាស្ទិក | ១៣ | ៩ | ១៥ | ៦ |
| កែវ | ៦ | ៦ | ២ | ២ |
| ក្រដាស | ៦ | ៨ | ៩ | ៤ |
| ដែក | ៣ | ១ | ១ | ១ |
| សំណល់អាហារ និងបន្លែ | ៣០ | ៥១ | ៥៤ | ៦២ |
| ក្រណាត់ | ២ | ១ | ១ | ១ |
| ឈើ ស្មៅ ស្លឹកឈើ | ១៥ | ២៣ | ១៦ | ២១ |
| ផ្សេងៗទៀត | ១០ | ១ | ១ | ១ |



## សំណល់អាហារ

| ប្រភព | Vientiane គីឡូក្រាមក្នុង១ថ្ងៃ | Luangprabang គក/ថ្ងៃ | Suvanaket គក/ថ្ងៃ | Champasak គក/ថ្ងៃ |
|---|---|---|---|---|
| . សណ្ឋាគារមានភោជនីយដ្ឋាន | ៣៥៥៥ | ១០០៨ | ៥២០ | ៧១៤ |
| . ភោជនីយដ្ឋាន | ៧៦០៥ | ៤៩៩២ | ២៧២០ | ៤១០០ |
| . អាងបាយតូចតាច | ៣៧១៨០ | ១៣១០៤ | ១២២៤០ | ១៣៨០០ |
| . តាមផ្ទះ(សមាជិក ៣-៥នាក់) | ៨១៣២០ | ៥៤០០០ | ៩៨២៥០ | ៦០០០០ |
| សរុប | ១២៩៦៦០ | ៧៣៧០៤ | ១១៣៧៣០ | ៧៨៦១៤ |

### អនុវត្តន៍គោលការណ៍កាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃ កុំអោយសំណល់ដែលមានតម្លៃក្លាយទៅជា សំណល់ដែលលែងមានតម្លៃ ។

គោលការណ៍ ទាំងបីនេះមាន៖

- កាត់បន្ថយ
- ប្រើប្រាស់ឡើងវិញ
- កែច្នៃ

**គោលការណ៍កាត់បន្ថយសំណល់ :**
គោលការណ៍កាត់បន្ថយសំណល់អាចធ្វើទៅបាន ដោយយោងទៅតាមមធ្យោបាយមូលដ្ឋានបី

- កាត់បន្ថយការទិញរបស់របរប្រើប្រាស់លើសសេចក្តីត្រូវការ
- ប្រើរបស់ឲ្យបានអស់ពីសុពលភាព និងគុណភាពរបស់វា
- លប់បំបាត់តម្រូវការផលិតផល ។

ត្រូវធ្វើយ៉ាងណាឲ្យសំណល់របស់អ្នកថ្ងៃនេះ តិចជាងសំណល់ពីម្សិលមិញ និងបរិមាណ សំណល់នៅថ្ងៃស្អែកនឹងតិច ជាងថ្ងៃនេះទៅទៀត

**គោលការណ៍ប្រើប្រាស់ឡើងវិញ**

មានផលិតផលជាច្រើនអាចប្រើប្រាស់ឡើងវិញបាន។ ផលិតផលមួយអាចដើរតួនាទី និងមានប្រយោជន៍ច្រើនយ៉ាង។ សូមប្រើប្រាស់របស់របរឡើងវិញរហូតដល់ប្រើលែងកើត។

**គោលការណ៍កែច្នៃ**

មានសំណល់ជាច្រើនប្រភេទ នៅក្នុងសំណល់រឹងទីក្រុងអាចយកទៅកែច្នៃបាន សម្រាប់បម្រើការជាវត្ថុធាតុដើមនៅក្នុងរោងចក្រ និងប្រើជាបន្ត។

សំណល់ដែលអាចកែច្នៃបានមាន៖ ក្រដាស ដែក អាលុយមីញ៉ូម ប្លាស្ទិក កែវ និងសំណល់ផ្ទះបាយ។

## ការញែកសំណល់រឹង

មុនអនុវត្តន៍គោលការណ៍ទាំងបីខាងលើ សំណល់ត្រូវបានធ្វើការញែកជាមុននៅតាមផ្ទះ។ សំណល់អាចញែកជាបីប្រភេទ

- សំណល់ដែលអាចបំបែកជីវៈបាន
- សំណល់ដែលអាចលក់បាន
- សំណល់ដែលមានជាតិពុល និងប្រកបដោយគ្រោះថ្នាក់។

**សំណល់ដែលអាចបំបែកជីវៈបានមាន៖** សំណល់អាហារ បន្លែ ផ្លែឈើ ស្មៅ ស្លឹកឈើជ្រុះ មែកឈើ កម្ទេចកំទេចឈើ។

**សំណល់លក់បានមាន៖** ប្លាស្ទិក ក្រដាស កែវ (ដប) ដែក សំណល់សណ្ឋាគារ។

**សំណល់ដែលមានជាតិពុល និងប្រកបដោយគ្រោះថ្នាក់មាន៖** ថ្មពិល អំពូលភ្លើង អំពូលណេអុង ថ្មទូរស័ព្ទ ដបថ្នាំពុល និងដបដាក់ជាតិគីមី។ល។

## បម្លែងសំណល់ទៅជាថាមពល

- ក្នុងសំណល់រឹងទីក្រុង ៧៥% ជាសំណល់សរីរាង្គ ដែលអាចបម្លែងវាទៅជាថាមពលដែលមានគុណប្រយោជន៍។
- ដុត (ដំណើរការកម្ដៅ) ចេញបានជា ធ្យូង ជីវៈម៉ាស់។
- ដំណើរការគីមីជីវៈ [តាមបែបអែនអែរូបិក (ផលិតជីវៈឧស្ម័ន) ដំណើរការបំបែកតាម ការបំបែកផលិតអេតាណុល]
- ដំណើរ បំបែកជីវៈ: *Esterification*

### ប្រព្រឹត្តិកម្មសំណល់



## កម្មវិធីឡជីវៈឧស្ម័នសាកល្បង

- នៅប្រទេសឡាវ អង្គការ **SNV** បានឧបត្ថម្ភក្រសួងកសិកម្ម និង រុក្ខាប្រមាញ់ ក្នុងការអនុវត្តន៍គម្រោងឡជីវៈឧស្ម័ន ។
- ទិសដៅរបស់កម្មវិធី គឺដំឡើងឡជីវៈឧស្ម័នឲ្យបាន ៦០០០ ឡក្នុងរយៈពេល៤ឆ្នាំ

ថវិកា គម្រោងនេះមកពីរដ្ឋាភិបាលហុឡង់ដ៍ ។

## ប្រាក់ឧបត្ថម្ភក្នុងការសាងសង់ឡមួយៗ

| ទំហំឡ | ៤ m³ | ៦ m³ | ៨ m³ | ១០ m³ |
|---|---|---|---|---|
| តម្លៃសំណង់ សរុបជា (ឡាវគីប) | ៣៦៥១០០០ | ៤២៣២០០០ | ៤៨៩៤០០០ | ៥៥៨៤០០០ |
| ការចំណាយរបស់ម្ចាស់ឡ (ឡាវគីប) | ១៧៩១០០០ | ២៣៧២០០០ | ៣០៣៤០០០ | ៣៧១៤០០០ |
| ប្រាក់ឧបត្ថម្ភ (ឡាវគីប) | ១៨៦០០០០ | ១៨៦០០០០ | ១៨៦០០០០ | ១៨៦០០០០ |

## ឧស្ម័នដែលចេញពីឡដែលមានទំហំផ្សេងៗគ្នា

| ទំហំឡ | សំណល់លាមកគោផ្តើមដាក់ចូល Kg | ដាក់ចូលប្រចាំថ្ងៃKg | បរិមាណទឹកត្រូវលាយ L | ជីវៈឧស្ម័នm³/ថ្ងៃ |
|---|---|---|---|---|
| ៤ | ១៥០០ | ២០ – ៤០ | ៣,៥ – ៤ | ០,៨ – ១,៦ |
| ៦ | ២៣០០ | ៤០ – ៦០ | ៥,៥ – ៦ | ១,៦ – ២,៤ |
| ៨ | ៣០០០ | ៦០ – ៨០ | ៧,៥ – ៨ | ២,៤ – ៣,២ |
| ១០ | ៣៨០០ | ៨០ – ១០០ | ៩,៥ – ១០ | ៣,២ – ៤,០០ |



អត្ថប្រយោជន៍ជីវៈឧស្ម័ន

- យកដុតសម្រាប់ចម្អិនអាហារ
- ដុតបំភ្លឺជាចង្កៀងហ៊ុំងសុង
- អាចបម្លែងជាអគ្គិសនី ។

**១ ម៉ែត្រគូប ជីវៈឧស្ម័នអាច ជំនួសបាន៖**

- ឧស ៥ គីឡូក្រាម ឬ
- ធ្យូង១,៦ គីឡូក្រាម
- ឥន្ធនៈ ០,៧៥លីត្រ
- LPG ហ្គាស ០,៤៥ គីឡូក្រាម
- នឹងផលិតបានអគ្គីសនី ១,៧ វ៉ាត់ ។

## ជីវៈឧស្ម័នផលិតពីសំណល់ផ្ទះបាយ

- អាចធ្វើពីធុងប្លាស្ទិកមានទំហំ ១៦៨ លីត្រ
- អាចធ្វើពីដែកមានទំហំ ២៦០ លីត្រ

**សំណល់ដែលត្រូវដាក់ក្នុង ធុងខាងលើនៅថ្ងៃដំបូង**

- លាមកគោ៣០គីឡូក្រាម បូកជាមួយទឹក ២០លីត្រ

**បន្ទាប់មកសំណល់ដែលអាចដាក់ចូលក្នុងធុងជីវៈឧស្ម័នបានមាន៖**

១. សំណល់អាហារ ដែលញែកបានស្អាតជាមុន

២. សំណល់បន្លែ និងផ្លែឈើ (បើធំត្រូវកាត់ចិញ្ច្រាំជាមុនសិន)

យកសំណល់នេះលាយច្របល់ចូលគ្នាលាយជាមួយទឹកដាក់ចូលក្នុងធុងជារៀងរាល់ថ្ងៃ ។

## ជីវៈឧស្ម័នដែលផលិតបានពីសំណល់ផ្ទះបាយ

| ទំហំធុង | អាចម៍គោដែលដាក់ថ្ងៃដំបូង (គីឡូក្រាម) | សំណល់អាហារដាក់ប្រចាំថ្ងៃ (គីឡូក្រាម) | ទឹកលាយ គិតជាលីត្រ | ឧស្ម័នផលិតបានម៉ែត្រគីបក្នុង១ថ្ងៃ |
|---|---|---|---|---|
| ០,១៧ | ៥០ | ៨ - ១០ | ០,៤ – ០,៨ | ០,១៥ |
| ០,២៦ | ៨០ | ១០ - ២០ | ១ - ១,៥ | ០,២០ |

## ដុតធ្វើជាធ្យូងសម្រាប់បង្កាត់ភ្លើង

- យកក្រដាស ៤០% និងអាច ន៏រណា ៦០% លាយច្របល់ចូលគ្នា ។
- ស្មៅស្ងួតកម្ទេចធ្យូងអាចប្រើបានដែរ
- យកអង្កាម ៦០% និងក្រដាស ៤០% និងម្សៅដំឡូងមី
- ស្លឹកស្ងួត និងបន្លែស្ងួតអាចធ្វើបានដែរ

ដំឡូងមី ឬស្អុលពោតតម្រូវឲ្យមានការលាយធ្វើយ៉ាងដូចម្តេចឲ្យវានៅដុំដុំ ។

## តើអ្វីខ្លះជាប្រយោជន៍ពីដុំធ្យូងសម្រាប់បង្កាត់ភ្លើង:

- កាត់បន្ថយទិញឧស និង ធ្យូង ។
- ចំណេញពេល និងថវិកា ។
- គោលការណ៍ទាញប្រយោជន៍ពីសំណល់ឲ្យទៅជាថាមពលត្រូវបានអនុវត្តន៍ ។
- កាត់បន្ថយការបំផ្លាញសម្បត្តិធម្មជាតិ ។
- ថយបរិមាណសំណល់ចោលតាមដងផ្លូវ និងទីលានចាក់សំរាម ។
- ចូលរួមទប់ស្កាត់ និងកាត់បន្ថយបម្រែបម្រួលអាកាសធាតុ (ជៀសវាងការបង្កើតការសាយភាយឧស្ម័នផ្ទះកញ្ចក់) ។

## ដំណើរការផលិតដុំធ្យូងបង្កាត់ភ្លើង

- ជំហានទីមួយ : ជ្រើសរើសយកសំណល់ដែលអាចធ្វើដុំធ្យូងនេះបាន (ក្រដាស សំណល់កសិកម្ម ស្មៅ ។ល។)
- ជំហាន ទីពីរ : សំងួតវាដោយហាលនៅក្រោមកម្តៅ ថ្ងៃ ។
- ជំហាន ទីបី : កាត់សំណល់ឲ្យនៅដុំតូចៗ ។
- ជំហាន ទី បួន : លាយសំណល់ទាំងនោះជាមួយម្សៅដំឡូងមី និងទឹក ។
- ជំហាន ទីប្រាំ : លុញវាឲ្យទៅជាស៊ីឡាំង ។
- ជំហាន ទី ប្រាំមួយ : កៀបវាដោយប្រើឧបករណ៍កៀប ។
- ជំហាន ទីប្រាំពីរ : យកហាលមុនយកទៅដុត ។



# សង្ខេបស្តីពីការងារគ្រប់គ្រងសំណល់សរីរាង្គទីក្រុង ចូលរួមទប់ស្កាត់បម្រែបម្រួលអាកាសធាតុ នៅប្រទេសថៃ

សាស្ត្រាចារ្យ បណ្ឌិត **Alice Sharp** នៅ **Sindhorn International Institute of Technology**

## មាតិកា

- ស្ថានភាព និងប្រព័ន្ធគ្រប់គ្រងសំណល់
- គោលនយោបាយថ្នាក់ជាតិ និងទិសដៅការគ្រប់គ្រងសំណល់
- ឧទាហរណ៍លើបទពិសោធន៍ជាក់ស្តែងមួយចំនួន
- កាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់។

## ស្ថានភាពសំណល់

| កន្លែង | បរិមាណសំណល់ (គិតជាតោនក្នុងមួយថ្ងៃ) | | | | |
|---|---|---|---|---|---|
| | ២០០៣ | ២០០៥ | ២០០៦ | ២០០៨ (PDC) | ២០០៩ (PDC) |
| បាងកក | ៩៣៥៦ | ៨២៩១ | ៨៣២៧៩ | ៨៧៨០ | ៨៨៣៤(+0,៦%) |
| ក្រុងបាតាយ៉ា (២០០៧ ការិយាល័យ) | ១២៥០០ | ១២៦៣៥ | ១២៩១២ | ១៤៩១៥ | ១៦៣៦៨(+៩,៦%) |
| ស្រុកចំណុះផ្សេងទៀត ការិយាល័យរដ្ឋបាល (៥៧៧០ ការិយាល័យ) | ១៨១០០ | ១៨២៩៥ | ១៨៩៦៧ | ១៧៣៦៩ | ១៦២០៨ (-៦,៦៨%) |
| សរុប | ៣៩៩៥៦ | ៣៩២២១ | ៣៩៩៨៨ | ៤១០៦៤ | ៤១៤១០ |

## ស្ថានភាពការគ្រប់គ្រងសំណល់

សំណល់ ១០០% ស្មើនឹង ១៥,១៦ មេកាតោន។ សំណល់ដែលអាចប្រមូលបាន មានតែ ៨៥% ស្មើទៅនឹង ១២,៧៣ មេកាតោន។ ក្នុងចំណោម ១២,៧៣ មេកាតោន នេះ

- ៤០% យកទៅចាក់ចោលនៅទីលាន ឬដុតកម្ទេចចោលដែលមានការត្រួតពិនិត្យ និង
- ៦០% យកទៅចាក់ចោល ឬ ដុតមិនតាមបទដ្ឋានបរិស្ថាន។

សក្តានុពលកែច្នៃ មានដល់ទៅ ៨០% នៃសំណល់ ១៥,១៦ មេកាតោន ស្មើទៅនឹង ១២,១៣ មេកាតោន។ ២២% នៃសំណល់ ១២,១៣ មេកាតោន ស្មើទៅនឹង ៣,៣៤ មេកាតោនអាចកែច្នៃបាន។

## សមាសធាតុសំណល់ នៅតំបន់មួយចំនួន

| សមាសធាតុសំណល់ (%នៃសំណល់សើម) | តំបន់មួយចំនួននៅប្រទេសថៃ | | | | | |
|---|---|---|---|---|---|---|
| | ជើង | កណ្តាល | ឦសាន | កើត | ត្បូង | មធ្យម |
| សរីរាង្គ | ៥៩,៧១ | ៦២,៥៦ | ៦៧,៥៣ | ៦៧,៥៣ | ៥៧,៦៥ | ៦១,៤៣ |
| មកពីសួនច្បារ | 0,៩៦ | 0,៦0 | 0,៥១ | 0,៧៧ | 0,២៥ | 0,៦២ |
| កែច្នៃបាន | ២៤,0៦ | ២0,៤៣ | ២0,២១ | ២១,៦១ | ២៦,៧៣ | ២២,៦១ |
| គ្រោះថ្នាក់ | 0,0៥ | 0,៣៤ | 0,១៤ | 0,៣៧ | 0,១៩ | 0,២២ |
| ផ្សេងទៀត | ១៥,២៣ | ១៦,៣៤ | ១១,៦១ | ១៧,៥៧ | ១៥,១៨ | ១៥,១៩ |
| សរុប | ១00 | ១00 | ១00 | ១00 | ១00 | ១00 |
| ដង់ស៊ីតេ (Kg/m$^3$) | ១៧៩,៤៧ | ១៨៥,២៨ | ១៧៦,៨២ | ១៦៧,២៨ | ២0៩,៤0 | ១៨៣,៦៥ |







## សមាសធាតុសំណល់រឹងទីក្រុង

| សំណល់អាហារសរីរាង្គ | ឈើ | ក្រដាស | ប្លាស្ទិក | កែវ | ដែក | ក្រណាត់ | កៅស៊ូស្បែក | ផ្សេងទៀត |
|---|---|---|---|---|---|---|---|---|
| ៦៣,៦% | ៧% | ៨,២% | ១៦,៨% | ៣,៥% | ២,១% | ១,៤% | 0,៥% | ៣,២% |

## ស្ថានភាពការគ្រប់គ្រងសំណល់បច្ចុប្បន្ន

### ទីលានអនាម័យ ៖

៩៤ ទីលានកំពុងដំណើរការ ១0ទីលានបានបិទ ៦ទីលានមិនអាចដំណើរការបាន និង១១ ទីលានកំពុងតែធ្វើផែនការ និងស្ថិតនៅក្នុងការសាងសង់។

### ឡដុតសំណល់កម្ទេចចោល ៖

នៅក្នុងទីក្រុង **Phuket** (ដុត២៥0តោនក្នុងមួយថ្ងៃ) នៅ **Kao Samui** * (ដុត១៤0តោនក្នុងមួយថ្ងៃ) នៅ **LamPhun*** * (ដុត១0តោនក្នុងមួយថ្ងៃ) នៅ **Kao Tao** (ដុត៥តោនក្នុងមួយថ្ងៃ) ។

* បិទសម្រាប់ជួសជុល

** បិទតែម្តង

### ប្រព័ន្ធចម្រុះ ៖

នៅ **Vieng Fang** (១៥0តោនក្នុងមួយថ្ងៃ) នៅ **Rayong** (៨0តោនក្នុងមួយថ្ងៃ) នៅ **Chonburi**** (៤00តោនក្នុងមួយថ្ងៃ) នៅ **Mae Sai** (៦0តោនក្នុងមួយថ្ងៃ)។

**បិទតែម្តង

## ការព្យាករណ៍ បរិមាណសំណល់៖

| ឆ្នាំ | សំណល់កើតឡើង គិតជា តោនក្នុងមួយថ្ងៃ | ឆ្នាំ | សំណល់កើតឡើង គិតជា តោនក្នុងមួយថ្ងៃ | ឆ្នាំ | សំណល់កើតឡើង គិតជា តោនក្នុងមួយថ្ងៃ |
|---|---|---|---|---|---|
| ២០០៨ | ៤០៦៦២,៤២ | ២០១៤ | ៤១៧៩៦,១១ | ២០២០ | ៤២៦៥៤,៦៥ |
| ២០០៩ | ៤០៨៧៨,២៤ | ២០១៥ | ៤១៩៥៤,៣៦ | ២០២១ | ៤២៧៧៩,៥៧ |
| ២០១០ | ៤១០៨១,៧២ | ២០១៦ | ៤២១០៥,៨៧ | ២០២២ | ៤២៩០០,២៦ |
| ២០១១ | ៤១២៧១,២០ | ២០១៧ | ៤២២៥១,២០ | | |
| ២០១២ | ៤១៤៥៦,៨១ | ២០១៨ | ៤២៣៩០,៨២ | | |
| ២០១៣ | ៤១៦៣០,៥០ | ២០១៩ | ៤២៥២៥,១៨ | | |

## កម្មវិធីគោលនយោបាយ

- អនុវត្តន៍គោលការណ៍ កាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងកែច្នៃ ព្រមទាំងការទាញយកប្រយោជន៍ពីសំណល់មកវិញ។
- លើកស្ទួយការងារបញ្ជ្រាបប្រព័ន្ធគ្រប់គ្រងសំណល់ ដើម្បីកាត់បន្ថយការប្រើប្រាស់ទីលានចាក់សំរាម ផលិតថាមពលកកើតឡើងវិញ។
- គាំទ្រលើកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរមូលដ្ឋានដែលនៅភូមិផងរបងជាប់គ្នា រៀបចំអនុសាសន៍ដើម្បីគ្រប់គ្រងសំណល់រួមគ្នា។
- អនុញ្ញាតឲ្យស្ថាប័ន សាធារណៈ ក្រុមហ៊ុនឯកជន ចូលរួមអនុវត្តគម្រោងគ្រប់គ្រងសំណល់។

## គោលនយោបាយទី១ ៖ កាត់បន្ថយសំណល់







- សំណល់ជាទិសដៅថ្នាក់ជាតិ
- កាត់បន្ថយមិនឲ្យតិចជាង ៣០% ( អនុវត្តន៍គោលការណ៍ កាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងកែច្នៃ អនុវត្តតាមបទដ្ឋានបរិស្ថាន)
- ជម្រាបប្រព័ន្ធគ្រប់គ្រងសំណល់ ( យកសំណល់ទៅចាក់ចោលនៅទីលានបទដ្ឋានបច្ចេកទេស មិនឲ្យតិចជាង ៤០%)
- ប្រព័ន្ធគ្រប់គ្រងសំណល់ ប្រកបដោយគ្រោះថ្នាក់ដែលកើតមានឡើងនៅតាមផ្ទះ (យ៉ាងហោចណាស់ឲ្យបាន ៣០%)

## គោលនយោបាយទី២ ៖ បម្លែងសំណល់ ទៅជាថាមពល

- សំណល់ដែលមិនអាចឆេះបាន (មិនមានចំហេះខ្ពស់) យកទៅចាក់ចោលនៅទីលាន
- សំណល់ដែលឆេះបាន (មានចំហេះខ្ពស់)យកទៅដុត។ ផេះដែលចេញពីឡដុត យកទៅចាក់ចោលនៅទីលានចាក់សំរាម។
- សំណល់សរីរាង្គយកទៅផលិតជីវឧស្ម័ន។ កាកដែលចេញពីឡជីវៈឧស្ម័ន យកធ្វើជីកំប៉ុស និងជីវឧស្ម័នដុតបម្លែងទៅជាថាមពលអគ្គិសនី ឬដុតយកកម្ដៅ។ សំណល់សរីរាង្គខ្លះអាចចម្រាញ់ធ្វើជាប្រេង ដុតបម្លែងឲ្យទៅជាភ្លើងអគ្គិសនី។
- សំណល់ដែលអាចកែច្នៃបាន យកទៅកែច្នៃ។
- ទឹកសំអុយដែលចេញពីសំណល់ ត្រូវធ្វើប្រព្រឹត្តិកម្មសំអាតវា។

## គោលនយោបាយទី៣ ៖ ចងក្រងរដ្ឋាភិបាលថ្នាក់មូលដ្ឋានជាចង្កោម

ដោយមានការគាំទ្រពីរដ្ឋាភិបាលថ្នាក់ជាតិ ក្នុងបំណងរៀបចំផែនការគ្រប់គ្រងសំណល់ក្នុងរយៈពេលវែង ប្រកបដោយប្រសិទ្ធភាព។

## លក្ខណៈវិនិច្ឆ័យចងក្រងរដ្ឋាភិបាលថ្នាក់មូលដ្ឋានជាចង្កោម

| ទំហំ | បន្ទុកគ្រប់គ្រងសំណល់ គិតជាតោនក្នុងមួយថ្ងៃ |
|---|---|
| ធំ **L** | ច្រើនជាង ៥០០ តោនក្នុងមួយថ្ងៃ |
| មធ្យម<br>**M1**<br>**M2**<br>**M3** | <br>នៅចន្លោះពី ២៥០ ទៅ ៥០០តោនក្នុងមួយថ្ងៃ<br>នៅចន្លោះពី ១០០ ទៅ ២៥០តោនក្នុងមួយថ្ងៃ<br>នៅចន្លោះពី ៥០ ទៅ ១០០តោនក្នុងមួយថ្ងៃ |
| តូច **S** | តិចជាង ៥០ តោនក្នុងមួយថ្ងៃ |

## បច្ចេកទេសសមស្រប

សម្រាប់ **L** : ញែកសំណល់ + ដំណើរការបំបែកតាមបែបជីវៈ +ឡដុតកម្ទេចសំណល់ +ទីលានចាក់សំរាម

សម្រាប់ **M1** : ញែកសំណល់ + ដំណើរការបំបែកតាមបែបអែនអែរូបិក +ឡដុតយកចំហាយ/ដុតឲ្យទៅជាធ្យូង + ឡដុតកម្ទេចសំណល់ + ទីលានចាក់សំរាម

សម្រាប់ **M2** : ញែកសំណល់ + ដំណើរការបំបែកតាមបែបជីវៈ +ដុតឲ្យទៅ ជាធ្យូង ឬឡដុតយកចំហាយ +ទីលានចាក់សំរាម

សម្រាប់ **M3** : ញែកសំណល់ + ដំណើរការបំបែកតាមបែបជីវៈ + ដុតឲ្យទៅ ជាធ្យូង /ឡដុតយកចំហាយ +ទីលានចាក់សំរាម

សម្រាប់ **S** : ញែកសំណល់ + ដំណើរការបំបែកតាមបែបជីវៈ +ទីលានចាក់សំរាម





Workshop on Capacity Building on Accounting and Utilising GHG Emission Reduction Measures for Local Waste Management Actors in Developing Asian Countries , 29-31 August 2011, Hotel Khemara 1 Battambang, Cambodia

## គោលនយោបាយទី៣ ៖ អភិវឌ្ឍន៍ភាពជាដៃគូ

គម្រោងគ្រប់គ្រងសំណល់ជាច្រើននៅប្រទេសថៃបានធ្វើតាមរយៈតាមរយៈភាពជាដៃគូរវាងអាជ្ញាធរ និងក្រុមហ៊ុនឯកជន។

## ការគ្រប់គ្រងសំណល់ទីក្រុងដែលគេនិយម

សំណល់ទីក្រុងទាំងអស់ដែលប្រមូលបាន យកទៅចាក់ចោលនៅកន្លែងមួយចំហ ឬ ដុតចោលដោយចំហ ឬ ដុតក្នុងឡកម្ទេចចោល ឬ នៅទីលានចាក់សំរាម ។

## បញ្ច្រាប ការគ្រប់គ្រប់គ្រងសំណល់ជាឱកាស

ជាដំបូងអនុវត្តគោលការណ៍ កាត់បន្ថយសំណល់ និងញែកសំណល់នៅប្រភព។ សំណល់ដែលអាចទាញយកប្រយោជន៍បានមកវិញ យកទៅ កែច្នៃ ធ្វើជីកំប៉ុស បម្លែងទៅជាថាមពល និងសម្រាប់សំណល់ដែលលែងមានតម្លៃយកទៅចាក់ចោលនៅទីលានអនាម័យ។

របៀបគ្រប់គ្រងសំណល់ដែលកំពុងនិយម

- គ្រប់គ្រងនៅតាមសហគមន៍
- បម្លែងសំណល់ទៅជាថាមពល
- បញ្ច្រាបការគ្រប់គ្រងសំណល់។

## គ្រប់គ្រងសំណល់តាមសហគមន៍

នៅតាមផ្ទះសំណល់ដែលកើតឡើងអាចមាន ប្រភេទសំណល់ ប្លាស្ទិក ក្រដាសកាសែត កែវ ដប ដបប្លាស្ទិក ដែក កំប៉ុង ជាសំណល់កែច្នៃបាន។ សំណល់នេះអាចញែក សម្រាប់លក់ធ្វើជាប្រភពចំណូល។ សំណល់ដែលអាចធ្វើជីកំប៉ុស បើមានទីតាំងនៅក្រោយផ្ទះ គួរធ្វើជីកំប៉ុសតាមផ្ទះ។

Dr. Alice_Overview of urban organic waste management

សំណល់ត្រូវបានប្រមូលនៅតាមសហគមន៍និមួយៗ ដែលមានការញែកជាស្រេច និងដឹកជញ្ជូនដោយឡែកពីគ្នា។ សំណល់ដែលអាចធ្វើជីកំប៉ុសបាន យក ធ្វើជីកំប៉ុសក្នុងសហគមន៍របស់ខ្លួន។ សំណល់ដែលអាចដាក់ឡជីវឧស្ម័នបាន យកផលិតជីវឧស្ម័នក្នុងសហគមន៍របស់ខ្លួន។ ធ្វើការកែច្នៃសំណល់អេតចាយដទៃទៀតដែលអាចកែច្នៃបាន។ សំណល់ដែលសល់ពីសកម្មភាពខាងលើ និងសំណល់ដែលមិនមានតម្លៃយកទៅចាក់ចោលនៅទីលានចាក់សំរាម។

**សមាសធាតុសំណល់៖** សំណល់សរីរាង្គ មានដល់ទៅ ៦៤% សំណល់ដែលអាចកែច្នៃបាន ៣០% សំណល់ប្រកបដោយគ្រោះថ្នាក់ ៣% និងសំណល់ផ្សេងទៀត ៣%។

## ការគ្រប់គ្រងសំណល់នៅ Phitsanulok

- មានមណ្ឌលធ្វើជីកំប៉ុសសហគមន៍
- ការញែកសំណល់នៅប្រភព

## ស្ថានីយផលិតអគ្គិសនីពីសំណល់ទីក្រុង

### ស្ថានីយបីដែលកំពុងដំណើរការ ៤,០៣៥ មេកាវ៉ាត (MW)

- ឡដុតសំណល់ Phuket ២,៥ មេកាវ៉ាត (MW)
- ឡ ជីវឧស្ម័ន និងប្រព័ន្ធធ្វើជីកំប៉ុស Rayon ៦២៥ គីឡូវ៉ាត (KW)
- ឧស្ម័នទីលាននៅ Racha ៩៥០ គីឡូវ៉ាត (KW)

### ស្ថានីយបីដែលកំពុងសាងសង់ ២,០២ មេកាវ៉ាត (MW)

- ឡនៅ Chunbori ៩៥០ គីឡូវ៉ាត (KW)
- ឡ ជីវឧស្ម័ននៅ Kao Chang ៧០គីឡូវ៉ាត (KW)
- ឧស្ម័នទីលាននៅ Nakhon Pathom ១ មេកាវ៉ាត (MW)







## បញ្ហាប្រការគ្រប់គ្រងសំណល់រឹង

សំណល់១០០% ប្រមូលនិងដឹកជញ្ជូនទៅស្ថានីយញែកសំណល់។

សំណល់ត្រូវបានញែក

- ៥០% ទៅ ៦០% យកធ្វើជីកំប៉ុស។ សល់ពីសកម្មភាពធ្វើជីកំប៉ុសយកទៅចាក់ចោលនៅទីលាន។
- ២០% ទៅ ៣០% សម្រាប់ធ្វើការកែច្នៃ។
- ១០% ទៅ ២០% ជាសំណល់ផ្សេងទៀតសម្រាប់ធ្វើឥន្ធនៈសម្រាប់ដុត បម្លែងទៅជាកម្តៅ ឬអគ្គិសនី។

### ការបញ្ហាប្រការគ្រប់គ្រងសំណល់រឹងនៅ **Nakhon Ratchasima**

សំណល់រឹងទីក្រុង ១៨០ តោនក្នុងមួយថ្ងៃត្រូវបាន ប្រមូលនិងដឹកជញ្ជូនទៅស្ថានីយញែកសំណល់។ ការញែកសំណល់ ធ្វើឡើងតាមបែបមេកានិច ។

ដំណាក់ការដំបូង សំណល់ត្រូវបានចាក់ចូលទៅក្នុងកន្លែងមួយដែល អាចបំបែកថង់ឲ្យសំណល់ធ្លាយចេញពីថង់។ សំណល់ហូរតាមខ្សែពាន ចូលទៅកន្លែងញែកដោយម៉ាស៊ីនមេកានិច មានប្រើមេដែក សម្រាប់ឆក់យកសំណល់ដែកចេញ។ សំណល់សរីរាង្គដែលមានទំហំតូចៗ ទទួលបានពីសកម្មភាពញែក ត្រូវបានបញ្ជូនតាមខ្សែពាន ទៅដាក់នៅឡជីវៈឧស្ម័ន និងសំណល់ដែកដាក់មួយកន្លែង។

សំណល់ដែលនៅសល់ បញ្ជូនបន្តតាមខ្សែពាន ទៅកន្លែងញែកសំណល់ដោយដៃ។ នៅកន្លែងនោះ មានញែកសំណល់សរីរាង្គសារជាថ្មី និង សំណល់កែច្នៃ មានដូចជាប្លាស្ទិក។ សំណល់សរីរាង្គត្រូវបានបញ្ជូនតាមខ្សែពាន ទៅដាក់បញ្ចូលក្នុងឡជីវៈឧស្ម័ន សំណល់ប្លាស្ទិកដាក់នៅមួយកន្លែង។ សំណល់ដែលនៅសល់ពីការញែកដែលមានបរិមាណ ប្រមាណ ៨តោន ក្នុងមួយថ្ងៃ យកទៅដុតយកចំហាយកម្តៅ ឬទាញយកថាមពលកម្តៅ។

សំណល់សរីរាង្គដែលមានការញែកប្រភពជាស្រេច ចំនួន ៥០ តោនក្នុងមួយថ្ងៃត្រូវបានដឹកយកមកដាក់នៅឡជីវៈឧស្ម័ន ។ សំណល់សរីរាង្គទាំងនោះ មុននឹងបញ្ចូលទៅក្នុង ឡជីវៈឧស្ម័ន ត្រូវកៀបយកទឹកចេញជាមុន។ តាមរយៈការកៀបយកទឹកដែលទទួលបានគេយកទៅអាងប្រព្រឹត្តិកម្ម។ បន្ទាប់មកគេសំណល់សរីរាង្គដែលកៀបរួចទៅកូរលាយច្របល់ជាមួយគ្នា និងប្រមូលយកគ្រួស ខ្សាច់ចេញយកទៅចាក់ចោលនៅទីលាន។

សំណល់សរីរាង្គដែលច្របល់គ្នារួច ត្រូវបានបញ្ជូនទៅដាក់ចូលក្នុងឡជីវៈឧស្ម័ន។ ជីវៈឧស្ម័នដែលទទួលបាន ដុតបម្លែងទៅជាអគ្គិសនី និងកាកដែលចេញពីឡ យកធ្វើជីកំប៉ុស តម្រូវឲ្យមានការសំងួតទឹក។

## ការបញ្ជាបការគ្រប់គ្រងសំណល់រឹងនៅទីក្រុង ***Wiang Fang***

សំណល់រឹងទីក្រុង ១៥០ តោនក្នុងមួយថ្ងៃត្រូវបាន ប្រមូលនិងដឹកជញ្ជូនទៅស្ថានីយញែកសំណល់។ នៅទីនោះ ញែកយកសំណល់សរីរាង្គធ្វើជីកំប៉ុស សំណល់កែច្នៃ និងសំណល់ដទៃបង្ហាប់វា មុននឹងដឹកយកទៅចាក់ចោល នៅទីលានចាក់សំរាម។

## ការបញ្ជាបការគ្រប់គ្រងសំណល់រឹងនៅទីក្រុង *Rayon*

សំណល់សរីរាង្គទីក្រុង ៧០ ទៅ ៨០ តោនក្នុងមួយថ្ងៃត្រូវបាន ប្រមូលនិងដឹកជញ្ជូនទៅកន្លែងធ្វើឡជីវៈឧស្ម័ន ។ នៅទីនោះតម្រូវឲ្យមានញែកសំណល់សរីរាង្គ ធ្វើដាក់ចូលឡជីវៈឧស្ម័ន។ ជីវៈឧស្ម័ន ទទួលបានយកទៅបម្រើការជាឥន្ធនៈ សម្រាប់ដំណើរការម៉ាស៊ីនភ្លើង ៦២៥ គីឡូវ៉ាត។





## បញ្ជីសារពើភណ្ឌ ការសាយភាយឧស្ម័ន ផ្ទះកញ្ចក់

| សកម្មភាព | ការសាយភាយចំពោះ | | ការសាយភាយមិនចំពោះ | ជៀសវាងការសាយភាយ | សកម្មភាពកាត់បន្ថយសាយភាយ |
|---|---|---|---|---|---|
| | ការសាយភាយសរុប | ការសាយភាយសុទ្ធ | | | |
| ប្រមូលនិងដឹកជញ្ជូន | $C_2O$ ពីការប្រើប្រែងឥន្ធនៈ | $C_2O$ ពីការប្រើប្រែងឥន្ធនៈ | $C_2O$ ពីយានយន្តអេឡិកទ្រិក និងពីការដឹកជញ្ជូន | | ប្រើយានយន្តអេឡិកទ្រិក ប្រើថាមពលកកើតឡើងវិញ ម្ភរមធ្យោបាយដឹកជញ្ជូន |
| ផ្ទេរ | $C_2O$ ពីការប្រើប្រែងឥន្ធនៈនៅនឹងកន្លែងប្រតិបត្តិការ | $C_2O$ ពីការប្រើប្រែងឥន្ធនៈនៅនឹងកន្លែងប្រតិបត្តិការ | $C_2O$ ពីការប្រើប្រាស់ភ្លើងអគ្គិសនី | | ប្រើម៉ាស៊ីន មធ្យោបាយ ដែលត្រូវប្រែងឥន្ធនៈតិច |
| ប្រព្រឹត្តិកម្មបឋមមេកានិច | $C_2O$ ពីការប្រើប្រែងឥន្ធនៈនៅនឹងកន្លែងប្រតិបត្តិការ | $C_2O$ ពីការប្រើប្រែងឥន្ធនៈនៅនឹងកន្លែងប្រតិបត្តិការ | $C_2O$ ពីការប្រើប្រាស់ភ្លើងអគ្គិសនី | | ប្រើម៉ាស៊ីន មធ្យោបាយ ដែលត្រូវប្រែងឥន្ធនៈតិច |
| ញែក កែច្នៃ និងស្តារយកប្រយោជន៍ | $C_2O$ ពីការប្រើប្រែងឥន្ធនៈនៅនឹងកន្លែងប្រតិបត្តិការ | $C_2O$ ពីការប្រើប្រែងឥន្ធនៈនៅនឹងកន្លែងប្រតិបត្តិការ | $C_2O$ ពីការទិញភ្លើងអគ្គិសនីប្រើប្រាស់ | | ធ្វើឲ្យប្រសើរឡើងអត្រាញែកសំណល់ ទាញយកប្រយោជន៍ពី |

| | | | | | |
|---|---|---|---|---|---|
| | | | | | សំណល់ដែលសល់ពីញែក សម្រាប់កែច្នៃ |
| ប្រព្រឹត្តិកម្មតាមបែប រូប គីមី | $C_2O$ ពីការប្រើប្រេងឥន្ធនៈនៅនឹងកន្លែងប្រតិបត្តិការ | $C_2O$ ពីការប្រើប្រេងឥន្ធនៈនៅនឹងកន្លែងប្រតិបត្តិការ | $C_2O$ ពីការទិញភ្លើងអគ្គិសនីប្រើប្រាស់ | | ធ្វើឲ្យប្រសើរឡើងលើសកម្មភាពផលិតថាមពលកកើតឡើងវិញ |
| ប្រព្រឹត្តិកម្ម ជីវៈ (អែរូបិក និង អែនអែរូបិក) | $C_2O$ ពីពពួកជីវៈម៉ាស<br>$C_2O$ ពីការប្រើប្រេងឥន្ធនៈ<br>$CH_4$ & $N_2O$ | $C_2O$ ពីការប្រើប្រេងឥន្ធនៈនៅនឹងកន្លែងប្រតិបត្តិការ<br>$CH_4$ & $N_2O$ | $C_2O$ ពីការទិញភ្លើងអគ្គិសនីប្រើប្រាស់ | ជៀសវាង $C_2O$ តាមរយៈផលិតថាមពល ប្រើប្រាស់កុំប៉ុស<br>និងការទាញបានមកវិញតាមរយៈផលិតកម្តៅ | ធ្វើឲ្យប្រសើរឡើងលក្ខខណ្ឌអែរូបិកសម្រាប់ដំណើរការធ្វើកុំប៉ុស<br>ធ្វើឲ្យប្រសើរឡើងលក្ខខណ្ឌអែនអែរូបិក ទាញយកប្រយោជន៍ថាមពល |
| ទីលានចាក់សំរាម | $CH_4$ & $C_2O$ ពីឧស្ម័នទីលាន<br>$C_2O$ ពីការប្រើប្រេងឥន្ធនៈ | $CH_4$ & $C_2O$ ពីឧស្ម័នទីលាន<br>$C_2O$ ពីការប្រើប្រេងឥន្ធនៈ | $C_2O$ ពីការទិញភ្លើងអគ្គិសនីប្រើប្រាស់ | ជៀសវាង $C_2O$ តាមរយៈផលិតថាមពល | ធ្វើឲ្យប្រសើរឡើងលក្ខខណ្ឌប្រព្រឹត្តិកម្មអុកស៊ីតកម្ម $CH_4$ ចាប់យកឧស្ម័នទីលាន និងដុតវា |
| ឡដុតសំរាម | $C_2O$ ពីសំណល់<br>$C_2O$ ពីឥន្ធនៈហ្វូស៊ីល | $C_2O$ ពីសំណល់<br>$C_2O$ ពីឥន្ធនៈហ្វូស៊ីល | $C_2O$ ពីការទិញភ្លើងអគ្គិសនីប្រើប្រាស់ | ជៀសវាង $C_2O$ តាមរយៈផលិតថាមពល និងកែច្នៃអាចម៍ដែក និងផេះ | ធ្វើឲ្យប្រសើរឡើងការងារទាញយកប្រយោជន៍ថាមពល |





| | | | | | |
|---|---|---|---|---|---|
| | $N_2O$ | $N_2O$ | | | |
| ប្រព្រឹត្តិកម្មជីវៈមេកានិក | $C_2O$ ពីពពួកជីវៈម៉ាស<br>$C_2O$ ពីការប្រើប្រេងឥន្ធនៈ<br>$CH_4$ & $N_2O$ | $C_2O$ ពីការប្រើប្រេងឥន្ធនៈនៅនឹងកន្លែងប្រតិបត្តិការ<br>$CH_4$ & $N_2O$ | $C_2O$ ពីការទិញភ្លើងអគ្គិសនីប្រើប្រាស់ | ជៀសវាង $C_2O$ តាមរយៈផលិតថាមពល ប្រើប្រាស់កុំប៉ុស ការទាញយកប្រយោជន៍ និងសក្តានុពលផលិតឥន្ធនៈ | ធ្វើឲ្យប្រសើរឡើងការងារលើការងារញែកសំណល់និងគុណភាពកំប៉ុស<br>ធ្វើឲ្យប្រសើរឡើងការងារទាញយកប្រយោជន៍ថាមពល |

## គន្លឹះទទួលបានជោគជ័យ

- ធ្វើការកែច្នៃឲ្យបានដល់កម្រិតអតិបរមា
- គ្រប់គ្រងឲ្យបានល្អ
- បច្ចេកទេសមានប្រសិទ្ធភាព
- បញ្ញត្តិ សមស្រប
- អនុញ្ញាតឲ្យមានការចូលរួមពីស្ថាប័នឯកជន។

## អនុសាសន៍

- មានស្ថានីយញែកសំណល់ច្រើនកន្លែង
- បង្កើនគុណភាពកន្លែងកែច្នៃ

- ស្ថានីយកែច្នៃសំណល់អេឡិកត្រូនិក
- ស្ថានីយកែច្នៃសំណល់ប្រកបដោយគ្រោះថ្នាក់
- កម្មវិធីផ្លាស់ប្ដូរបទពិសោធន៍ការងារគ្រប់គ្រងសំណល់
- បម្លែងសំណល់ទៅជាថាមពល។ មានចំណាប់អារម្មណ៍ ពីសំណាក់អ្នកសិក្សាស្រាវជ្រាវ និងក្រុមវិនិយោគ (ក្នុងស្រុក និងក្រៅស្រុក) លើគម្រោង បម្លែងសំណល់ទៅជាថាមពល និងឥន្ធនៈ។



# ការរៀនសូត្រពីបទពិសោធន៍លើការងារទាញយកប្រយោជន៍ពីសំណល់ទីក្រុង នៅប្រទេសជប៉ុន

វាគ្មិន **Yoshiaki Totoki**
មកពី **Sustainable Consumption and Production, Institute for Global Environment Strategies - IGES**
អ៊ីមែល: **totoki@iges.or.jp**

## ១. គោលបំណង និងមាតិកា

### គោលបំណង

- រៀនសូត្រពីបទពិសោធន៍លើការងារទាញយកប្រយោជន៍ពីសំណល់ទីក្រុងនៅប្រទេសជប៉ុន
- ពិចារណាថាតើនៅកម្ពុជានៅទីក្រុងមានសំណល់អ្វីខ្លះអាច យកធ្វើជាវត្ថុធាតុដើម ឬជាប្រភពថាមពល

### មាតិកា

១. គោលបំណង និងមាតិកានៃបទបង្ហាញ
២. តំបន់ទីប្រជុំជន (ទីក្រុង) និងការទាញយកប្រយោជន៍ឡើងវិញពីសំណល់ជីវម៉ាស
៣. ការបែងចែកសមាសធាតុសំណល់ជីវម៉ាស
៤. ការធ្វើជីកំប៉ុសពីសំណល់សរីរាង្គ
៥. ការផលិតជីវឧស្ម័នពីសំណល់សរីរាង្គ
៦. ការផលិតម៉ាសូតជីវៈពីប្រេងឆាចាស់ៗ
៧. សំណល់ទីក្រុងនៅកម្ពុជា
៨. ការផលិតអគ្គិសនីពីការដុតអង្កាមនៅកម្ពុជា
៩. សរុប និងគន្លឹះនាំឲ្យជោគជ័យ

## ២. តំបន់ទីក្រុង (ទីប្រជុំជន) និងការទាញយកប្រយោជន៍ពីសំណល់ជីវម៉ាស

- ទីក្រុងជាកន្លែងក្បាលម៉ាស៊ីនលើការងារអភិវឌ្ឍន៍ និងជាកន្លែងដែលមានសកម្មភាពសេដ្ឋកិច្ចជាច្រើន ព្រមទាំងជាប្រភពបញ្ចេញសំណល់។
- មានសំណល់ជាច្រើនដែលកើតមានក្នុងទីក្រុងអាចយកធ្វើជាវត្ថុធាតុដើម និងជាប្រភពថាមពល ដែលជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាពក្នុងការងារគ្រប់គ្រងសំណល់ និងកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់។
- ការអនុវត្តន៍ លើការគ្រប់គ្រង សំណល់ជីវម៉ាសនៅជប៉ុន ៖ សហគមន៍មួយដែលមានសកម្មភាពទាញយកប្រយោជន៍ពីសំណល់ជីវម៉ាសក្រោមការសហការយ៉ាងស្អិតរមួត រវាងសហគមន៍ និងអ្នកពាក់ព័ន្ធ។ មាន ៣១៨ ទីក្រុង ដែលបានអនុវត្តន៍ ក្រោមការសហការល្អរវាងសហគមន៍ និងអ្នកពាក់ព័ន្ធ (កក្កដា២០១១)។
- សំណល់ជីវម៉ាស បានរាប់បញ្ចូលទៅក្នុងសំណល់ទីក្រុង។
- សំណល់ជីវម៉ាសអាចរាប់បញ្ចូលទាំងសំណល់កសិកម្ម។

## ៣. សំណល់ទីក្រុងជីវម៉ាស និងប្រភព

<u>**ប្រភេទជីវម៉ាស**</u>

**ជីវម៉ាស ដែលជាសំណល់មាន ៖** លាមកសត្វ សំណល់កសិកម្ម សំណល់ឈើ សំណល់ប្រេងឆា សំណល់សល់ពីសកម្មភាពចិញ្ចឹមត្រី សំណល់សល់ពីសកម្មភាពកែច្នៃឈើ ឈើសល់ពីសំណង់ មែកឈើដែលគេកាត់នៅតាមផ្លូវសាធារណ: សំណល់ក្រដាស សំណល់ភក់ សំណល់ផ្សេងៗទៀត។

**ជីវម៉ាសដែលមិនធ្លាប់បានគិតថាជាសំណល់ជីវម៉ាសមាន៖** ចំបើង និងអង្កាម សំណល់បន្លែដែលមិនហូបបាន កូនឈើល្អិត និងឈើបាក់បែកចោលក្នុងព្រៃ មែកឈើ ឫស្សី និង ផ្សេងៗទៀត។

**ធញ្ញជាតិ ជាប្រភពថាមពល។**

<u>**សំណល់ជីវម៉ាសគេយកទៅប្រើប្រាស់ក្នុងប្រយោជន៍ផ្សេងៗ**</u>

**សំណល់ជីវម៉ាសជាវត្ថុធាតុដើម ៖** សម្រាប់ធ្វើជីកំប៉ុស(ដាក់សម្រាប់កែលំអរដី) យកលាយធ្វើចំណីសត្វ និងធ្វើជីវៈប្លាស្ទិក។

**សំណល់ជីវម៉ាសជាប្រភពថាមពល ៖** មានផលិតជីវៈឧស្ម័ន(ឧស្ម័នមេតាន)ដុតយកកម្តៅ ដុតយកចំហាយកម្តៅ ទាញយកសមាសធាតុកាបូន ឥន្ធនៈរឹង ជីវៈម៉ាស៊ូត ជីវៈអេតាណុល និងផ្សេងទៀត។



## ៤. ករណីធ្វើជីកំប៉ុសពីសំណល់សរីរាង្គ

នៅទីក្រុង Motegic ស្រុក Tochgi (មានប្រជាពលរដ្ឋ ១៦៤០០នាក់ ផ្ទៃដី១៧២គីឡូម៉ែត្រការ៉េ)

**សំណល់ដែលយកធ្វើជីកំប៉ុសមាន**

| | | |
|---|---|---|
| • សំណល់អាចម៍គោ | ៣២២៨ | តោនក្នុងមួយឆ្នាំ |
| • សំណល់ផ្ទះបាយ | ៥០០ | តោនក្នុងមួយឆ្នាំ |
| • ស្លឹកឈើ | ២៥០ | តោនក្នុងមួយឆ្នាំ |
| • អាចម៍រណា(កាត់មែកឈើ) | ២០០ | តោនក្នុងមួយឆ្នាំ |
| • អង្កាម | ២៥០ | តោនក្នុងមួយឆ្នាំ |

**ដំណើរការធ្វើកំប៉ុស**

- ធ្វើការបំបែកបឋមមានរយៈពេល២៥ថ្ងៃ
- ធ្វើការបំបែកលើកទីពីរមានរយៈពេល៦៥ថ្ងៃ
- សំងួតមានរយៈពេល១៥ថ្ងៃ

**ផលដែលទទួលបាន**

- ជីកំប៉ុស "Modoric" ១១១៧ តោនក្នុងមួយឆ្នាំ ។ ១ តោនកុំប៉ុសមានតម្លៃ ៤០០០ យ៉េន។ ១០ គីឡូក្រាមមានតម្លៃ ៥០០យ៉េន។
- ៦០%នៃប្រជាពលរដ្ឋ Motegi ប្រើប្រាស់ផលិតផលនេះ។
- ជីកំប៉ុសទឹក ៨៩៤តោនក្នុងមួយឆ្នាំ។

**ជាគម្រោងសាកល្បងកាត់បន្ថយការសាយភាយឧស្ម័ន $CO_2$ និង $CH_4$**

- សំណល់ ៥០០ តោនក្នុងមួយឆ្នាំជាសំណល់អាហារ
- សំណល់ ២៥០ តោនក្នុងមួយឆ្នាំសំណល់ស្លឹកឈើជ្រុះ

- សំណល់ ២០០ តោនក្នុងមួយឆ្នាំអាចម័រណា
- សំណល់ ២៥០ តោនក្នុងមួយឆ្នាំអង្កាម

**ក្នុងករណីយមិនមានការយកសំណល់ខាងលើទៅដុតកម្ទេចចោល**
**ដូចនេះ អាចកាត់បន្ថយការសាយភាយឧស្ម័នCO2 បាន ៥៨១,៨ [t – $CO_2$/Y]**

សំណល់អាចម៍ មានបរិមាណ ៣២២៨ តោនក្នុងមួយឆ្នាំ

**ក្នុងករណីយមានការទប់ស្កាត់ការសាយភាយបានល្អ នៅពេលដែលយើង**
**បំបែកវាផលិតយកមេតាន បានល្អកាត់បន្ថយបាន $CH_4$=១២១ [t – $CH_4$/Y]**

នៅប្រទេសកំពុងអភិវឌ្ឍ

កាត់បន្ថយការសាយភាយ$CH_4$ ពីទីលានចាក់សំរាមដែលសាយភាយពីសំណល់ផ្ទះបាយ និងមែកឈើ=CH4 កាត់បន្ថយ= ?

## ៥. ករណីផលិតជីវឧស្ម័នពីសំណល់សរីរាង្គ

ទីក្រុង Hita ស្រុក Oita (ប្រជាពលរដ្ឋ ៧២០០ នាក់ ផ្ទៃដី៦៦៦ គីឡូម៉ែត្រការ៉េ (៨២,៨%ជាដីព្រៃឈើ)

១. សំណល់យកទៅដុតកម្ទេចចោលឬចាក់ចោលក្នុងទីលានចាក់សំរាម

២. កើតមានបញ្ហាឡើងកម្តៅ

៣. បញ្ហាបរិស្ថានគឺការចិញ្ចឹមគោ

**សំណល់ដែលផលិតឧស្ម័នមេតានមាន**

- អាចម៍ និងទឹកនោមជ្រូក ២៧ តោនក្នុងមួយថ្ងៃ (៥០តោនក្នុងមួយថ្ងៃ)
- សំណល់ផ្ទះបាយ ២២តោនក្នុងមួយថ្ងៃ(២៤តោនក្នុងមួយថ្ងៃ)
- សំណល់ភក់ ៥ តោនក្នុងមួយថ្ងៃ(៦តោនក្នុងមួយថ្ងៃ)
- សំណល់ពីហាងធ្វើនំ ១៦ តោនក្នុងមួយថ្ងៃ(០ តោនក្នុងមួយថ្ងៃ)

**បច្ចេកទេសឡជីវឧស្ម័នសើម**

- លទ្ធផលឧស្ម័នមេតាន៨០ តោនក្នុងមួយថ្ងៃ ផលិតបានអគ្គិសនី ៣៤០គីឡូវ៉ាត់។

ផែនការផលិតភ្លើងសម្រាប់ប្រើប្រាស់ ៥៦២០គីឡូវ៉ាត់ម៉ោងក្នុងមួយថ្ងៃ។ ដូចនេះ បច្ចេកទេសឡជីវឧស្ម័នសើមខាងលើអាចចូលរួមកាត់បន្ថយការសាយភាយ$CO_2$ បាន

**កាត់បន្ថយការសាយភាយ$CO_2$ =៤៨៧តោនក្នុងមួយឆ្នាំ**

តម្រូវការថាមពលកម្តៅ ក្នុងមួយថ្ងៃ មានទំហំដល់ទៅ ៨,៣០០ **Mcal**

ដូចនេះ បច្ចេកទេសឡជីវឧស្ម័នសើមខាងលើអាចចូលរួមកាត់បន្ថយការសាយភាយ$CO_2$ បាន

**កាត់បន្ថយការសាយភាយCO2 = ៥៦៨ តោនក្នុងមួយឆ្នាំ**

មិនតែប៉ុណ្ណោះ ផលិតបានកុំប៉ុស ៣០០ តោន ដែលមានតំលៃ៥០យ៉េនក្នុង១៥គីឡូក្រាម និង កុំប៉ុសទឹក ២៥០០ តោន។

ក្រោយពេលឲ្យមានការរៀញកសំណល់នៅប្រភព បរិមាណសំណល់ផ្ទះបាយត្រូវបានកាត់បន្ថយពី៩០០តោនទៅ ៦០០តោនក្នុងមួយខែ។

## ៦. ចម្រាញ់ខ្លាញ់ឆាចាស់ៗធ្វើជីវៈម៉ាស៊ូត

នៅក្រុង **Omi** ស្រុក **Shiga** (ប្រជាជន១១៦៧៩៧ នាក់ផ្ទៃដី៣៨៨៥៨គីឡូម៉ែត្រការ៉េ)

**ការប្រមូលប្រេងឆាចាស់ៗ**

- ឆ្នាំ ២០០៥ បាន១៩១២៩លីត្រ
- ឆ្នាំ ២០០៦ បាន២៨៤៧៤លីត្រ
- ឆ្នាំ ២០០៧ បាន២៦៥៧៦លីត្រ
- ឆ្នាំ ២០០៨ បាន៣២៣០០លីត្រ
- ឆ្នាំ ២០០៩ បាន៣១៥៤៣លីត្រ

**លទ្ធផលចេញពីការចម្រាញ់ប្រេងឆាចាស់ ទទួលបាន**

កាត់បន្ថយCO2 =៦៤,៦ តោនក្នុងមួយឆ្នាំ[t - CO2/Y]

## ៧. សំណល់ទីក្រុងនៅកម្ពុជា

***សំណល់ដែលអាចបម្លែងទៅជាថាមពលមានៈ*** *សំណល់ផ្ទះបាយ ប្រេងឆាចាស់ៗ ភក់ សំណល់កសិកម្ម លាមក និងទឹកនោមសត្វ អង្កាម និងចំបើង កាកអំពៅ សំបកដូង ។ល។*

***មធ្យោបាយដែលអាចទាញយកប្រយោជន៍ពីសំណល់ខាងលើមាន***

- *ធ្វើកំប៉ុស*
- *ឡជីវឧស្ម័ន*
- *ឡដុតយកចំហាយ ។ល។*

## ៨. ការដុតយកចំហាយ

*នៅកម្ពុជាបើយកអង្កាមទាំងអស់ដុតអាចជំនួសប្រេងម៉ាស៊ូតបានដល់ទៅ៧៥%សម្រាប់ដំណើរការកិនស្រូវ។ សំណល់អង្កាមមានរហូតដល់៧៤៦៤០តោនក្នុងមួយឆ្នាំអាចកាត់បន្ថយការសាយភាយ* $CO_2$ *បាន២០៨៤៨៨ តោន*$CO_2$ *-eq ក្នុងមួយឆ្នាំ។*

- *ឆ្នាំ ២០០៣ មានគម្រោងសាកល្បងតូចមួយ (មានកម្លាំង៣គីឡូវ៉ាត់)*
- *គម្រោង(បច្ចេកទេសអង្គរផលិត) ផលិតមានកម្លាំង ២០០គីឡូវ៉ាត់។ ម៉ាស៊ីនប្រើអង្កាមជំនួសម៉ាស៊ូត។*
- *ភ្លើង ២០០ គីឡូវ៉ាត់បានដោយការដុតអង្កាមអាចកាត់បន្ថយបានការប្រើប្រាស់ប្រេងម៉ាស៊ូត៧៥% (៥៥០០លីត្រក្នុងមួយខែ)។*
- *ក្រុមហ៊ុន SME បាន ម៉ាស៊ីនដុតអង្កាម បាន ៥៣ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។*
- *៦ គីឡូក្រាមអង្កាមជំនួសបានម៉ាស៊ូត១លីត្រ។*

## ៩. សង្ខេប និងគន្លឹះជោគជ័យ

### សង្ខេប

- *សំណល់ជីវម៉ាសទីក្រុងមួយចំនួនអាចយកមកទាញប្រយោជន៍បានមកវិញតាមរយៈប្រើបច្ចេកទេសដែលមានប្រើប្រាស់រួចៗនៅប្រទេសជាច្រើនគេប្រើបច្ចេកទេសច្រើនក្នុងការទាញយកប្រយោជន៍ពីសំណល់ ជីវម៉ាសក្រុង។*
- *នៅកម្ពុជាមានសក្តានុពលខ្ពស់ក្នុងការយកសំណល់ជីវម៉ាសទៅបម្លែងជាថាមពល សម្រាប់សម្រួលការងារគ្រប់គ្រងសំណល់ និងកាត់បន្ថយការសាយភាយឧស្ម័នផ្ទះកញ្ចក់។*

### គន្លឹះជោគជ័យ

- *អត្ថិភាពចម្បង គឺការគ្រប់គ្រងសំណល់ឲ្យបានត្រឹមត្រូវ។*
- *ការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់។*
- *ប្រើប្រាស់នូវមធ្យោបាយដែលមានស្រាប់ បច្ចេកទេស ធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងសំណល់។*
- *ញែកសំណល់នៅប្រភព និងការប្រមូល សំណល់ប្រកបដោយប្រសិទ្ធភាពជាគន្លឹះជោគជ័យ៕*

# របៀបគណនាការសាយភាយឧស្ម័នផ្ទះកញ្ចក់ពីទីលានចាក់សំរាម និងដំណើរប្រព្រឹត្តិកម្មសំណល់។

*វាគ្មិន លោក* **Baasan Suren Jamsranjav**,

*មកពី* **Intergovernmental Panel on Climate Change, IPCC TFI TSU**

## មាតិកា

- សាវតារ
- គោលការណ៍ណែនាំ IPCC 2006 សម្រាប់ធ្វើបញ្ជីសារពើភណ្ឌសាយភាយឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ ។
- របៀបគណនាការសាយភាយឧស្ម័នផ្ទះកញ្ចក់ពី
  - ✔ សំណល់រឹងដែលយកទៅចាក់ចោលនៅទីលានចាក់សំរាម
  - ✔ ការធ្វើប្រព្រឹត្តកម្មតាមបែបជីវៈលើសំណល់រឹង
  - ✔ ដុតកម្ទេចសំណល់ចោលដោយមានការត្រួតពិនិត្យ និងដុតសំណល់ដោយចំហ ។
- មធ្យោបាយ និងសម្ភារៈមួយចំនួន សម្រាប់ជំនួយក្នុងការងារគណនាការសាយភាយឧស្ម័នផ្ទះកញ្ចក់
- សារុបសេចក្តី

## សាវតារ

- សំណល់ដែលយកទៅចាក់ចោលនៅទីលានចាក់សំរាម និងតាមសកម្មភាពធ្វើប្រព្រឹត្តកម្ម បង្កើតឲ្យមានការសាយភាយឧស្ម័នផ្ទះកញ្ចក់ ។
- ការសាយភាយឧស្ម័នផ្ទះកញ្ចក់ត្រូវបានរំពឹងទុកថា នឹងអាចកើតមានការកើនឡើងនៅប្រទេសកំពុងអភិវឌ្ឍន៍ ។
- បញ្ជីសារពើភណ្ឌសាយភាយ ៖ កត់ត្រាពីលទ្ធផលការគណនាលើការសាយភាយ ការលប់បំបាត់ ទាំងអស់ជាពិសេស ឧស្ម័ន ពីប្រភពដែលកំណត់ក្នុងតំបន់មួយ ក្នុងរយៈពេលមួយ ។



  - ✔ ផ្តល់ព័ត៌មានស្តីពីនិន្នាការសាយភាយ
  - ✔ បង្កើតជាគោលនយោបាយជម្រើសយកមធ្យោបាយសម្រាប់កាត់បន្ថយ ការសាយភាយ
  - ✔ អនុញ្ញាតត្រួតពិនិត្យលើការអនុវត្តន៍គោលនយោបាយ
  - ✔ ជាគន្លឹះធនធានសម្រាប់ធ្វើការសិក្សាស្រាវជ្រាវពីបម្រែបម្រួលអាកាសធាតុ ។
- **IPCC NGGIP** ផ្តល់នូវការទទួលស្គាល់ជាលក្ខណអន្តរជាតិ លើមធ្យោបាយ សម្រាប់ធ្វើបញ្ជីសារពើភណ្ឌលើការសាយភាយ ឧស្ម័នផ្ទះកញ្ចក់ និងការលប់បំបាត់ ។

## គោលការណ៍ណែនាំ IPCC 2006 សម្រាប់ធ្វើបញ្ជីសារពើភណ្ឌសាយភាយថ្នាក់ជាតិ

- បដិវត្តរីកចំរើនមួយ ចាប់ផ្តើមពីគោលការណ៍ណែនាំ IPCC 1996, GPG 2000 និង GPG-LULUCF
- ការធ្វើឲ្យប្រសើរឡើងចំពោះមធ្យោបាយ និងតម្លៃកំណត់ ព័ត៌មានពី (**http://www.IPCC-nggip.iges.or.jp/2006gl/index.html**)
- ការប៉ាន់ស្មានលើការសាយភាយ និងលប់បំបាត់សំដៅលើសកម្មភាព ដូចខាងក្រោមនេះ
  - ✔ ផលិតថាមពល
  - ✔ ដំណើរការក្នុងរោងចក្រ និង ប្រើប្រាស់ផលិតផល **(IPPU)**
  - ✔ វិស័យកសិកម្ម, ព្រៃឈើ និង ការប្រើប្រាស់ដីធ្លី **( AFOU )**
  - ✔ ពីសំណល់ ។

- **គោលការណ៍ណែនាំភាគ ៥ ជាមគ្គុទ្ទេសក៍គណនាការសាយភាយ $CO_2$ $CH_4$ និង $N_2O$ ពីសំណល់**
  - ✔ ពីទីលានចាក់សំរាម
  - ✔ ពីការធ្វើប្រព្រឹត្តកម្មលើសំណល់រឹងតាមបែបជីវៈ
  - ✔ ពីការដុតកម្ទេចសំណល់ដោយមានការត្រួតពិនិត្យ ឬ ដុតដោយចំហ
  - ✔ ពីការប្រព្រឹត្តិកម្មសំណល់ទឹកសំអុយ និងបង្ហូរចេញ។

- ទីលានចាក់សំណល់ជាប្រភពសាយភាយពីសំណល់ធំជាងគេ
- ការសាយភាយ $CO_2$ ពីធម្មជាតិ មិនបានបញ្ចូលក្នុងការគណនាការសាយភាយលើសំណល់
- រាល់ការសាយភាយពីសកម្មភាពបម្លែងសំណល់ទៅជាថាមពល ត្រូវបានគណនានិងធ្វើ របាយការណ៍ក្នុងផ្នែកថាមពល ។

- រូបមន្តដែលពេញនិយម ក្នុងការគណនាការសាយភាយឧស្ម័នផ្ទះកញ្ចក់

**ការសាយភាយ = AD * EF**

**AD:** ទិន្នន័យសកម្ម - ជាទិន្នន័យដែលកើតឡើងពីសកម្មភាពរបស់មនុស្សបង្កើតឲ្យមានការ សាយភាយ ឬ បំបាត់សាយភាយក្នុងពេលមួយ (ឧទាហរណ៍ ហិមាណនៃសំណល់ដែលកំពុងដុត គិតជា **Gg/Yr** គីកាក្រាមក្នុងមួយឆ្នាំ)

**EF:** មេគុណសាយភាយ- ជាមេគុណ លើហិមាណ ការសាយភាយ ឬ ការលប់បំបាត់នៃឧស្ម័ន ក្នុងមួយឯកតានៃសកម្មភាព (ឧទាហរណ៍ **Kg $CH_4$/Gg** នៃសំណល់ដុតដោយចំហ)

- ប្រមូលទិន្នន័យ **AD** និង ប៉ារ៉ាម៉ែត្រ **EF** ជាអនុគមន៍មួយនៃការគណនា**(Integral)** ការសាយភាយ
- ជាការប្រសើរក្នុងការអនុវត្តន៍ការគណនា ការសាយភាយបើធ្វើឡើងទៅលើទិន្នន័យក្នុងប្រទេសណាមួយច្បាស់លាស់
- ទិន្នន័យសំណល់ ជា ចំណោទធំនៅប្រទេសកំពុងអភិវឌ្ឍន៍ (ដូចជាហិមាណសំណល់សរុប, សមាសធាតុដែលមានក្នុងសំណល់ និងការគ្រប់គ្រង ។ល។)
- គោលការណ៍ណែនាំ **IPCC 2006** មានទិន្នន័យកំណត់ ជួយលើកស្ទួយ និងជាមគ្គុទ្ទេសក៏ក្នុងការ ប្រមូលទិន្នន័យ។

- ការសាយភាយឧស្ម័ន **$CH_4$** ពីទីលានចាក់សំរាម
- ឧស្ម័ន $CH_4$ គិតជាតោន T សំណល់ (Gg)

**ការសាយភាយ $CH_4$ = [∑ $CH_4$ ដែលកើតឡើង $_{x,T}$ - $R_T$] * (1- 0$X_T$ )**

**T** តម្លៃបញ្ជីសារពើភណ្ឌតាមឆ្នាំ

**X** ប្រភេទសំណល់

**$R_T$** $CH_4$ ដែលទាញចេញយកបានក្នុងឆ្នាំ **T** គិតជា **Gg**

**$OX_T$** ជាមេគុណអុកស៊ីតកម្មក្នុងឆ្នាំ T



- ការបំបែកសំណល់សរីរាង្គក្រោមលក្ខខ័ណ្ឌអែនអែរូបិក
  - យឺត និងដំណើរការពេញលេញ
  - ប្រែប្រួលតាមលក្ខខ័ណ្ឌ SWDS

- **Mass balance Method** ដែលមាន ក្នុងគោលការណ៍ណែនាំដំបូង សម្រាប់គណនា " សក្តានុពលការសាយភាយ" មានប្រសិទ្ធភាពជាងការគណនាសាយភាយប្រចាំឆ្នាំ។ មានន័យថាការគណនាការសាយភាយ សម្រាប់ក្នុងឆ្នាំបច្ចុប្បន្នដែលគេគណនា មិនគិតពីការសាយភាយ នៅ ឆ្នាំក្រោយៗទៀត ។
- **First order decay (FOD) method** អាចយកមកធ្វើការគណនាកការសាយភាយច្រើនឆ្នាំបន្តបន្ទាប់ អាស្រ័យទៅនឹងពេលវេលា និងការគណនា ការសាយភាយឧស្ម័ន **$CH_4$** ។
- នៅក្នុងគោលការណ៍នៅក្នុង **IPCC** ២០០៦ គេប្រើយក **FOD method** ធ្វើជាមូលដ្ឋានគណនា។ **FOD method** ជាគំរូគោលការណ៍នៅក្នុង **IPCC** ដែលមានការណែនាំ ជាជំហានៗ។ មាននៅក្នុង http: //www.ipcc-nggip.jp/public/zoogIPCC.html
- គំរូតារាង **FoD Model** តម្រូវមានទិន្នន័យស្តីពីប្រវត្តិចាក់សំណល់នៅទីលាន។ ឆ្នាំ ២០០៦ មានគំរូតារាង **FoD Model** នៅក្នុងគោលការណ៍ណែនាំពីការគណនាទិន្នន័យ ប្រវត្តិចាក់សំណល់ដែលយកទៅ ចាក់ចោលនៅទីលាន ។

## គំរូតារាង FoD Model ក្នុងគោលការណ៍ណែនាំ IPCC

មូលដ្ឋានសម្រាប់ការគណនាតម្លៃពពួកសរីរាង្គការបោនដែលអាចធ្វើការបំបែកបាន **(DDOCm)** នៅក្នុងសំណល់ដែលមានសរីរាង្គការបោន ដែលនឹងធ្វើការបំបែកក្រោមលក្ខខណ្ឌអែនអែរូបិកក្នុងសំណល់ដែលត្រូវយកទុកដាក់នៅទីលាន **SWDS** ។

$$DDOC_m = W \bullet DOC \bullet DOC_f \bullet MC_f$$

DDOCm : ម៉ាសនៃសំណល់ដែលយកទៅចាក់នៅលាន អាចបំបែកធាតុសរីរាង្គការបោនបាន គិតជា គីកាក្រាម (Gg)

**W** : ម៉ាសសំណល់ដែលយកទៅចាក់នៅលាន គិតជា គីកាក្រាម (Gg)

**DOC** : បំបែកធាតុសរីរាង្គការបោន នៅ ក្នុងឆ្នាំដែលសំណល់កំពុងធ្វើការបំបែក ជាប្រភាគគិតជា គីកាក្រាម **Gg C/ Gg** នៃសំណល់

**$DOC_f$** : ប្រភាគនៃ ការបំបែកធាតុសរីរាង្គការបោន

**$MC_F$** : ការកែតម្រូវមេគុណ **$CH_4$** សម្រាប់ការបំបែកធាតុតាមបែបអែនអែរូបិកនៅក្នុងឆ្នាំដែល

សំណល់ធ្វើការបំបែក

- អត្ថប្រយោជន៍ជាច្រើនចំពោះដំណាក់កាលទី១ ប៉ុន្តែវាអាចប្រែប្រួលសម្រាប់ដំណាក់ការទាំងមូល ។
- មានជម្រើស ២ សម្រាប់ការគណនាការសាយភាយពីសំណល់រឹងទីក្រុង អាស្រ័យទៅលើទិន្នន័យដែលមាន៖
  - សមាសធាតុសំណល់
  - មាឌរបស់សំណល់
- រក្សាតម្លៃសំណល់បំបែកធាតុសរីរាង្គការបោន ហើយកត់ត្រាបន្ថែមនូវទិន្នន័យសំណល់ដែលចាក់បន្ថែមប្រចាំឆ្នាំ និងបរិមាណឆ្នាំមុន ។
- ការកំណត់ AD កំណត់ប៉ារ៉ាម៉ែត្រ បញ្ចូល តារាង FoD ។

- គ្រប់ការដាក់បញ្ចូលប៉ារ៉ាម៉ែត្រត្រូវបញ្ចូលទៅក្នុងតារាងបញ្ចីពណ៌លឿង។ ក្នុងតារាងផ្សេងទៀតត្រូវបាន គណនាដោយស្វ័យប្រវត្តិ។
- ការជ្រើសរើសតំបន់ណាមួយ ដែលសមរម្យនៅក្នុងតារាងប៉ារ៉ាម៉ែត្រ នឹងមានការកែតម្រូវនៅក្នុង IPCC ។
- អនុញ្ញាតអោយធ្វើការជ្រើសរើសពពួកដែលមានការបំបែកសរីរាង្គការបោន និងអត្រាមេតានដែលប្រព្រឹត្តទៅជាគំរូដោយការ កម្ទេចកាកសំណល់ ឬ ជម្រើសមាឌសំណល់ ។
- អនុញ្ញាតអោយធ្វើការជ្រើសរើសតម្លៃមេគុណ K ដែលបានកំណត់ IPCC សម្រាប់ជ្រើសបរិយាកាសតំបន់ ។
- អនុញ្ញាតអោយកំណត់ពន្យារពេល
  - ពេលសម្រាប់ការធ្វើការបំបែកនៃសំណល់ និង ការចាប់ផ្តើមបញ្ចេញ $CH_4$ ។
- គណនាតម្លៃ $CH_4$ ដែលបានភាយពីសមាសធាតុសំណល់មួយៗទៀត នៅក្នុងតារាងគណនាផ្សេងៗគ្នា។



## ប៉ារ៉ាម៉ែត្រក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍

សូមបញ្ចូលប៉ារ៉ាម៉ែត្រទៅក្នុងតារាងពណ៌លឿង ។ ប្រសិនបើគ្មានទិន្នន័យជាតិត្រូវចំលងនូវតម្លៃកំណត់ដោយ IPCC ។ ប៉ារ៉ាម៉ែត្រនេះអាចរកឃើញក្នុងគោលការណ៍ណែនាំ IPCC នៅឆ្នាំ ២០០៦

| | ប៉ារ៉ាម៉ែត្រ កំណត់ក្នុងIPCC | | ប៉ារ៉ាម៉ែត្រ ជាក់លាក់របស់ប្រទេសមួយៗ | |
|---|---|---|---|---|
| ឆ្នាំដែលចាប់ផ្តើម | 1950 | | 1950 | |
| | | | | |
| **សំណល់អាចបំបែកជីវការបោន** | | | | |
| (ទម្ងន់សមាមាត្រ សមាសធាតុទឹក) | តម្លៃ | តម្លៃកំណត់ | | |
| សំណល់អាហារ | 0.80-0.20 | 0.15 | 0.15 | |
| សំណល់សួនច្បារ | 0.18-0.22 | 0.2 | 0.2 | |
| សំណល់ ក្រដាស | 0.36-0.45 | 0.4 | 0.4 | |
| សំណល់ ឈើ និងស្មៅ | 0.39-0.46 | 0.43 | 0.43 | |
| សំណល់ ក្រណាត់ | 0.20-0.40 | 0.24 | 0.24 | |
| សំណល់ទ្រនាប់ខោកូនក្មេងដែលអាចចោលបាន | 0.18-0.32 | 0.24 | 0.24 | |
| សំណល់ ភក់ | 0.4-0.5 | 0.5 | 0.5 | |
| សំណល់ រោងចក្រ | 0-0.54 | 0.15 | 0.15 | |
| DOCf | | 0.5 | 0.5 | |
| K | សីតុណ្ហភាព នៅសើម | | | |
| ឆ្នាំទី១ | Range | Default | | |
| សំណល់អាហារ | 0.1-0.2 | 0.185 | 0.185 | |
| សំណល់សួនច្បារ | 0.06-0.1 | 0.1 | 0.1 | |
| P សំណល់ ក្រដាស | 0.05-0.07 | 0.06 | 0.06 | |
| សំណល់ ឈើ និងស្មៅ ចំបើង | 0.02-0.04 | 0.03 | 0.03 | |
| សំណល់ ក្រណាត់ | 0.05-0.07 | 0.06 | 0.06 | |
| សំណល់ទ្រនាប់ខោកូនក្មេងដែលអាចចោលបាន | 0.06-0.1 | 0.1 | 0.1 | |
| សំណល់ រោងចក្រ | 0.1-0.2 | 0.185 | 0.185 | |
| Industrial waste | 0.08-0.1 | 0.09 | 0.09 | |
| Delay time (month) | | 6 | 6 | |

## Methane calculation from: Food waste

| | | National values |
|---|---|---|
| DOC | DOC | 0.15 |
| DOCf | DOCf | 0.500 |
| Methane generation rate constant | k | 0.185 |
| Half-life time ($t_{1/2}$, years): | h = ln(2)/k | 3.7 |
| exp1 | exp(-k) | 0.83 |
| Process start in deposition year. Month M | M | 13.00 |
| exp2 | exp(-k*((13-M)/12)) | 1.00 |
| Fraction to CH4 | F | 0.500 |

| Year | Amount deposited | MCF | Decomposable DOC (DDOCm) deposited | DDOCm not reacted. Deposition year | DDOCm decomposed. Deposition year | DDOCm accumulated in SWDS end of year | DDOCm decomposed | $CH_4$ generated |
|---|---|---|---|---|---|---|---|---|
| | W | MCF | D = W * DOC * DOCf * MCF | B = D * exp2 | C = D * (1- exp2) | H = B + ($H_{last\ year}$ * exp1) | E = C + $H_{last\ year}$ * (1 - exp1) | Q = E * 16/12 * F |
| | Gg | fraction | Gg | Gg | Gg | Gg | Gg | Gg |
| | | | | | | | | |
| 1950 | 693 | 0.71 | 37 | 37 | 0 | 37 | 0 | 0 |
| 1951 | 693 | 0.71 | 37 | 37 | 0 | 67 | 6 | 4 |
| 1952 | 693 | 0.71 | 37 | 37 | 0 | 92 | 11 | 8 |
| 1953 | 693 | 0.71 | 37 | 37 | 0 | 113 | 16 | 10 |
| 1954 | 693 | 0.71 | 37 | 37 | 0 | 131 | 19 | 13 |
| 1955 | 693 | 0.71 | 37 | 37 | 0 | 145 | 22 | 15 |
| 1956 | 693 | 0.71 | 37 | 37 | 0 | 158 | 25 | 16 |
| 1957 | 693 | 0.71 | 37 | 37 | 0 | 168 | 27 | 18 |
| 1958 | 693 | 0.71 | 37 | 37 | 0 | 176 | 28 | 19 |
| 1959 | 693 | 0.71 | 37 | 37 | 0 | 183 | 30 | 20 |
| 1960 | 693 | 0.71 | 37 | 37 | 0 | 189 | 31 | 21 |
| 1961 | 693 | 0.71 | 37 | 37 | 0 | 193 | 32 | 21 |
| 1962 | 693 | 0.71 | 37 | 37 | 0 | 197 | 33 | 22 |
| 1963 | 693 | 0.71 | 37 | 37 | 0 | 201 | 33 | 22 |
| 1964 | 693 | 0.71 | 37 | 37 | 0 | 203 | 34 | 23 |
| 1965 | 693 | 0.71 | 37 | 37 | 0 | 206 | 34 | 23 |
| 1966 | 693 | 0.71 | 37 | 37 | 0 | 208 | 35 | 23 |
| 1967 | 693 | 0.71 | 37 | 37 | 0 | 209 | 35 | 23 |
| 1968 | 693 | 0.71 | 37 | 37 | 0 | 210 | 35 | 24 |
| 1969 | 693 | 0.71 | 37 | 37 | 0 | 212 | 36 | 24 |
| 1970 | 693 | 0.71 | 37 | 37 | 0 | 212 | 36 | 24 |

## ការធ្វើប្រព្រឹត្តកម្មកាកសំណល់ជីវៈសរីរាង្គ : ការធ្វើជីកំប៉ុស



- ដំណើរការអែរូបិក និងប្រភាគនៃ **DOC** នៅក្នុងសំណល់ត្រូវបានបម្លែងទៅជា $CO_2$
  - ✔ បន្ថយមាឌសំណល់ មានលំនឹង
  - ✔ កន្លែងផ្ទុកកាបូនខ្លះមាននៅក្នុងកុំប៉ុស
  - ✔ ផ្អែកទៅលើគុណភាពរបស់វា   ជីកុំប៉ុសអាចយកទៅធ្វើជាជីសម្រាប់ជំនួយដល់ដី   និងកែទម្រង់ដី( បង្កើតនូវរូបធាតុសរីរាង្គ និងរក្សានូវជាតិទឹកបានខ្ពស់ ។ល។)

- **$CH_4$** និង **$N_2O$** អាចជួយដល់ដំណើរការអំពុក ។
  - ✔ **$CH_4$** អាចជួយដល់ដំណើរការអែនអែរូបិកមួយផ្នែកនៃជីកុំប៉ុស
  - ✔ ការធ្វើជីកុំប៉ុសមិនត្រឹមត្រូវ ប្រៀបដូចជាបង្កើនឡើងវិញនូវ **$CH_4$** និង **$N_2O$** ។

## ការធ្វើប្រព្រឹត្តិកម្មកាកសំណល់ជីវៈរឹង បែបអែនអែរូបិក

- ការបំបែកធាតុសម្ភារៈសរីរាង្គធម្មជាតិក្រោមអវត្តមានអុកស៊ីហ្សែន ។
- ផលិតជីវៈឧស្ម័ន ( **$CH_4$ + $CO_2$** ) និង សំណល់ពីឡូ ។
  - ✔ ផលិត ផល $CH_4$ អាចបង្កើតជាថាមពលកម្ដៅ ឬ ក៏ថាមពលអគ្គិសនី
  - ✔ សំណល់ពីឡូ អាចធ្វើជាជី ឬប្រើសម្រាប់កែលំអ គុណភាពដី
- ការសាយភាយ **$N_2O$** ពីដំណើរការត្រូវបានអះអាងថាស្ដួចស្ដើង ។

## ការធ្វើប្រព្រឹត្តិកម្មនៃកាកសំណល់ជីវៈរឹង : ការសាយភាយ $CH_4$

- វិធីគណនាការសាយភាយនៃ **$CH_4$**

$$CH_4 \text{ សាយភាយ} = \Sigma_i ( M_i \cdot EF_i ) \cdot 10^{-3} - R$$

$CH_4$ Emissions : ការសាយភាយ $CH_4$ សរុបនៅក្នុងបញ្ជីសារពើភណ្ឌប្រចាំឆ្នាំ គិតជា $GgCH_4$

$M_i$ : ម៉ាសនៃសំណល់សរីរាង្គដែលធ្វើប្រព្រឹត្តកម្មដោយ តាមបែបជីវៈ **i, Gg**

$EF_i$ : កត្តាសាយភាយពីការធ្វើប្រព្រឹត្តិកម្ម **i, g $CH_4$/Kg**

I : ការអំពុក ឬ ការបំបែកបែបអែនអែរូបិក

R: តម្លៃ $CH_4$ សរុបដែលបានមកពីបញ្ជីសារពើភណ្ឌប្រចាំឆ្នាំ Gg $CH_4$ ។ប្រសិនបើឧស្ម័នបានមកពីការឆេះ, ការសាយភាយត្រូវកត់ចូលទៅក្នុងផ្នែកសំណល់ ។

## ការធ្វើប្រព្រឹត្តិកម្ម ជីវៈកាកសំណល់រឹង : ការសាយភាយឧស្ម័ន $NO_2$

- **វិធីគណនារូបមន្តសាយភាយ** $N_2O$

$$N2O\ សាយភាយ = \Sigma i\ (Mi \cdot Efi) \cdot 10\text{-}3$$

**$N_2O$** សាយភាយ : ការសាយភាយឧស្ម័ន **$N_2O$** សរុបនៅក្នុងបញ្ជីសារពើភណ្ឌប្រចាំឆ្នាំ **Gg, $N_2O$**

**$M_i$** :ម៉ាសនៃសំណល់សរីរាង្គ ដែលបានប្រព្រឹត្តការធ្វើប្រព្រឹត្តិកម្មបែបជីវៈ **i ,Gg**

**$EF_i$** : គំនរកត្តសម្រាប់ប្រព្រឹត្តិកម្ម **i, Gg $N_2O$/Kg** សំណល់ដែលបានប្រព្រឹត្តិកម្ម

**i** : ការអំពុក ឬ ការបំបែកអែនអែរូបិក ។

## ការដុតសំណល់ដោយមានការត្រួតពិនិត្យ និងការដុតដោយចំហ : ការសាយភាយ $C_2O$

ការសាយភាយ **$C_2O$** អាស្រ័យទៅហិមាណសំណល់ដែលដុត

$$C_2O\ សាយភាយ = \Sigma_i\ (SW_i \cdot dm_i \cdot Cf_i \cdot FCF_i \cdot Of_i)\ 44/12$$

**$C_2O$** សាយភាយ = $C_2O$ សាយភាយនៅក្នុងបញ្ជីសារពើភណ្ឌប្រចាំឆ្នាំ **Gg/year**

**$SW_i$** : ហិមាណសំណល់រឹងប្រភេទ i (ឆ្លឹងពេលនៅសើម) ដុតកម្ទេចចោលដោយមានការត្រួតពិនិត្យ ឬ ដុតដោយចំហ គិតជា **Gg/year**

**$dm_i$** : សំណល់ស្ងួត (ទម្ងន់សំណើម) ដុតកម្ទេចចោលដោយមានការត្រួតពិនិត្យ ឬដុតដោយចំហ (មេគុណ)

**$FCF_i$** : មេគុណនៃការបោនសំណល់ស្ងួត នៅក្នុងកាបូនសរុប

**$OF_i$** : កត្តអុកស៊ីតកម្ម (ជាមេគុណ)

**44/12** : មេគុណការប្តូរពី **C** ទៅ **$C_2O$**

**i** : ប្រភេទសំណល់ដែលដុតកម្ទេចចោលដោយមានការត្រួតពិនិត្យ ឬដុតដោយចំហជាសំណល់រឹងទីក្រុង សំណល់រឹងចេញពីរោងចក្រ កាកសំណល់ សំណល់ភក់ សំណល់ប្រកបដោយគ្រោះថ្នាក់, សំណល់មន្ទីរពេទ្យ ។

- ការគណនា តន្ទនៈការបោន ជា កត្តសំខាន់លើការកំណត់មេគុណការសាយភាយ **$C_2O$** ពីព្រោះវាជាប្រភពវត្ថុធាតុដើម (មានប្លាស្ទិក ក្រណាត់ប្រភេទខ្លះៗ កៅស៊ូ ទឹកសំអាត និងប្រេងចាស់ៗ)ដែលត្រូវរាប់បញ្ចូល។

## ការដុតសំណល់ដោយមានការត្រួតពិនិត្យ និងការដុតដោយចំហ : ការសាយភាយ $C_2O$

- សម្រាប់ការដុតក្រុមសំណល់រឹង

$$C_2O\ សាយភាយ = MSW \bullet \Sigma_i\ (WFj \bullet dm_j \bullet CFj \bullet FCF_j \bullet OF_j) \bullet 44/12$$

**$C_2O$** សាយភាយ = $C_2O$ សាយភាយនៅក្នុងបញ្ជីសារពើភណ្ឌប្រចាំឆ្នាំ **Gg/year**

**MSW** : ហិមាណសំណល់រឹងទីក្រុងសរុប ដុតទាំងនៅសើមដោយមានការត្រួតពិនិត្យ ឬ ដុតដោយចំហ គិតជា **Gg/year**

**$WF_j$** : មេគុណសំណល់រឹងទីក្រុងប្រភេទ **j** (ដុតទាំងនៅសើមដោយមានការត្រួតពិនិត្យ ឬ ដុតដោយចំហ)

**$dm_j$** : សំណល់ស្ងួត សំណល់រឹងទីក្រុងប្រភេទ **j** ដុតកម្ទេចចោលដោយមានការត្រួតពិនិត្យ ឬដុតដោយចំហ (មេគុណ)

**$FCF_j$** : មេគុណនៃការបោនសំណល់ស្ងួត (សមាសធាតុការបោន) នៅក្នុងសំណល់ប្រភេទ **j**

**$OF_j$** : កត្តអុកស៊ីតកម្ម (ជាមេគុណ)

**44/12** : មេគុណការប្តូរពី **C** ទៅ **$C_2O$**

**j** : ប្រភេទសំណល់រឹងទីក្រុង ដុតកម្ទេចចោលដោយមានការត្រួតពិនិត្យ ឬដុតដោយចំហ ក្រដាសកាតុង វាយនភណ្ឌ, សំណល់អាហារ, ឈើ, សំណល់សួន និងចំណតរថយន្ត, សំណល់កន្ទប, កៅស៊ូ និងស្បែកសត្វ, ជ័រ, កែវលោហៈ សំណល់និចល ។

## ការដុតកម្ទេចសំណល់ដោយមានការត្រួតពិនិត្យ ឬដុតដោយចំហ : ការសាយភាយឧស្ម័ន $CH_4$

លទ្ធផលសាយភាយ $CH_4$ មកពីការដុតសំណល់មិនបានល្អដែលវាបណ្តាលមកពីសីតុណ្ហភាពពេលវេលា និងខ្យល់។

$$CH4\ សាយភាយ = \Sigma_i\ (IW_i \cdot EF_i) \cdot 10^{-6}$$

**$CH_4$ សាយភាយ** : $CH_4$ សាយភាយនៅក្នុងបញ្ជីសារពើភណ្ឌប្រចាំឆ្នាំ គិតជា **Gg/year**

**$IW_i$** : ហិមាណសំណល់រឹង ប្រភេទ i ដុតកម្ទេចចោលដោយមានការត្រួតពិនិត្យ ឬដុតដោយចំហ គិតជា **Gg/year**

**$EF_i$** : កត្តដែលផ្តិជាការសាយភាយនូវឧស្ម័ន $CH_4$, Kg CH4/Gg នៃសំណល់

$10^{-6}$ : ការប្តូរកត្តាពីគីឡូក្រាមទៅគីកាក្រាម Gg

i : ប្រភេទសំណល់ដែលដុតកម្ទេចចោលដោយមានការត្រួតពិនិត្យ ឬដុតដោយចំហ(សំណល់រឹងទីក្រុង សំណល់រោងចក្រ សំណល់ដែលប្រកបដោយគ្រោះថ្នាក់ សំណល់មន្ទីរពេទ្យ សំណល់ភក់ ។ល។

- ចំនួន និងសមាសធាតុនៃកាកសំណល់គួរតែស្ថិតស្ថេរជាមួយទិន្នន័យ ដើម្បីងាយស្រួលក្នុងការ គណនារកឧស្ម័ន C2O និង N2O ដែលសាយភាយពីការដុតដោយចំហ ។

## ការដុតកម្ទេចសំណល់ដោយមានការត្រួតពិនិត្យ ឬដុតដោយចំហ : ការសាយភាយឧស្ម័ន $N_2O$

- ការសាយភាយឧស្ម័ន $N_2O$ កើតឡើងអាស្រ័យកម្តៅ (ការសាយភាយកម្រិតទាបកាលណាកម្តៅនៅចន្លោះពី ៥០០ ទៅ ៩០០ អង្សាសេ ) និងអាស្រ័យទៅនឹងសមាសភាពសំណល់ ។

$$N_2O \text{ សាយភាយ} = \Sigma_i ( IW \cdot EF_i ) \cdot 10^{-6}$$

**$N_2$0** សាយភាយ : $N_2O$ សាយភាយនៅក្នុងបញ្ជីសារពើភណ្ឌប្រចាំឆ្នាំ **Gg/year**

**$IW_i$** : បរិមាណសំណល់រឹង ប្រភេទ i ដុតកម្ទេចចោលដោយមានការត្រួតពិនិត្យ ឬដុតដោយចំហ គិតជា **Gg/year**

**$EF_i$** : កត្តាដែលផ្តុំជាការសាយភាយនូវឧស្ម័ន $N_2O$ ( $KgN_2O/Gg$ នៃសំណល់) ដែលសំណល់ជាi

**$10^{-6}$** : ប្រភេទសំណល់ដែលដុតកម្ទេចចោលដោយមានការត្រួតពិនិត្យ ឬដុតដោយចំហ(សំណល់រឹងទីក្រុង សំណល់រោងចក្រ សំណល់ដែលប្រកបដោយគ្រោះថ្នាក់ សំណល់មន្ទីរពេទ្យ សំណល់ភក់ ។ល។

## បរិមាណសំណល់ដែលដុតដោយចំហ

- ស្ថិតិប្រហែលជាមិនអាចរកបានទេ។ កន្លែងដែលទិន្នន័យដែលមិនអាចរកបាន បរិមាណសំណល់រឹងទីក្រុង នៃសំណល់ដុតដោយចំហ MSW អាចគណនាបានដោយរូបមន្ត

$$MSW_B = P \cdot P_{frac} \cdot MSW_p \cdot B_{frac} \cdot 365 \cdot 10^{-6}$$

**$MSW_B$** : បរិមាណសំណល់រឹងទីក្រុងសរុប ដុតទាំងនៅសើមដោយមានការត្រួតពិនិត្យ ឬ ដុតដោយចំហ គិតជា **Gg/year**



**P** : ចំនួនប្រជាជន (នាក់)

**$P_{frac}$** : មេគុណដែលប្រជាជនដុតសំណល់ចំហ (មេគុណ)

$MSW_p$ : បរិមាណសំណល់បញ្ចេញដោយមនុស្សម្នាក់ គិតជា គីឡូក្រាម ក្នុងមួយថ្ងៃ

$B_{frac}$ : មេគុណសំណល់ដែលត្រូវបានដុតទាក់ទងនឹងបរិមាណសំណល់ ដែលទទួលធ្វើប្រព្រឹត្តិកម្ម

365 : ចំនួនថ្ងៃក្នុងមួយឆ្នាំ

$10^{-6}$ : ការផ្លាស់ប្តូរកត្តាពីគីឡូក្រាមទៅជាគីកាក្រាម **Gg**

## ឧបករណ៍ និងសម្ភារៈ ផ្សេងៗដែលគាំទ្រក្នុងការគណនាការសាយភាយ

- IPCC EFDB
  - ✔ ផ្តល់ជូនយ៉ាងទូលំទូលាយនូវដំណើរការនៃ **EFs** និងប៉ារ៉ាម៉ែត្រ ផ្សេងៗជាមួយសាវតារឯកសារទាំងឡាយ ឬ បច្ចេកទេសយោង ដែលអ្នកប្រើប្រាស់អាចជ្រើសរើសនិងប្រើប្រាស់ទិន្នន័យសមរម្យទៅលើការទទួលខុសត្រូវរបស់ពួកគេផ្ទាល់ ។
  - ✔ អាចទទួលបានព័ត៌មានពី **http://www.ipcc-nggip.iges.or.jp/EFDB** ។

- កម្មវិធីកុំព្យូទ័រជាមគ្គុទ្ទេសក៍ **2006 IPCC** ។
  - ✔ កម្មវិធីថ្មី មាននៅចុងឆ្នាំ ២០១១ ឬដើមឆ្នាំ ២០១២

- ព័ត៌មាននៅលើគេហទំព័រ **TFI** ។
  - ✔ មានជាសំណួរចម្លើយ FAQ
  - ✔ ការធ្វើបទបង្ហាញ
  - ✔ ឯកសារ (កិច្ចប្រជុំ, របាយការណ៍, សៀវភៅព័ត៌មាន ។ល ។

## សរុប

- ការគណនាការសាយភាយ ឬធ្វើបញ្ជីសារពើភណ្ឌសាយភាយ ផ្តល់ព័ត៌មានពីកម្រិត និងនិន្នាការ នៃការសាយភាយ និងធ្វើអោយអាចត្រួតពិនិត្យ លើការអនុវត្តន៍ គោលនយោបាយ ដើម្បីកាត់បន្ថការសាយភាយ ។
- មគ្គុទ្ទេសក៍ **IPCC 2006** សម្រាប់បញ្ជីសារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ អនុវត្តន៍ការកាត់បន្ថយ និងលប់បំបាត់ការសាយភាយ ។
- វិធីសម្រាប់គណនាការ សាយភាយ ឧស្ម័នផ្ទះកញ្ចក់ ពីការប្រព្រឹត្តិកម្មសំណល់រឹង និងទឹកសំអុយត្រូវបានផ្តល់ជាលើកទី ៥ របស់មគ្គុទ្ទេសក៍ **IPCC 2006** ។
- **IPCC TFI** ផ្តល់អោយការបន្ថែមកា រឧបករណ៍ និងសម្ភារៈសម្រាប់គណនានិងលប់បំបាត់ការសាយភាយ ឧស្ម័នផ្ទះកញ្ចក់ ( កម្មវិធី **EFDB** និងសម្ភារៈ ផ្សេងៗទៀត នៅលើ គេហទំព័រ **TFI)** ៕



# ការធ្វើអោយថយចុះនូវការសាយភាយឧស្ម័នផ្ទះកញ្ចក់ តាមរយៈការធ្វើប្រព្រឹត្តិកម្ម និងការទាញយកផលប្រយោជន៍សមស្រប ពីសំណល់ប្លាស្ទិក

វាគ្មិន YOICHI KODER PhD,
Senior Research Scientist National Institute of Advance Industrial Science & Technology

## កម្មវត្ថុ

- ក្នុងបំណងផ្សព្វផ្សាយឲ្យបានយល់ដឹងថា ប្លាស្ទិកជាបញ្ហាចម្បងក្នុងការធ្វើប្រព្រឹត្តិកម្មសំណល់
- ក្នុងបំណងផ្សព្វផ្សាយឲ្យយល់ដឹងពីទំនាក់ទំនងរវាងការសាយភាយឧស្ម័នផ្ទះកញ្ចក់ និងសំណល់ប្លាស្ទិក ។
- លើកឡើងពីវិធានការវាស់ការសាយភាយឧស្ម័នផ្ទះកញ្ចក់ ដើម្បីរៀបចំការគ្រប់គ្រងសំណល់ប្លាស្ទិក ។

## មាតិកា

១. ប្លាស្ទិក, ជាសមាសធាតុសំខាន់ ក្នុងការកើនឡើងសំណល់ ។
២. វដ្តប្លាស្ទិក និងការសាយភាយឧស្ម័នផ្ទះកញ្ចក់ ។
៣. ឧទាហរណ៍ ស្តីពីការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់តាមរយៈសកម្មភាពកែច្នៃ ។
៤. វិធី កែច្នៃខុសៗគ្នា ។
៥. ច្បាប់ស្តីពីការកែច្នៃដែលទាក់ទងទៅ នឹងសំណល់ប្លាស្ទិកនៅជប៉ុន ។

## ការកើនឡើងសំណល់ស្របនឹងកំណើន GDP

http://www5.cao.go.jp/keizai-shimon/special/pdf/1004item7.pdf

### បរិមាណសំណល់រឹងទីក្រុងដែលប្រជាពលរដ្ឋម្នាក់បង្កើតក្នុងមួយថ្ងៃ

(Kg/Cap/Day)

| ប្រទេស | GDP<br>គិតជា US$ | សំណល់<br>Kg/Cap/Day |
|---|---|---|
| កម្ពុជា | ក្រោម ៣០០ | កៀកទៅ ០,៣៥ |
| ណាប៉ាល់ | ក្រោម ៣០០ | ០,៤ |
| ឥណ្ឌូណេស៊ី | ច្រើនជាង ២០០០ បន្តិច | ០,៦ |
| ម៉ាឡេស៊ី | ប្រហែល ៦០០០ | ០,៥ |
| សាំងហ្គាពួរ | ប្រហែល ១៦០០០ | ប្រហែល ០,៨៥ |
| ជប៉ុន | ជិតដល់ ១៨០០០ | ជិតដល់ ១ |




## កំណើនសំណល់នៅប្រទេសមួយចំនួនលើពិភពលោក




Fig. 4 Relationship of GDP per capita and MSW generation rate

- ប្រទេសដែលបង្កើតសំណល់ច្រើនជាងគេមាន សហរដ្ឋអាមេរិក, ប្រទេសអៀរឡង់, អូស្ត្រាលី, ហុងគ្រី, ។
- ប្រទេសដែលបង្កើតសំណល់កម្រិតមធ្យមមាន ប្រទេសកាណាដា, ម៉ិកស៊ិក, កូរ៉េខាងត្បូង, អូទ្រីស, បែលហ្ស៊ិក, ឆែក, ដាណឺម៉ាក, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិក, អ៊ីស្លង់, អ៊ីតាលី, ហូឡង់, ណ័រវេស, ប៉ូឡូញ, ព័រទុយហ្គាល់, អេស្ប៉ាញ, ស្វីស, ទួរគី, អង់គ្លេស, ស្លូវ៉ាគី,
- លុចហ្សំបួរ, ជប៉ុន, ញ៉ូស៊ីឡែន, ស៊ុយអែត ប្រទេសដែលបង្កើតសំណល់កម្រិតទាបជាងគេ។

## ការបង្កើតសំណល់រឹងទីក្រុង (ឆ្នាំ១៩៩៥)

ប្រភពព័ត៌មាន ធនាគារ/ធនាគារពិភពលោក - ធនាគារអន្តរជាតិសម្រាប់ការស្តាបនាឡើងវិញ និងការអភិវឌ្ឍន៍ ការគ្រប់គ្រងសំណល់រឹងនៅអាស៊ី។

http://web.mit.edu/urbanupgrading/urbanenvironment/resources/references/pdfs/WhatAWasteAsia.pdf

| Country | GNP Per Capita [1] (1995 US $) | Current Urban Population (% of Total)[2] | Current Urban MSW Generation (kg/capita/day) |
|---|---|---|---|
| **Low Income** | **490** | **27.8** | **0.64** |
| Nepal | 200 | 13.7 | 0.50 |
| Bangladesh | 240 | 18.3 | 0.49 |
| Myanmar | 240* | 26.2 | 0.45 |
| Vietnam | 240 | 20.8 | 0.55 |
| Mongolia | 310 | 60.9 | 0.60 |
| India | 340 | 26.8 | 0.46 |
| Lao PDR | 350 | 21.7 | 0.69 |
| China | 620 | 30.3 | 0.79 |
| Sri Lanka | 700 | 22.4 | 0.89 |
| **Middle Income** | **1,410** | **37.6** | **0.73** |
| Indonesia | 980 | 35.4 | 0.76 |
| Philippines | 1,050 | 54.2 | 0.52 |
| Thailand | 2,740 | 20.0 | 1.10 |
| Malaysia | 3,890 | 53.7 | 0.81 |
| **High Income** | **30,990** | **79.5** | **1.64** |
| Korea, Republic of | 9,700 | 81.3 | 1.59 |
| Hong Kong | 22,990 | 95.0 | 5.07 |
| Singapore | 26,730 | 100 | 1.10 |
| Japan | 39,640 | 77.6 | 1.47 |

[1]World Bank, 1997b
[2]United Nations, 1995
*estimated GNP

See Figure 7 for comparison to 2025.

## សមាសធាតុសំខាន់នៅក្នុងសំណល់ផ្ទះបាយ

សំណល់ផ្ទះបាយ សំណល់ប្លាស្ទិក សំណល់ក្រដាស និងសំណល់ផ្សេងទៀត។



## សំណល់ផ្ទះសម្បែងនៅប្រទេសអង់គ្លេស ឆ្នាំ 2006-2007

http://www.resourcesnotwaste.org/upload/documents/webpage/RRF%20Advisory%20Committee/JulianParfitt(2010)presentation.pdf




## សំណល់ទីក្រុងនៅក្នុងទីក្រុងបាងកក, ប្រទេសថៃ

http://gec.jp/gec/en/Activities/EST/2009/wasteplatics/D2_AliceSharp.pdf



## លក្ខណៈសម្បត្តិសំណល់

| ប្រភេទ | កម្តៅ | បរិមាណសំងួត | ឥន្ធនៈការបោន | $CO_2$ ភាយពីឥន្ធនៈការបោន | ការបោនជីវៈ | សក្តានុពល $CH_4$ |
|---|---|---|---|---|---|---|
| | MJ/Kg-wet | %Wet base | % Total solid | Kg/ 100kg Total solid | % Total solid | L/Kg-Dry solid |
| ប្លាស្ទិក | 34.1 | 89.1 | 79.3 | 290.8 | 0.4 | 0 |
| ក្រដាស | 12.9 | 90.5 | 0.2 | 0.7 | 32.7 | 158.1 |
| សំណល់ផ្ទះបាយ | 5.8 | 29.6 | 0.5 | 1.8 | 49 | 435.7 |
| សំណល់តាមសួនច្បារ | 7.5 | 52.2 | 0.8 | 2.9 | 43.1 | 114.6 |
| សំណល់កាតុង | 13.6 | 80.6 | 2.1 | 7.7 | 42.4 | 154.8 |

## ការប្រមូលសំណល់តាមប្រភេទសំណល់ដែលញែកនៅប្រទេសជប៉ុន

- **សំណល់អាចដុតឆេះ មាន៖** សំណល់ផ្ទះបាយ សំណល់ឈើ សំណល់ក្រដាស (នៅទីក្រុងមួយចំនួនគេប្រមូលវាហើយញែកវាដើម្បីធ្វើការកែច្នៃឡើងវិញ)
- **សំណល់មិនអាចដុតឆេះ**
- **សំណល់ដែលអាចយកធ្វើជាវត្ថុធាតុដើមបានវិញ មាន៖** សំណល់ប្លាស្ទិក ( ដបដប ប្រអប់ ដបប្រភេទ PET ) សំណល់កំប៉ុង (ដែក អាលុយមីញ៉ូម) ដបកែវ (ពណ៌ ថ្លា សុកុឡា និងផ្សេងទៀត)
- **សំណល់គ្រោះថ្នាក់**



## មធ្យោបាយដែលជាជម្រើសសម្រាប់ប្រព្រឹត្តិកម្មសំណល់ មានការដុតកម្ទេចចោល យកទៅចាក់ចោលនៅទីលាន និង កែច្នៃ

- សំណល់អាហារ => ធ្វើការអំពុកដើម្បីក្លាយជាជីកំប៉ុស
- សំណល់ក្រដាស => ធ្វើការកែច្នៃសំណល់ក្រដាសអោយក្លាយជាក្រដាសថ្មី
- បង្កើនឡើងការកែច្នៃសំណល់ប្លាស្ទិក => ធ្វើការកែច្នៃជាជ័រ និងចម្រាញ់ចេញជាឥន្ធនៈ

តើការសាយភាយឧស្ម័ន CO2 មានផលប៉ះពាល់ដល់បរិស្ថានដែរ ឬទេ?

## ការកាត់បន្ថយផលប៉ះពាល់បរិស្ថានតាមរយៈការទាញយកផលប្រយោជន៍ពីប្លាស្ទិក

១. កែច្នៃ ឲ្យទៅជាជ័រ

- សំណល់ប្លាស្ទិកដែលធ្វើការញែក អាចយកទៅធ្វើការកែច្នៃដើម្បីធ្វើជាជ័រ ។
- នេះគឺជាយន្តការមួយក្នុងការអភិវឌ្ឍន៍ស្អាត ដែលបានឆ្លងកាត់អង្គការសហប្រជាជាតិ ។ http://cdm.unfccc.int/UserManagement/FileStorage/T1INGS9C34QMRP2YXJ78UHAZVD5FL6

២. ជាអ្នកឥន្ធនៈស្អាតជាង ធ្យូង ឬប្រេងចាស់

- ប្លាស្ទិកខ្លះអាចផលិតទៅជាវត្ថុរឹង វត្ថុរាវ និងឧស្ម័ន។ ជាផ្តល់អោយនូវការឥន្ធនៈស្អាត ឧស្ម័នចេញជាងធ្យូង និងប្រេងចាស់ ហើយមិនមាន $CO_2$ និង$NO_x$ច្រើន។

## វដ្តនៃប្លាស្ទិក ១

វត្ថុធាតុដើម

- ប្រេងឆៅ ទៅប្រេងសាំង
- ប្រេងមិនទាន់ចម្រាញ់ទៅជាអេទីឡែន និងផ្សេងៗទៀត

ប៉ូលីមែរ

- អេទីឡែន ទៅជាពហុអេទីឡែន
- ផលិតផលគីមីផ្សេងៗទៀត

សម្ភារៈធ្វើពីប្លាស្ទិក

- សូនធ្វើជារូបរាងផ្សេងៗ
- ហ្វីល

## វដ្តនៃប្លាស្ទិក២

### ប្រើប្រាស់

- ផលិតផលធ្វើពីប្លាស្ទិកតែមួយមុខ ឬលាយជាមួយសមាសធាតុផ្សេងទៀត
- ប្លាស្ទិកអាចប្លាស្ទិករឹង ឬទន់

### ការប្រមូល

- សំណល់ជារបស់របរទាំងមូល
- តម្រូវឲ្យមានការញែកអង្គធាតុចេញ

### ធ្វើប្រព្រឹត្តិកម្ម

- យកទៅចោល ឬដុត ដាក់ទីលាន
- កែច្នៃ ឬ កែច្នៃជាជ័រ ឬ ឥន្ធនៈ

## វដ្តនៃប្លាស្ទិក ៣

ពីប្រេងឆៅទៅជារបស់របរប្រើប្រាស់កាត់ តាមរយៈ ប៉ូលីម៊ែរ និងផលិតផលជ័រ។

ប្រេងឆៅ => រោងចក្រស្លប្រេង => ប៉ូលីម៊ែរឬ ជ័រ => ក្លាយជាផលិតផលប្លាស្ទិក => ប្រើប្រាស់ => សំណល់ប្លាស្ទិក => ប្រមូលកែច្នៃ => ទៅជាជ័រសម្រាប់ផលិត របស់របរប្រើប្រាស់ពីប្លាស្ទិក។

## កាត់បន្ថយការសាយភាយឧស្ម័ន $CO_2$ តាមរយៈការប្រើប្រាស់របស់កែច្នៃប្លាស្ទិក

សំអាតប្លាស្ទិក => ស្អាតតែនៅមានថ្នាំពណ៌។






| ផលប៉ះពាល់ដល់បរិស្ថាន | ធ្វើការកែច្នៃ កញ្ចប់ប្លាស្ទិក ៦០% | កញ្ចប់ប្លាស្ទិក ថ្មី |
|---|---|---|
| ថាមពលជាវត្ថុធាតុដើមគិតជា Gj | 11 | 32 |
| ថាមពលលើការដឹកជញ្ជូននិងដំណើរការ គិតជា Gj | 25 | 33 |
| $CO_2$/ton | 2.4 | 4.5 |
| $SO_x$ | 1.6 | 2.7 |
| $NO_x$ | 2.4 | 3.2 |
| សំណល់រឹង/Kg | 8.7 | 22 |

## ការកាត់បន្ថយឧស្ម័នCO2 ដោយធ្វើការកែច្នៃប្លាស្ទិក

កញ្ចែ្រង ៦០% បានកែច្នៃជាប្លាស្ទិកជ័រ កញ្ចែ្រង១០០% ជាប្លាស្ទិកថ្មី




ការកាត់បន្ថយផលប៉ះពាល់បរិស្ថានដោយធ្វើការកែច្នៃជ័រ60%

## ហេតុអ្វីបានយើងកែច្នៃសំរាម?

1. រដ្ឋាភិបាលមូលដ្ឋាន និងការគ្រប់គ្រងក្រុមហ៊ុន: លក់ផលិតផលអេតចាយដើម្បីប្រាក់ចំណូល
2. កាត់បន្ថយសម្ភារ: ឬថាមពលប្រើប្រាស់ដោយប្រើសំណល់ជាប្រភពធនធាន
3. កាត់បន្ថយផលប៉ះពាល់បរិស្ថានដោយបម្លែងសំណល់ទៅជាថាមពល ឬសម្ភារ:។

## ការគ្រប់គ្រង (កែច្នៃ) សំណល់ប្លាស្ទិក ភាគច្រើនដែលគេបានអនុវត្តន៍ ក្រោយ

កែច្នៃ សំណល់ប្លាស្ទិកទៅជាជ័រ ដុតយកកម្តៅ និង កែច្នៃ ទៅជាឥន្ទនៈ។

## ឥន្ទនៈរឹង

- ផលិតផល៖ ការកម្ទេច និងសូនជាគ្រាប់។ ដំណើរការសម្ងួតត្រូវធ្វើចំពោះសំណល់សើម។ ការសូនជាគ្រាប់ត្រូវធ្វើនៅ សីតុណ្ហភាព ២០០ °C។
- ផលិតផល: Pyrolysis ធ្វើការចំហុយ។ សំណល់ខ្លះតម្រូវអោយធ្វើការកម្ទេច ឬញែកចេញ។

## ឧស្ម័នឥន្ទនៈ

- ផលិតផល: កម្ទេច និងPyrolysis។
- ម៉ាស៊ីនកម្តៅ: - ថាមពលម៉ាស៊ីន., ឬចំហេះឧស្ម័នពីតួប៊ីន- ថាមពលម៉ាស៊ីន។
- បញ្ហាចម្បង: ការដាក់បញ្ចូលល្បាយទៅក្នុងបំពង់ឡ និងញែកជ័រឧស្ម័ន។



## ការកាត់បន្ថយផលប៉ះពាល់ដោយការប្រើប្រាស់ឥន្ធនៈស្អាតមកពីសំណល់ប្លាស្ទិក




| Heat | Ash | Flue gas |
|---|---|---|
| ◎ | ◎ | ◎ |
| ◎ | ◎ | ○ |
| ○ | △ | △ or × |
| △ | × | × |

## ច្បាប់ដែលទាក់ទងទៅនឹងសំណល់ប្លាស្ទិកនៅក្នុងប្រទេសជប៉ុន

| ច្បាប់ស្តីពី | ឧទាហរណ៍ពីការកែច្នៃប្លាស្ទិក | បញ្ហា |
|---|---|---|
| សំណល់វិញខ្ចប់ និងច្បាប់កែច្នៃ | ផលិតផលជ័រ ចូលចិត្តប្រើប្រាស់ជាធ្យូងជំនួសក្នុងឡធ្យូង និងផលិតផលឧស្ម័ន | តម្លៃខ្ពស់ ៨០ Yen/Kg ក្នុងផលិតផលជ័រ ឡធ្យូងប្រព្រឹត្តិកម្ម ៤០ Yen/Kg |
| ច្បាប់កែច្នៃផលិតផលតាមផ្ទះ | សកម្មភាពសំអាតប្លាស្ទិកមានសកម្មភាពខ្លាំង។ ការញែកសំណល់កែច្នៃត្រូវបានក្លាយទៅជាជំនួញ | ល្បាយប្លាស្ទិក និងប្លាស្ទិកមិនកែច្នៃ ដូចជា ជ័រឈើ |
| ច្បាប់កែច្នៃយានយន្តខូច | ASR ដែលមានប្លាស្ទិក និងសំណល់ដែលប្រឡាក់ ត្រូវបានអនុញ្ញាតអោយដុតចោល។ | ការទទួលបានមកវិញយ៉ាងត្រឹមត្រូវនូវលោហៈនិងប្លាស្ទិក |

គោលដៅប្លាស្ទិកផ្សេងទៀតនៅពេលអនាគត: សំណល់អេឡិចត្រូនិក លោហ: គ្មានការខ្ចប់, កម្ទេចកំទីនៅលើផ្ទៃសមុទ្រ, វាយនភណ្ឌ, និងផលិតផលកសិកម្ម ។

## ស្ថានការណ៍ការកែច្នៃ

- សំណល់ត្រូវបានញែកពីសំណល់ឧស្សាហកម្ម ពាណិជ្ជកម្ម និងសំណល់ទីក្រុង (សំណល់ដែលចេញពីផ្ទះសម្បែង)។
- មានសំណល់កែច្នៃនិងការកែច្នៃអនុបាតមាននិន្នាការយ៉ាងជាប់លាប់បន្ទាប់ពីការបង្កើតច្បាប់កែច្នៃ។




## ច្បាប់កែច្នៃ សំណល់វេចខ្ចប់

វាមានសារៈសំខាន់ណាស់ដើម្បីដោះស្រាយបញ្ហាទីលានចាក់សំរាម និងបង្កើតសង្គមមួយឲ្យតម្លៃការងារកែច្នៃ។ បដិសេធការយកសំណល់អាចកែច្នៃ ទៅចាក់ចោលនៅទីលាន បន្ថយមាឌសំណល់ទីក្រុង។ សំណល់វេចខ្ចប់ ប្រមាណ ៦០% ជាសំណល់តាមផ្ទះ(គិតជាមាឌ)។




## ច្បាប់ផ្ទុកកែច្នៃសំណល់វេចខ្ចប់

មូលដ្ឋានគ្រឹះនៃច្បាប់នេះគឺអ្នកដែលពាក់ព័ន្ធទាំងអស់ត្រូវដើរតួនាទីក្នុងការកែច្នៃ។ អ្នកប្រើប្រាស់គួរតែញែកសំណល់ពួកគេដោយឡែកពីគ្នា, ចំពោះសំណល់ទីក្រុងគួរតែប្រមូលសំណល់ដើម្បីធ្វើការញែក, ហើយអាជីវកម្មគួរកែច្នៃនូវអ្វីដែលគាត់បានប្រមូលទៅជាផលិតផលថ្មី។




## ចំណោទ និងកង្វល់អំពីច្បាប់

ថ្មីៗនេះ, យើងធ្វើការរកឃើញចំណុចខ្វះខាតច្បាប់កែច្នៃសំណល់វេចខ្ចប់នៅក្នុងប្រទេសជប៉ុនដូចជា

1. ប្រសិទ្ធភាពប្រព័ន្ធកែច្នៃ (ឧទាហរណ៍ កាត់បន្ថយការចំណាយ ប្រសិទ្ធភាពចំណាយ និងការបង្កើតតម្លៃផលិតផលកែច្នៃ)
2. ធ្វើអោយប្រសើរឡើងភាពយុត្តិធម៌ ស្មើភាព និងស្មោះភាព
3. លើកទឹកចិត្ត ការទប់ស្កាត់ និងប្រើប្រាស់ឡើងវិញ។

1. ធ្វើអោយប្រសើរឡើង នូវប្រព័ន្ធកែច្នៃ
   - → កាត់បន្ថយការចំណាយ / ប្រសិទ្ធភាព
     - រួមបញ្ចូលតម្លៃសង្គមកិច្ចក្នុងដំណើរការទាំងមូល ពីការញែកសំណល់ ប្រមូល និងកែច្នៃ
   - → ការបង្កើត/លើកកម្ពស់តម្លៃផលិតផលកែច្នៃ
2. ធ្វើអោយប្រសើរឡើងនូវយុត្តិធម៌ភាព ច្បាស់លាស់ និងស្មោះភាព
   - → ពិចារណាអំពីតួនាទី និងការទទួលខុសត្រូវអំពីនាក់ដែលមានការពាក់ព័ន្ធនិងការប្រតិបត្តិការរបស់ពួកគេ
   - → ទប់ស្កាត់ ការអនាធិបតេយ្យ។
3. លើកកម្ពស់ការទប់ស្កាត់ និងប្រើប្រាស់គោលដៅ ឡើងវិញ → វិធីដាក់បរិមាណការទប់ស្កាត់ និងឯកតា

# គម្រោងដុតសំណល់ប្លាស្ទិកបម្លែងទៅជាឥន្ធនៈ នៅ ប្រទេសថៃឡង់ដ៏ ករណីសិក្សានៅ ទីក្រុង *Warinchamrap*

***Dr. Rungnapa Tubnonghee* ប្រធានតាយកដ្ឋាន សុខភាពសាធារណៈនិងបរិស្ថាន ក្រុង *Warinchamrap Municipality*, ខេត្ត *Ubonratchathani***

## ១. បុព្វយោគ

- សំណល់រឹងទីក្រុងនៅប្រទេសថៃទាំងមូលមានបរិមាណប្រហែល ១៥,០៦ លានតោនក្នុងមួយឆ្នាំ ឬ ៤១១០០ តោនក្នុងមួយថ្ងៃ
- ៣០% សំណល់ដែលអាចកែច្នៃបាន ក្នុងនោះ ១៦,៨ ភាគរយ ជាសំណល់ប្លាស្ទិក
- នៅ ទីក្រុង **Warinchamrap** សំណល់រឹងទីក្រុង មាន ២៤ ទៅ ២៥ តោនក្នុងមួយថ្ងៃ
- ២០% សំណល់ដែលអាចកែច្នៃបាន ក្នុងនោះ ១២,៦ ភាគរយ ជាសំណល់ប្លាស្ទិក
- នៅទីក្រុងនេះ គេញែកសំណល់ តាមរយៈអនុវត្តន៍គោលការណ៍ កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និង កែច្នៃ
- នៅ ទីក្រុង **Warinchamrap** គេកាត់បន្ថយបរិមាណសំណល់នៅប្រភពតែម្តង ដូចជានៅតាមផ្ទះ តាមសាលារៀន តាមផ្សារ ទីវត្តអារាម ។ល។
- មានការលើកស្ទួយការងារញែកសំណល់នៅតាមសហគមន៍ តាមរយៈវគ្គបណ្តុះបណ្តាលស្តីពី ការញែកសំណល់ សំណល់សម្រាប់លក់ សកម្មភាពកែច្នៃ សំណល់ធ្វើអ៊ីអឹម និងធ្វើកុំប៉ុស។
- នៅប្រទេសថៃ ទីលានចាក់សំរាម ភាគច្រើនជាទីលានចំហ ទីលានដែលមានការគ្រប់គ្រង។ សមកម្មភាពកែច្នៃនៅមានកម្រិត។
- ថង់ប្លាស្ទិកជាចំណោទមួយនៅប្រទេសថៃ ព្រោះបរិមាណសំណល់ប្លាស្ទិកដែលអាចកែច្នៃបានមានចំនួនតិច និងការវិនិយោគនិងដំណើរការកែច្នៃនៅមានតម្លៃខ្ពស់។
- សំណល់រឹងទីក្រុង ភាគច្រើនត្រូវបានយកទៅចាក់ចោលនៅទីលានចាក់សំរាម។ ៩០ភាគរយសំណល់ប្លាស្ទិកទីក្រុងត្រូវបានគេយកទៅធ្វើប្រព្រឹត្តិកម្ម **PE** និង **PP** ។
- នៅ **Warinchamrap** មានទីលានអនាម័យ ចំនួន ៣ កន្លែង។ ទីលាន G និង F ត្រូវគ្របបិទតាំងពីប្រាំឆ្នាំមុន ២០០៥ – ២០០៦។
- នៅប្រទេសថៃគេពេញនិយមគ្រប់គ្រងសំណល់ប្លាស្ទិក តាមការកែច្នៃដោកយញែកសំណល់នេះ







ចេញពីសំណល់ទីក្រុងដទៃទៀត កែទម្រង់សំណល់ប្លាស្ទិកតាមរយៈដុតវាទាញយកឥន្ធនៈ។

- នៅប្រទេសថៃមានគោលនយោបាយលើកកម្ពស់ឲ្យមានការប្រើប្រាស់ថាមពលកកើតឡើងវិញ។ ការិយាល័យគោលនយោបាយថាមពល និងផែនការ ក្រសួងថាមពល បានគាំទ្រថវិកាសម្រាប់អង្គការក្នុងស្រុក បី សម្រាប់អនុវត្តន៍គម្រោង កែទម្រង់តាមរយៈការដុតវាទាញយកឥន្ធនៈ ឆ្នាំ ២០៩៩ - ២០១០។

## កែទម្រង់សំណល់ប្លាស្ទិកតាមរយៈការដុតវាទាញយកឥន្ធនៈ រាវ

នៅ **Warinchamrap** គម្រោងកែទម្រង់សំណល់ប្លាស្ទិកតាមរយៈដុតវាទាញយកឥន្ធនៈដោយក្រុមហ៊ុន **Muang Sa-ad Co.,** ។

គម្រោងកែទម្រង់សំណល់ប្លាស្ទិកតាមរយៈការដុតវាទាញយកឥន្ធនៈមានពីរដំណាក់កាលៈ

- ញែកសំណល់ប្លាស្ទិកណាដែល ចម្រាញ់យកប្រេងបាន។ ធ្វើនៅលើទីលានចាក់សំរាម G (មានអាយុពីឆ្នាំ) ដែលមានសំណល់១២៥០០០ តោន ។ សំណល់ប្លាស្ទិកដែលញែកបាន ត្រូវបានសំអាត និង សម្ងួត។
- ចម្រាញ់ថង់ប្លាស្ទិកយកប្រេង។ សំណល់ដែលលក់បាន។ polypropylene (PP), polyethylene (PE) and polystyrene (PS) ជាសមាសធាតុសំខាន់បំផុតនៅក្នុងប្លាស្ទិក។ នៅក្រោមលក្ខខណ្ឌប្លាស្ទិកក្លាយទៅជាហ្គាស វត្ថុរាវ និងកាកដែលនៅសល់ជាវត្ថុរឹង។ សំណល់ប្លាស្ទិកត្រូវបានដុតក្នុងកម្តៅ ពី ៣៨០ ទៅ ៤៣០ អង្សាសេ។ ការដុតក្នុងកម្តៅ ៤៣០ អង្សាសេ មានរយៈពេល ៤ម៉ោង ទៅ៦ម៉ោង។ នៅក្នុងដំណើរការឡដុតកម្តៅក្រោមអវត្តមានអុកស៊ីហ្សែន។ ចំហាយដែលភាយចេញវាក្លាយទៅជាវត្ថុរាវនៅក្រោមកំដៅ២៥ អង្សាសេ។ ពេលណាវត្ថុរាវ ចុះត្រជាក់ វាក្លាយជា ប្រេងឆៅ និងជីវ។
- ចេញពីឡដែលចម្រាញ់ ប្លាស្ទិក ១០តោនក្នុងមួយថ្ងៃ ឬ ៣០០ តោនក្នុងមួយខែ ៣០០០តោនក្នុងមួយឆ្នាំ ទិន្នផលប្រេងឆៅទទួលបាន ៦០ភាគរយ មានបរិមាណ ៦៦០០ លីត្រក្នុងមួយ ១៩៨០០០លីត្រក្នុងមួយខែ ១៩៨០០០០ លីត្រក្នុងមួយឆ្នាំ។

សំណល់ដែលមិនមានការញែកនៅប្រភព ត្រូវបានយកទៅធ្វើប្រព្រឹត្តិកម្មបែបជីវៈមេកានិក។ ក្រោយពីដំណើរប្រព្រឹត្តិកម្មចប់ សំណល់ទាំងត្រូវបានរែង យកសំណល់សំណល់ប្លាស្ទិក សម្រាប់ដុតចម្រាញ់យកប្រេង និង សំណល់ដែលនៅសល់ពីនេះ មានលក្ខណៈស្រដៀង កុំប៉ុស ដុតយកចំហាយកម្តៅ។

## ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

សំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវបានយកមកទុកដាក់មួយកន្លែងសម្រាប់ប្រមូលនិងដឹកជញ្ជូន យកទៅទុកនៅស្ថានីយស្តុកបណ្តោះអាសន្នមួយកន្លែងសម្រាប់ រៀបចំយកទៅចាក់នៅទីលានសុវត្ថិភាពមួយគ្រប់គ្រងដោយក្រុមហ៊ុនឯកជន។

## ការគ្រប់គ្រងសំណល់ដែលនាំឲ្យមានការចម្លងមេរោគ

សំណល់ដែលនាំឲ្យការចម្លងមេរោគ ត្រូវបានប្រមូល និងយកទៅដុតកម្ទេចចោល។ ដំបូងសំណល់នេះត្រូវបានបញ្ជូនទៅ ស្ថានីយស្តុកបណ្តោះអាសន្នមួយកន្លែងសម្រាប់ រៀបចំយកទៅដុតកម្ទេចចោល។

## ការធ្វើប្រព្រឹត្តិកម្មសំណល់តាមបែបជីវៈមេកានិក

ជាប្រព្រឹត្តិកម្មដំណើរការដោយមេកានិកផង និងជីវៈផង។

- ការធ្វើប្រព្រឹត្តិកម្មដោយមេកានិក មានការរើសយកសំណល់ដែលអាចកែច្នៃបាន ដូចជា ដែក កែវ ក្រដាស សំណល់គ្រឿងសង្ហារិម ។ល។ ការធ្វើប្រព្រឹត្តិកម្មបែបនេះ អាចធ្វើបានដោយដៃ ឬដោយម៉ាស៊ីនស្វ័យប្រវត្តិ។
- ការធ្វើប្រព្រឹត្តិកម្មដោយជីវៈតាមរយៈការសំងួតសំណល់ដោយកម្តៅថ្ងៃ ការបំបែកតាមរយៈអែរ៉ូបិក កុំប៉ុស ឬដំណើរការទាំងពីររួមគ្នា។
- ជាប្រព្រឹត្តិកម្មដំណើរការដោយជីវៈមេកានិកផង ធ្វើឡើងតាមបែបមេកានិកមុន បន្ទាប់មក ធ្វើតាមបែបជីវៈ ។

## កន្លែងធ្វើប្រព្រឹត្តិកម្មសំណល់បែបជីវៈមេកានិក។

តម្រូវឲ្យមានរៀបចំជារង សម្រាប់ការគរសំណល់។ រងមួយៗមាន ទំហំ បណ្តោយ២៥ ម៉ែត្រ និង ទទឹង ២,៥ ម៉ែត្រ និងជម្រាល ប្រហែល៣ ភាគរយ ។ បាតក្រោមនៃរងសំណល់មានរាយបំពង់សម្រាប់បញ្ចូលខ្យល់។ សំណល់យកមកធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក ត្រូវច្របល់វា ដោយម៉ាស៊ីនជាមុន។ ក្នុងរយៈពេលដំណើរការ ប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក នេះ មានការជ្រោយរងសំណល់ ដោយប្រើប្រាស់គ្រឿងយន្ត។





បើមានឈើទ្រនាប់ដាក់ឥវ៉ាន់ ដែលគេបោះបង់ចោល អាចយកមកក្រាលពីក្រោមរងសំណល់។ ជាទីបញ្ចប់សំណល់ដែលធ្វើប្រព្រឹត្តិកម្មរួចត្រូវបានយកវាទៅរែង ហើយសមិទ្ធផលដែលទទួលបាន មានស្រដៀងដូចកុំប៉ុស ។ សំណល់ដែលសល់ពីការរែងភាគច្រើនជាសំណល់ប្លាស្ទិក ត្រូវបានយកទៅដុតចម្រាញ់យកប្រេង ដោយម៉ាស៊ីនចម្រាញ់។

## សេចក្តីសន្និដ្ឋាន

- សំណល់ដែលយកមកធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក ជាសំណល់ដែលនិចល សម្រាប់ធ្វើប្រព្រឹត្តិកម្មចុងក្រោយ។
- កាត់បន្ថយទឹកសំអុយនៅពេល ធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក តាមរយៈបញ្ចូលខ្យល់ទៅក្នុងរងសំណល់។
- សំណល់ដែល ធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិករួច មានលំនឹង និងថយការសាយភាយឧស្ម័នទីលាន បើសំណល់នោះតម្រូវឲ្យយកទៅចាក់ចោលនៅទីលានចាក់សំណល់។
- អាចទទួលបានឥណទានការបោន ជាប្រភពចំណូល បន្ថែម។
- មិនចាំបាច់តម្រូវឲ្យមាន ការគ្របសំណល់នៅទីលានចាក់សំណល់ជារៀងរាល់ថ្ងៃ។
- ពន្យារអាយុកាលទីលានចាក់សំរាម យ៉ាងតិចបានពីរដង ព្រោះតាមរយៈធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក សំណល់ថយមាឌដល់ទៅ៥០ភាគរយ (ដង់ស៊ីតេសំណល់ ១,៣តោន ក្នុងមួយម៉ែត្រគូប។
- សំណល់បានពីធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិកអាច យកទៅដុតយកចំហាយកំដៅ និងប្លាស្ទិកចម្រាញ់យកប្រេង។

សំណល់មិនមានការញែកចំនួន ១០០ តោន

ក្រោយពីធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក ទទួលបាន

- ៣០ តោន ជាសំណល់ដែលមានចំហេះខ្ពស់
- ៣០ តោនជាសំណល់ដែលមានលក្ខណៈស្រដៀងនឹងកុំប៉ុស

| ចំណាយគិតជាប្រាក់បាត ក្នុងមួយតោន | ទីលានចាក់សំរាម | ធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក | ធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក | ធ្វើប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក |
|---|---|---|---|---|

| សំណល់ | | និង ទីលានចាក់សំរាម | និងដុតចម្រាញ់ | ដុតចម្រាញ់ និងដុតយកចំហាយក្តៅ |
|---|---|---|---|---|
| វិនិយោគ | ១០០ | ១០០ | ១០០ | ១០០ |
| ប្រតិបត្តិការ | ២០០ | ៣០ | ៣០ | ៣០ |
| គ្រប់គ្រងបន្ត | ៥០ | | | |
| ប្រព្រឹត្តិកម្មតាមបែបជីវៈមេកានិក | | ៣៥០ | ៣៥០ | ៣៥០ |
| ដុតចម្រាញ់ | | | ចំណូល ១៥០ | ចំណូល ១៥០ |
| ដុតយកចំហាយក្តៅ | | | | ចំណូល ១០០ |
| សរុប | ៣៥០ | ៤៨០ | ៣៣០ | ២៣០ |